សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of law and Economics


**សារណាបញ្ចប់ការសិក្សា**

# ភាពជាពលរដ្ឋ និងការទទួលបានសញ្ជាតិខ្មែរ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤


រៀបរៀងដោយៈ

និស្សិតឈ្មោះ កញ្ញា **ហេង ស៊ីនាថ**

ណែនាំដោយៈ

លោកស្រី **ស្រី វណ្ណធី**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្ដីថ្លែងអំណរគុណ

នាងខ្ញុំឈ្មោះ **ហេង ស៊ីនាថ** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្រ្តជំនាន់ទី២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០-២០២៤។

## សូមសម្ដែងនូវកតញ្ញូតាធម៌គោរពដឹងគុណចំពោះ

លោកឪពុកអ្នកម្ដាយ ដែលបានផ្ដល់កំណើត បីបាច់ថែរក្សានាងខ្ញុំប្រកបដោយព្រហ្មវិហារធម៌និងតែងតែអប់រំ ទូន្មានប្រៀនប្រដៅនាងខ្ញុំអោយខិតខំយកចិត្តទុកដាក់រៀនសូត្រជាទៀងទាត់ពីព្រោះ លោកទាំងពីរយល់ថាចំណេះដឹងគឺជាទ្រព្យសម្បត្តិដ៏មានតម្លៃកាត់ថ្លៃពុំបានលើសទ្រព្យនានា ហើយលោកតែងតែជួយទំនុកបម្រុងគ្រប់បែបយ៉ាងដើម្បីឱ្យ នាងខ្ញុំទទួលបានការសិក្សាតាំងពីបឋមសិក្សា រហូតដល់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ ដោយពុំខ្លាចនឿយហត់គ្រប់បែបយ៉ាងធ្វើយ៉ាងណាអោយតែនាងខ្ញុំបានសិក្សាដោយយកចិត្តទុកដាក់និងងាយស្រួល។

## សូមសម្ដែងនូវការគោរពដឹងគុណចំពោះ

**លោកស្រី ស្រី វណ្ណាធី** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ក្នុងការណែនាំកិច្ចការសារណាមួយនេះ ដោយលោកស្រី បានផ្ដល់នូវគំនិតល្អៗជាច្រើនរួមនិងការចែករំលែកជាបទពិសោធន៍ និងឯកសារចាំបាច់សម្រាប់ចងក្រងសារណានេះ លើសពីនេះលោកស្រីបានចំណាយពេលវេលាដ៏មមាញឹក ក្នុងការកែតម្រូវរាល់កំហុសឆ្គងក្នុងការចងក្រង ដើម្បីឈានដល់ការសម្រេចបាននូវសមិទ្ធិផលសារណាមួយនេះដោយជោគជ័យ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមបណ្ឌិត សាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្រ្តាចារ្យ និងបុគ្គលិកទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ចដែលបានដឹកនាំគ្រប់គ្រងគ្រប់ផ្នែកយ៉ាងយកចិត្តទុកដាក់ និងបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយចិត្ត ព្រមទាំងពេលវេលាដ៏មានតម្លៃ ក្នុងការបង្ហាត់បង្រៀននាងខ្ញុំ អោយទទួលបាននូវចំណេះដឹងយ៉ាងច្បាស់លាស់ក្នុងការប្រកបវិជ្ជាជីវៈក្នុងវិស័យច្បាប់នាអនាគតដ៏ខ្លី។

ជាចុងបញ្ចប់នេះ នាងខ្ញុំសូមប្រសិទ្ធពរជ័យជូនដល់ លោកអ្នកមានគុណ ឯកឧត្តមបណ្ឌិតសាកលវិទ្យធិការ សាកលវិទ្យាធិការរង សាស្រ្តាចារ្យ សាស្រ្តាចារ្យរង សាស្រ្តាចារ្យជំនួយ លោក/លោកស្រី និង បុគ្គលិកសិក្សាទាំងអស់ អោយទទួលបាននូវព្រះពុទ្ធមង្គលពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងជៀសឆ្ងាយពីជំងឺដង្កាត់នានា និងបានជោគជ័យនូវរាល់ភារៈកិច្ចទាំងឡាយទាំងពួង។

# អារម្ភកថា

សារណាថ្នាក់បរិញ្ញាបត្រ គឺជាឯកសារស្រាវជ្រាវឯករាជ្យ ដែលនិស្សិតចងក្រងសរសេរឡើងដើម្បីតម្រូវការសម្រាប់ការបញ្ចប់ថ្នាក់បរិញ្ញាបត្រ សារណាថ្នាក់បរិញ្ញាបត្រ ក៏ជាគម្រោងស្រាវជ្រាវដ៏ទូលំទូលាយមួយ ដើរតួនាទីជាស្នូលដើម្បីឲនិស្សិតទទួលបាននូវបទពិសោធន៍ថ្មីក្រៅពីការសិក្សាក្នុងថ្នាក់ ហើយវាក៏បង្ហាញពីសមត្ថភាពរបស់និស្សិតក្នុងការធ្វើការស្រាវជ្រាវ វិភាគទិន្នន័យ និងបង្ហាញការរកឃើញលើប្រធានបទជាក់លាក់ណាមួយទាក់ទងនឹងវិស័យសិក្សារបស់និស្សិត ម្យ៉ាងវិញទៀតនិស្សិតក៏ទទួលបានកាណែនាំពីសាស្ត្រាចារ្យដឹកនាំសារណាអំពីដំណើរការស្រាវជ្រាវ វិធីសាស្ត្រ និងការសរសេរសារណា ដែលជាពុទ្ធិដ៏មានសារៈសំខាន់សម្រាប់ការប្រកបវិជ្ជាជីវៈក្រោយបញ្ចប់ការសិក្សារបស់និស្សិត។

ដោយនាងខ្ញុំមើលឃើញនូវសារៈសំខាន់របស់សារណា សម្រាប់អភិវឌ្ឍអាជីពការងារនាថ្ងៃមុខក៏ដូចការបង្កើនសម្ថភាពតាមរយៈការសិក្សាស្រាវចងក្រងសារណាដែលជាបទពិសោធន៍ថ្មីសម្រាប់នាងខ្ញុំ ព្រមទាំងជាឯកសារសម្រាប់សិក្សាស្រាវជ្រាវសម្រាប់និស្សិតជំនាញ់ក្រោយនិងសាធារណជនទូទៅ ទើបនាងខ្ញុំសម្រេចចងក្រងសារណាដែលមានចំណងជើងថា **ភាពជាពលរដ្ឋ និងការទទួលបានសញ្ជាតិខ្មែរ** នេះឡើងដើមសិក្សាស្រាវជ្រាវចងក្រង ពីព្រោះនាងខ្ញុំយល់ប្រធានបទនេះមានសារប្រយោជន៍ខ្លាំងណាស់សម្រាប់ប្រជាពលរដ្ឋដែលចង់ស្វែងយល់អំពីសិទ្ធិនិងករណីយកិច្ចរបស់ខ្លួន រួមនិងការផ្តល់ភាពងាយដល់អ្នកអានដែលចង់សិក្សាស្វែងយល់អំពីបែបបទនិងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរ ក្នុងសម័យសកលភាវូបនីយកម្មនេះ ដោយហេតុថាបច្ចុប្បន្ននេះលំហូរជនបរទេសដែលចូលមកវិនិយោគក្នុងប្រទេសកម្ពុជាមានចំនួនកើនឡើងជាលំដាប់ ហើយជនបរទេសមួយចំនួនក៏ស្រលាញ់ពេញចិត្តក្នុងការរស់នៅប្រទេសកម្ពុជានឹងចង់ក្លាយជាប្រជាពលរដ្ឋកម្ពុជា តាមរយៈការរៀបការនិងការវិនិយោគឬការធ្វើវិភាគទានដើម្បីទទួលបានសញ្ជាតិខ្មែរ ប៉ុន្តែលក្ខខណ្ឌនិងនីតិវិធីក្នុងចូលសញ្ជាតិលំអិតពួកគាត់ពុំសូវបានយល់ឡើយ អាស្រ័យហេតុនេះទើបនាងខ្ញុំសម្រេចចិត្តជ្រើសរើសប្រធានបទដ៏មានសារសំខាន់នេះមកស្រាវជ្រាវចងក្រងពន្យល់លម្អិតដល់អ្នកដែលចង់ស្វែងយល់អំពីបែបបទនិងនីតិវិធីចាំបាច់សម្រាប់ទទួលបានសិទ្ធិជាពលរដ្ឋ និងការទទួលបានសញ្ជាតិខ្មែរស្របតាមច្បាប់និងលិខិតបទដ្ឋានជាធរមាន។

ជាទីបញ្ចប់ ដោយសាការចងក្រងសារណាជាបទពិសោធន៍ថ្មីថ្មោងសម្រាប់នាងខ្ញុំ នៅឡើយ ហើយសម្ថភាពសិក្សាស្រាវជ្រាវរបស់នាងខ្ញុំនៅមានកម្រិតនៅឡើយ ដែលធ្វើអោយមានចំណុចខុសឆ្គងខ្វះខាតជាក់ជាពុំខាន ទៅលើ ការបកស្រាយប្រធានបទ អក្ខរាវិរុទ្ធ និងកង្វះខាតនានា។ អាស្រ័យហេតុនេះ នាងខ្ញុំសូមធ្វើការអធ្យាស្រ័យអភ័យទោស រាល់កំហុសឆ្គងដែលកើតឡើងដោយ អចេតនា និងសូមទទួលយករាល់មតិយោបល់កែតម្រូវនិង ការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោក លោកស្រីសាស្ត្រាចារ្យដែលគណកម្មការវាយតម្លៃ បងប្អូនអ្នក

សិក្សាស្រាវជ្រាវ និងសាធារណជនទាំងឡាយ ទាំងអស់ ដើម្បីឱ្យសារណានេះមានលក្ខណល្អប្រសើរឡើងបន្ថែមមួយកម្រិតទៀតសម្រាប់ជាឯកសារដ៏មានសារប្រយោជន៍សម្រាប់បម្រើការសិក្សាស្រាវជ្រាវ។

# មាតិកា

**ទំព័រ**

**សេចក្ដីផ្ដើម** .................................................................................................. ១

**ជំពូកទី១**

**ភាពជាពលរដ្ឋសកល និងភាពជាពលរដ្ឋខ្មែរស្របតាមរដ្ឋធម្មនុញ្ញ**

**ផ្នែកទី១ ការកកើតរដ្ឋនិងភាពជាពលរដ្ឋសកល** ............................................................ ៤

១.១ ការកកើតរដ្ឋ .................................................................................................. ៤

១.២ ភាពជាពលរដ្ឋសកលស្របតាមច្បាប់អន្តរជាតិ ................................................................ ៦

**ផ្នែកទី២ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរស្របតាមច្បាប់** .................................. ៦

១.២.១ សិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ..................................................................................... ៨

១.២.២ ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ........................................................................ ១០

**ជំពូកទី២**

**លក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែរ នីតិវិធីនៃការស្នើសុំ និង សារប្រយោជន៍នៃសញ្ជាតិនិងគោលការណ៍ច្បាប់អន្តរជាតិទប់ស្កាត់ស្ថានភាពនិរេតិកជន**

**ផ្នែកទី១ លក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែរ** ........................................................ ១២

១.ការទទួលបានសញ្ជាតិខ្មែរពីកំណើត ........................................................................ ១២

២.ការទទួលបានសញ្ជាតិខ្មែរតាមរយៈសុំកូនពេញលេញ ....................................................... ១៣

៣.ការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍ ................................................... ១៥

៤.ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម............................................................ ២០

៤.១ ជនបរទេសណាដែលបានទទួលការអនុញ្ញាតឲវិនិយោគត្រឹមត្រូវតាមច្បាប់ ........................ ២១

៤.២ ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ....................................២១

៤.៣ ជនបរទេសដែលបានបង្ហាញនូវកស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយ..........................................................................................................២២

៤.៤ ជនបរទេសមិនមែនអន្តោប្រវេសន៏ ..........................................................................២២

៤.៥ ជនបរទេសអន្តោប្រវេសន៍ ....................................................................................២៣

៤.៦ ជនបរទេសអន្តោប្រវេសន៏ជាអ្នកវិនិយោគឯកជន..........................................................២៣

**ផ្នែកទី២ នីតិវិធីនៃការស្នើសុំសញ្ជាតិ ស្របតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន និងបណ្តឹងតវ៉ា**..........................................................................................................២៤

**១. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរពីកំណើត**..................................................................២៤

២. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរតាមរយៈការសុំកូនពេញលេញ ...................................៣២

៣. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍.................................៣៦

៤. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មស្របតាមលិខិតបទដ្ឋានជាធរមាន..........................................................................................................៣៨

**ផ្នែកទី៣ សារប្រយោជន៍នៃសញ្ជាតិនិងគោលការណ៍ច្បាប់អន្តរជាតិទប់ស្កាត់ស្ថានភាពនិរេតិកជន**..........................................................................................................៤៤

**១ គោលការណ៍នៃការបាត់បង់សញ្ជាតិខ្មែរ**.............................................................................៤៤

១.១ តាមការស្ម័គ្រចិត្តរបស់សាមីខ្លួន...............................................................................៤៤

១.១.១ លក្ខខណ្ឌ....................................................................................................៤៤

១.១.២ អានុភាព.....................................................................................................៤៦

១.២ តាមរយៈទោសទណ្ឌ...........................................................................................៤៦

១.២.១ លក្ខខណ្ឌ....................................................................................................៤៥

១.២.២ អានុភាព...................................................................................................... ៤៧

**២ គោលការណ៍ច្បាប់អន្តរជាតិ** ...................................................................................... ៤៧

២.១ អនុសញ្ញាទីក្រុងញូយ៉ក ឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានសញ្ជាតិ........................................................................................................................ ៤៧

ក.ខ្លឹមសារ ...................................................................................................................... ៤៧

ខ.ការអនុវត្តនិងចំនួនប្រទេសចូលរួមហត្ថលេខី ......................................................... ៤៨

គ.លទ្ធផល ....................................................................................................................... ៤៩

**៣ សារៈប្រយោជន៍នៃការទទួលបានសញ្ជាតិ** ...................................................................... ៥០

៣.១ ភាពជាពលរដ្ឋតាមច្បាប់ជាតិ និងអន្តរជាតិ ............................................................ ៥០

៣.២ ទទួលបានសិទ្ធិស៊ីវិល នយោបាយ និង និងភាពជាពលរដ្ឋនៃប្រទេសពេញបរិបូណ៌ ......... ៥០

៣.៣ ការលុបបំបាត់ភាពរើសអើងជនជាតិដើមភាគតិចដែលទទួលបានសញ្ជាតិខ្មែរ................ ៥២

៣.៤ ការគោរពនូវគោលការណ៍សន្ធិសញ្ញាស្តីពីការលុបបំបាត់ជនគ្មានសញ្ជាតិលើដែនដីកំណើតរបស់ខ្លួន.............................................................................................................................. ៥៥

៣.៥ ការពូកិច្ចរបស់រាជរដ្ឋាភិបាលក្នុងការបម្រើនិងគិតគូរដល់ប្រជាពលរដ្ឋរបស់ខ្លួន................ ៥៦

**សេចក្តីសន្និដ្ឋាន**.................................................................................................................. ៥៧

**អនុសាសន៍**......................................................................................................................... ៥៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហា

ក្រោយបោះឆ្នោតជាតិឆ្នាំ ១៩៩៣ ព្រះរាជាណាចក្រកម្ពុជាទី២បានចាប់កំណើតឡើង រដ្ឋធម្មនុញ្ញថ្មីដែលជាច្បាប់កំពូលជាតិត្រូវបានតាក់តែងឡើងស្របតាមស្ថានភាពជាក់ស្តែងរបស់ព្រះរាជាណាចក្រកម្ពុជា ផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យ សេរីពហុបក្ស ធានាសិទ្ធិ មនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ ចំពោះវាសនាប្រទេសជាតិ បានកំពុងរីកចម្រើនលូតលាស់ រុងរឿងជានិច្ចនិរន្តរ៍ រាល់បណ្តាស្ថាប័នអង្គការកំពូលៗរបស់ជាតិត្រូវបានបង្កើតឡើងស្របតាមរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូលរបស់ជាតិ រួមមាន ស្ថាប័ននីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ ក្រោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុបានបង្កើតឡើងជាផ្លូវការតាមរយៈកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសឆ្នាំ ១៩៩១ និងការបោះឆ្នោតឆ្នាំ ១៩៩៣ គឺជាពេលវេលាដ៏សំខាន់សម្រាប់កម្ពុជា ក្នុងការផ្លាស់ប្តូររបស់ប្រទេសពីជម្លោះជាច្រើនទសវត្សរ៍ និងអស្ថិរភាពទៅកាន់ដំណាក់កាលនៃការកសាងឡើងវិញ ការផ្សះផ្សា និងសមាហរណកម្មចូលទៅក្នុងសហគមន៍អន្តរជាតិ។ ជាមួយគ្នានេះផងដែររាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បានយកចិត្តទុកលើកកម្ពស់សិទ្ធិរបស់ពលរដ្ឋស្របតាមជំពូកទី៣ នៃរដ្ឋធម្មនុញ្ញដែលបានចែងអំពី សិទ្ធិ និងករណីយកិច្ច របស់ប្រជាពលរដ្ឋខ្មែរ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តិនានាក៏ត្រូវបានតាក់តែងចងក្រងឡើងស្រមតាមស្ថានភាពសង្គមជាក់ស្តែង ក្រោយមកទៀតច្បាប់រដ្ឋធម្មនុញ្ញទទួលបានការធ្វើវិសោធនកម្មចំនួន ១០ លើក គិតត្រឹមខែសីហា ឆ្នាំ២០២២។

តាមរយៈស្ថិរភាពនយោបាយនិងការលើកកម្ពស់សិទ្ធិរបស់ពលរដ្ឋដែលមានចែងនៅក្នុងច្បាប់ ប្រជាពលរដ្ឋខ្មែរពេញលេញ ក្នុងការរស់រានមានជីវិតប្រកបការងារ រៀបមង្គលការ ធ្វើដំណើរដោយសេរីទាំងក្នុងនិងក្រៅប្រទេសនិងការទទួលបានសញ្ជាតិខ្មែរស្របតាមច្បាប់ រួមជាមួយគ្នានេះផងដែរ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ទោះជាការខិតខំប្រឹងប្រែងដើរទៅមុខយ៉ាងមុះមុតយ៉ាងណាក៏ដោយ ក៏ភាពខ្វះចន្លោះនៅតែមានដូចជាស្រមោលអន្ទោលតាមប្រាណដូច្នេះដែរ។

ហេតុដូចនេះ ទើបជាឱកាសនៃមូលហេតុក្នុងការជ្រើសរើសប្រធានបទស្តីអំពី **ភាពជាពលរដ្ឋ និងការទទួលបានសញ្ជាតិខ្មែរ** មកជាគោលនៃការសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាប័ត្រនីតិសាស្ត្ររបស់ខ្ញុំផង និងក៏ជាប្រធានបទដែលពុំធ្លាប់មានការចាប់អារម្មណ៍ពីនិស្សិតរៀមច្បងពីមុនផងដែរ។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រជាជនទាំងអស់រស់នៅលើទឹកដីនៃប្រទេសមួយ មិនប្រាកដថាទទួលបានសញ្ជាតិនៃប្រទេសនោះឡើយ បើទោះជាគោលការណ៍នេះមានចែងនៅក្នុងច្បាប់អន្តរជាតិក៏ដោយ តើច្បាប់នៃព្រះរាជាណាចក្រកម្ពុជា បានកំណត់អំពី លក្ខខណ្ឌបែបបទនិងនីតិវិធីអ្វីខ្លះដើម្បីទទួលបានសញ្ជាតិខ្មែរ? តើច្បាប់ស្ដីអំពីសញ្ជាតិខ្មែរមានការវិវត្តន៍យ៉ាងដូចម្ដេច? តើប្រជាពលរដ្ឋខ្មែរមានសិទ្ធិ និងករណីយកិច្ច អ្វីខ្លះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

គោលបំណងនៃការសិក្សាស្រាវជ្រាវចងក្រងសារណានេះឡើង គឺដើម្បីផ្ដោតសំខាន់លើការពិនិត្យមើលគោលការណ៍រដ្ឋធម្មនុញ្ញ និងច្បាប់ដែលបញ្ជាក់ពីសិទ្ធិ និងកាតព្វកិច្ចរបស់ពលរដ្ឋ។ សិក្សាស្វែងយល់អំពីលក្ខខណ្ឌច្បាប់បែបបទនិងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរ សិក្សាពីការការវិវត្តន៍នៃច្បាប់សញ្ជាតិចាប់ឆ្នាំ១៩៩៦ មកទល់បច្ចុប្បន្ននេះ និងសិក្សាអំពីសារសំខាន់របស់ច្បាប់នេះសម្រាប់រួមដំណែកអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិតាមរយៈការទាក់ទាញអ្នកវិនិយោគនិងជនបរទេសមកវិនិយោគនិងរស់នៅប្រទេសកម្ពុជា និងដើម្បីទុកជាស្នាដៃឯកសារស្រាវជ្រាវមួយដែលចូលរួមបង្កើនជាប្រយោជន៍ និងផ្ដល់ជាពុទ្ធិសម្រាប់និស្សិតជំនាន់ក្រោយដើម្បី មានលទ្ធភាពបន្តធ្វើការស្រាវជ្រាវបន្ថែមលើប្រធានបទនេះ។

## ៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទនេះ ផ្ដោតសំខាន់លើ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរស្របតាមរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ និងវិសោធនកម្មនានារហូតមកទល់បច្ចុប្បន្ននេះតែប៉ុណ្ណោះ ចំពោះលក្ខខណ្ឌច្បាប់បែបបទនិងនីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរត្រូវលើកយកមកសិក្សាស្រាវជ្រាវ ចាប់ពីឆ្នាំ ១៩៩៦ មកទល់បច្ចុប្បន្ននេះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

ចែករំលែកការយល់ដឹងអំពីច្បាប់ស្ដីពីសញ្ជាតិ ជាឯកសារជំនួយក្នុងការយល់ដឹងអំពីក្របខ័ណ្ឌច្បាប់ជុំវិញការទទួលបានសញ្ជាតិខ្មែរនៅក្នុងប្រទេសកម្ពុជា រួមទាំងសិទ្ធិ និងកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ និងដើម្បីផ្ដល់អនុសាសន៍លើការស្រាវជ្រាវសម្រាប់ការកែលម្អ ឬកំណែទម្រង់ដែលដោះស្រាយបញ្ហាប្រឈមបច្ចុប្បន្នក្នុងក្របខ័ណ្ឌសញ្ជាតិ។ជាឯកសារសម្រាប់និស្សិត និងអ្នកស្រាវជ្រាវ វាផ្ដល់នូវការយល់ដឹងដ៏ទូលំទូលាយអំពីទិដ្ឋភាពសំខាន់ៗនៃច្បាប់ និងសង្គមកម្ពុជា។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវមួយនេះ ទទួលបានការណែនាំផ្ទាល់ពី **លោកស្រី ស្រី វណ្ណធី** នូវអនុសាសន៍ល្អៗ ការកែតម្រូវចំណុចខ្វះខាតនានា ព្រមទាំងទទួលបានគំនិតផ្សេងៗពី រៀមច្បងមេធាវី និងអ្នកជំនាញក្នុងវិស័យច្បាប់ ព្រមទាំងសិក្សាទៅ លិខិតបទដ្ឋានគតិយុត្តិរួមមាន ច្បាប់ អនុក្រឹត្យ ប្រកាស ឯកសារណែនាំផ្លូវការនានា រួមនិងឯកសារដែលមានតម្កល់ទុកក្នុង បណ្ណាល័យនៃសាកលវិទ្យាល័យ ភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច និងបណ្ណាល័យ និងឯកសារតាមបណ្ណាល័យនានា និងតាមរយៈប្រព័ន្ធអ៊ីនធើណែតជាដើម។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវលើប្រធានបទខាង ត្រូវបែងចែកជា ២ជំពូក ក្នុងនោះរួមមាន **ជំពូកទី១ ភាពជាពលរដ្ឋសកល និងភាពជាពលរដ្ឋខ្មែរស្របតាមរដ្ឋធម្មនុញ្ញ ជំពូកទី២ លក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែរ នីតិវិធីនៃការស្នើសុំ និង សារប្រយោជន៍នៃសញ្ជាតិនិងគោលការណ៍ច្បាប់អន្តរជាតិទប់ស្កាត់ស្ថានភាពនិបេតិកជន រួមជាមួយនូវសេចក្តីសន្និដ្ឋាន អនុសាសន៍ ឯកសារយោង ឧបសម្ព័ន្ធផងដែរ។**

# ជំពូកទី១

# ភាពជាពលរដ្ឋសកល និងភាពជាពលរដ្ឋខ្មែរស្របតាមរដ្ឋធម្មនុញ្ញ

## ផ្នែកទី១ ការកកើតរដ្ឋនិងភាពជាពលរដ្ឋសកល

### ១.១ ការកកើតរដ្ឋ

និយមន័យរបស់រដ្ឋនៅក្នុងវិទ្យាសាស្ត្រនយោបាយ គឺជាអង្គភាពនយោបាយដែលគ្រប់គ្រងសង្គម និងប្រជាជននៅក្នុងទឹកដីមួយ វាច្រើនតែមានន័យដូចនឹងប្រទេសមួយ។[1]និយមន័យរបស់រដ្ឋក៏មានការបកស្រាយពន្យល់តាមទ្រឹស្តីផ្សេងៗផងដែរ។ លក្ខណៈស្នូលដែលបានរៀបរាប់ខាងលើរបស់រដ្ឋគឺ (អធិបតេយ្យភាព ទឹកដី ចំនួនប្រជាជន និងរដ្ឋាភិបាល)។ បើតាមទ្រឹស្តីកិច្ចសន្យាសង្គមៈ ទ្រឹស្តីនេះបង្ហាញថាបុគ្គលស្ម័គ្រចិត្តលះបង់សេរីភាពខ្លះរបស់ពួកគេដើម្បីបង្កើតរដ្ឋសម្រាប់ផលប្រយោជន៍ទៅវិញទៅមក។

អនុសញ្ញាទីក្រុងម៉ុងតេវីដេអូ ( **Montevideo Convention on the Rights and Duties of States** ) ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ១៩៣៣ ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋ បានឱ្យនិយមន័យក្នុងមាត្រា ១ បញ្ញត្តថា រដ្ឋ ក្នុងឋានៈជានីតិបុគ្គលអន្តរជាតិ ត្រូវមានលក្ខណៈ វិនិច្ឆ័យដូចតទៅ ៖ មានទឹកដីជាក់លាក់ (Defined Territory) មានប្រជាពលរដ្ឋអចិន្ត្រៃយ៍ (Permanent Population) មានរដ្ឋាភិបាល ឬអំណាចគ្រប់គ្រងរដ្ឋ (Government) និងសមត្ថភាពធ្វើការ ទាក់ទងជាមួយរដ្ឋដទៃទៀត (មានឯករាជ្យអធិបតេយ្យ) ។[2]

**ទឹកដី (Territory)** ទឹកដី គឺជាលំហមួយ ដែលមានព្រំដែនខណ្ឌសីមាកំណត់ត្រឹមត្រូវ តាមច្បាប់អន្តរជាតិសម្រាប់ឱ្យរដ្ឋដំណើរការសកម្មភាពនៃអំណាច ក្នុងអធិបតេយ្យភាពពេញលេញរបស់ខ្លួន ។ ប្រសិនបើគ្មានទឹកដី រដ្ឋក៏គ្មានដែរ ។ ទឹកដី មិនកំណត់ពីទំហំតូច ធំ ឬមធ្យមទេ ហើយបែង ចែកជាបី គឺដែនគោក ដែនទឹក(សមុទ្រ) និងដែនអាកាស ។ ឧទាហរណ៍ អាមេរិកមានផ្ទៃ ក្រឡា ៩.៣៦៤.០០០ $km^2$អង់គ្លេស ២៤៣.៥០០ $km^2$ កម្ពុជា ១៨១.០៣៥ $km^2$ ស្វីស ៤១.២៩៣ $km^2$ លុច្សសំបួរ ២.៥៨៦ $km^2$ សឹង្ហបូរី៦៣៩ $km^2$ ទូវ៉ាលូ ២៦ $Km^2$ ជាដើម ។[3]

---

1 យោងគេហទំព័រ state | Wex | US Law | LII / Legal Information Institute

2 ខាំ សុមករា, រដ្ឋបាលសាធារណៈ, ២០១៨, ៧

3 ខាំ សុមករា, រដ្ឋបាលសាធារណៈ, ២០១៨, ៨

**ប្រជាពលរដ្ឋ** (Population) ជាសម្ព័ន្ធមនុស្ស ដែលជាសមាជិករបស់រដ្ឋ ជាធាតុចាំបាច់សម្រាប់រដ្ឋ ទោះជាមានចំនួន ច្រើនឬតិច ក្រឬមាន ក៏គេចាត់ទុកជាប្រទេស ដែលមានសម្លេងមួយដូចគ្នា នៅអង្គការសហប្រជាជាតិ ។ ជាក់ស្តែង ប្រទេសចិន មានប្រជាពលរដ្ឋចំនួន ១២២.១,៥ លាននាក់ អាឡឺម៉ង់ ៨១.៥៩ លាននាក់ ម៉ូណាកូ ៣២.០០០ នាក់ (ឆ្នាំ១៩៩៤) ថៃ ៦៦.៣២ លាននាក់ ព្រុយណេ ៣៨២.០០០ (២០០៨) ។ សម្ព័ន្ធនៃប្រជាពលរដ្ឋត្រូវផ្សាភ្ជាប់រួមគ្នា ដោយសាសនា ភាសា និងពូជអំបូរ ប៉ុន្តែតាមច្បាប់ យើងអាចកំណត់សមាជិករបស់រដ្ឋត្រឹមតែសញ្ជាតិប៉ុណ្ណោះ ទោះជាមានភាសា ជាតិសាសន៍ វប្ប ធម៌ និងប្រវត្តិសាស្ត្រខុសគ្នាក៏ដោយ ។ សញ្ជាតិចេញមកពីប្រជាជាតិ ។[4]

**ប្រជាជាតិ** (Nation) មានន័យច្រើន តែគេអាចឱ្យនិយមន័យ បី យ៉ាង ៖

ប្រជាជាតិ គឺជាការរួមផ្តុំគ្នានៃជនដែលមានចរិតលក្ខណៈរួម គឺភាសាជាតិសាសន៍ពីកំណើត សាសនាដូចគ្នា ។ល។

ប្រជាជាតិ គឺសំដៅជនទាំងអស់ ដែលនិយមវប្បធម៌ ដូចគ្នា មានអក្សរសាស្ត្រ សិល្បៈ និង ប្រវត្តិសាស្ត្រ រួមជាមួយគ្នាជាដើម ។ល។

ប្រជាជាតិ អាចសន្មតយកត្រឹមតែឆន្ទៈរួម របស់ជនទាំងឡាយដែលប្រាថ្នាចងរួមរស់ក្នុងរដ្ឋតែមួយជាមួយគ្នា។[5]

**សញ្ជាតិ** (Nationality) ជាចំណងខាងផ្លូវច្បាប់ និង នយោបាយ ដែលចងភ្ជាប់បុគ្គលម្នាក់ ទៅនឹងរដ្ឋអធិបតេយ្យមួយ ។ រដ្ឋនីមួយៗ មានសេរីភាពពេញលេញ ក្នុងការផ្តល់សញ្ជាតិនេះ ទៅឱ្យ បុគ្គលណាម្នាក់ ដើម្បីក្លាយទៅជាពលរដ្ឋរបស់ខ្លួន ។[6]

**រដ្ឋាភិបាល** (Government) រដ្ឋាភិបាល ជាធាតុសំខាន់ទី៣ របស់រដ្ឋ ពីព្រោះបើមានទឹកដីត្រូវតែមានប្រជាពលរដ្ឋ ហើយបើមានប្រជាពលរដ្ឋ ត្រូវតែមានការរៀបចំ ដូច្នេះត្រូវមានរដ្ឋាភិបាលគ្រប់គ្រង និងដឹកនាំ ។ រដ្ឋាភិបាលជានិមិត្តរូបតំណាងឱ្យរដ្ឋ ដឹកនាំកិច្ចការទូទៅរបស់រដ្ឋ គ្រប់គ្រងបញ្ហា ប្រើប្រាស់យោធា នគរបាល និងរដ្ឋបាលក្នុងការធ្វើសកម្មភាពរបស់ខ្លួន ក្នុងបំណងការពារទឹកដី និងអភិវឌ្ឍន៍ប្រទេស ឱ្យប្រជាពលរដ្ឋបានសុខសាន្ត ។ ដើម្បីទទួល

[4] ខាំ សុមករា, រដ្ឋបាលសាធារណៈ, ២០១៨, ៨

[5] ខាំ សុមករា, រដ្ឋបាលសាធារណៈ, ២០១៨, ៨

[6] ខាំ សុមករា, រដ្ឋបាលសាធារណៈ, ២០១៨, ៨

បានសមត្ថភាព លក្ខណសម្បត្តិជាអង្គការនីតិប្រតិបត្តិត្រឹមត្រូវតាមច្បាប់ រដ្ឋាភិបាល ត្រូវតែជា' ៖ រដ្ឋាភិបាលកើតចេញពីការទុកចិត្ត និងទទួលការគាំទ្រភាគច្រើនពីសំណាក់ប្រជាពលរដ្ឋ ។ គ្រប់គ្រងទឹកដីមួយភាគធំ ឬ ទាំងស្រុងពេញផ្ទៃប្រទេស ។ មានសមត្ថកិច្ចធ្វើការទាក់ទងជាមួយរដ្ឋដទៃ ។[7]

**ឯករាជ្យភាព និង អធិបតេយ្យភាព** (Independence - Sovereignty) ឯករាជ្យភាពរបស់រដ្ឋ មានន័យថា រដ្ឋនោះ មានសិទ្ធិអំណាចពេញលេញ នៅក្នុងការគ្រប់ គ្រងទឹកដី ប្រជាពលរដ្ឋ និងវិស័យទាំងអស់នៅក្នុងប្រទេស ដោះស្រាយចាត់ចែងកិច្ចការរបស់ខ្លួន ដោយសេរីខ្លួនឯង គ្មានការជ្រៀតជ្រែក ឬត្រួតត្រាពីខាងក្រៅ ។ ប្រទេសដែលប្រកាសថាខ្លួន ឯករាជ្យ (ទទួលបានឯករាជ្យ) ហើយមានការទទួលស្គាល់ជាផ្លូវការពីសហគមន៍អន្តរជាតិ ទើប ក្លាយទៅជារដ្ឋអធិបតេយ្យ ។ បន្ទាប់មករដ្ឋនោះមានសមត្ថភាពបង្កើតទំនាក់ទំនងអន្តរជាតិតាមផ្លូវ ច្បាប់ជាមួយរដ្ឋដទៃទៀតបាន ។ នៅពេលដែលរដ្ឋមួយជារដ្ឋអធិបតេយ្យរដ្ឋនោះទទួលបាននូវះសិទ្ធិស្វ័យសម្រេចជោគវាសនាដោយខ្លួនឯង(self determination) (បង្កើតដោយលោក Washington ក្នុង សេចក្តីប្រកាសឯករាជ្យរបស់អាមេរិក)។ បូរណភាពទឹកដី (Territorial Integrity) មានន័យថា រដ្ឋនីមួយៗមានសិទ្ធិអំណាច ការពារទឹក ដីរបស់ខ្លួនពេញលេញកុំឱ្យមានការបាត់បង់ ។ការមិនធ្វើអន្តរាគមន៍(Non-intervention) ពោលការមិនជ្រៀតជ្រែកលើកិច្ចការប្រទេសដទៃគឺការមិនធ្វើអន្តរាគមន៍សំណាក់រដ្ឋដទៃមកក្នុងកិច្ច ការផ្ទៃក្នុង និង ផ្ទៃក្រៅរបស់ខ្លួន (មានចែងក្នុងធម្មនុញ្ញអង្គសហប្រជាជាតិ ជំពូកទី ៧ )។ សមភាពរបស់រដ្ឋ (Equality State) មានន័យថា រដ្ឋមានភាពស្មើគ្នា តាមច្បាប់អន្តរជាតិ ពិសេសលើគោលការណ៍សម្លេងតែមួយដូចគ្នា ក្នុងសម័យប្រជុំអង្គការសហប្រជាជាតិ។[8]

## ១.២ ភាពជាពលរដ្ឋសកលស្របតាមច្បាប់អន្តរជាតិ

**ភាពជាពលរដ្ឋ** គឺជាស្ថានភាពផ្លូវច្បាប់ដែលផ្តល់សិទ្ធិ និងទំនួលខុសត្រូវជាក់លាក់ដល់បុគ្គលម្នាក់នៅក្នុងប្រទេសមួយ។ ជាទូទៅ វារួមបញ្ចូលសិទ្ធិក្នុងការរស់នៅ ធ្វើការ និងការបោះឆ្នោតជ្រើសរើសមេដឹកនាំ នៅក្នុងប្រទេសនោះ កាន់តំណែងសាធារណៈ ទទួលបានការអប់រំ ពលរដ្ឋត្រូវបានគាំពារដោយច្បាប់។ ជាការតបស្នងវិញ ប្រជាពលរដ្ឋត្រូវបានរំពឹងថានឹងគោរពច្បាប់របស់ប្រទេស និងរួមចំណែកដល់ការអភិវឌ្ឍសង្គមរបស់ខ្លួន។

[7] ខាំ សុមករា, រដ្ឋបាលសាធារណៈ:, ២០១៨, ៩

[8] ខាំ សុមករា, រដ្ឋបាលសាធារណៈ:, ២០១៨, ៩

ប្រជាពលរដ្ឋក៏ត្រូវមានទំនួលខុសត្រូវមួយចំនួនចំពោះប្រទេសជាតិផងដែរៈ ទាំងនេះអាចរួមបញ្ចូលការបង់ពន្ធ ការការពារប្រទេសប្រសិនបើចាំបាច់ ការគោរពច្បាប់ ប្រជាពលរដ្ឋជាធម្មតាត្រូវមានភក្ដីភាពចំពោះប្រទេសរបស់ខ្លួន មានន័យថាពួកគេស្មោះត្រង់ចំពោះជាតិ រដ្ឋាភិបាល និងច្បាប់របស់ប្រទេសខ្លួន។[9]

ក្រៅពីការគាំពារដោយច្បាប់របស់ប្រទេសនីមួយៗ ប្រជាពលរដ្ឋលើសកលលោកយើងនេះ ក៏បានការយកចិត្តទុកដាក់ពី អង្គការអន្តរជាតិនានាផងដែរ ជាពិសេសគឺអង្គការសហប្រជាជាតិ លើបញ្ហាលើកកម្ពស់សិទ្ធិមនុស្ស

សិទ្ធិរស់រានមានជីវិត និងសិទ្ធិចម្បងៗមួយចំនួនទៀត ដើម្បីឲការលើកកម្ពស់សិទ្ធិទាំងអស់នេះអោយមានប្រសិទ្ធិភាព អង្គការសហប្រជាជាតិ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅទូទាំងពិភពលោក ក្របខណ្ឌសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិបានចាប់ផ្ដើមជាមួយនឹងការបង្កើតអង្គការសហប្រជាជាតិនៅឆ្នាំ ១៩៤៥។ ធម្មនុញ្ញអង្គការសហប្រជាជាតិដែលត្រូវបានអនុម័តនៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ ១៩៤៥ បានសង្កត់ធ្ងន់លើការលើកកម្ពស់ និងការការពារសិទ្ធិមនុស្សជាគោលបំណងស្នូលមួយ។[10]

ហើយក៏ជាពេលវេលាសំខាន់ក្នុងការបង្កើតប្រព័ន្ធសិទ្ធិមនុស្សអន្តរជាតិក្នុងសម័យទំនើប ការអនុម័តសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស (UDHR) ដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨។ ឯកសារនេះដែលរៀបរាប់អំពីសិទ្ធិមនុស្សជាមូលដ្ឋានដែលគួរត្រូវបានការពារជាសកល ត្រូវបានចាត់ទុកថាជាមូលដ្ឋានគ្រឹះនៃច្បាប់សិទ្ធិមនុស្សអន្តរជាតិ ជាមួយនេះផងដែរកិច្ចព្រមព្រៀងនិងសន្ធិសញ្ញានានាក៏ត្រូវបង្កើតឡើងជាបន្តបន្ទាប់ ដើម្បីលើកកម្ពស់សិទ្ធិពលរដ្ឋជាសកល និងសិទ្ធិជនអន្តោប្រវេសន៍ និងជនដែលគ្មានរដ្ឋ និងសញ្ជាតិ ជាមួយគ្នានេះផងដែរ អង្គការសហប្រជាជាតិបានបង្កើតឡើងនៅការិយាល័យសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (OHCHR) គឺជាអង្គភាពសំខាន់របស់អង្គការសហប្រជាជាតិ ដែលទទួលខុសត្រូវក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្សនៅទូទាំងពិភពលោក មានមូលដ្ឋាននៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នាឆ្នាំ ១៩៩៣ បន្ថែមទៀតផងដែរ។[11]

## ផ្នែកទី២ សិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរស្របតាមច្បាប់

[9] https://migrationobservatory.ox.ac.uk//resources/primers/citizenship-what-is-it-and-why-does-it-matter
[10] https://www.un.org/en/about-us/universal-declaration-of-human-rights
[11] https://www.un.org/en/about-us/universal-declaration-of-human-rights

ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិ មនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាស ជាសកលស្ដីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំង ឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ។[12]

ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព អ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌ កំណត់ក្នុងច្បាប់ ។

ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និង មានសន្តិសុខផ្ទាល់ខ្លួន ទោសប្រហារជីវិតមិនត្រូវឱ្យមានឡើយ ។[13]

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យ ប្រទេសក្រៅណាមួយឡើយ លើកលែងតែមាន កិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបាន រដ្ឋគាំពារ ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។[14]

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបោះឆ្នោត និងអាច ឈរឈ្មោះឱ្យ គេបោះឆ្នោត ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច ៤០ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោតជ្រើសតាំងជាសមាជិកព្រឹទ្ធសភា បទប្បញ្ញត្តិបន្ថយសិទ្ធិបោះឆ្នោត និងសិទ្ធិឈរឈ្មោះឱ្យ គេបោះឆ្នោតត្រូវចែងក្នុងច្បាប់បោះឆ្នោត ។[15]

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្ម ក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌របស់ប្រទេស ជាតិ ។សេចក្ដីស្នើទាំងឡាយរបស់ប្រជាពលរដ្ឋ ត្រូវបានទទួល ការពិនិត្យ និងដោះស្រាយយ៉ាងហ្មត់ចត់ពីអង្គការរដ្ឋ ។[16]

[12] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣១

[13] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣២

[14] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣៣

[15] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣៤ ថ្មី

[16] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣៥

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរ សមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្ដីត្រូវការរបស់សង្គម ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ ស្មើគ្នាចំពោះការងារដូចគ្នា ការងារមេផ្ទះ មានតម្លៃស្មើគ្នានឹងកម្រៃដែលបានមក ពីការងារធ្វើនៅក្រៅផ្ទះ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលការធានារ៉ាប់រង សង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព នឹងមានកំណត់ក្នុងច្បាប់។[17]

សិទ្ធិធ្វើកូដកម្ម និងធ្វើបាតុកម្មដោយសន្តិវិធី ត្រូវយកមក អនុវត្តនៅក្នុងក្របខ័ណ្ឌនៃច្បាប់ ។[18]

ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភបំពានលើរូបរាងកាយ បុគ្គលណាមួយឡើយ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូរ របស់ប្រជាពលរដ្ឋ ការចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួន ឬការឃុំខ្លួន ជនណាមួយនឹងអាចធ្វើទៅកើត លុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិ ច្បាប់ ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តិកម្ម ណាមួយ ដែលបន្ថែមទម្ងន់ទណ្ឌកម្ម អនុវត្តចំពោះជនជាប់ឃុំឃាំង ឬ ជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ អ្នកដៃដល់ អ្នករួម ប្រព្រឹត្ត និងអ្នកសមគំនិត ត្រូវទទួលទោសតាមច្បាប់ ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាម ផ្លូវកាយក្ដី តាមផ្លូវចិត្តក្ដី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ វិមតិសង្ស័យ ត្រូវបានជាប្រយោជន៍ដល់ជនជាប់ចោទ ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ជនគ្រប់រូប មានសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ។[19]

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិប្ដឹងបរិហារ ប្ដឹងតវ៉ា ឬប្ដឹងទារ សំណងជួសជុលការខូចខាតដែលបណ្ដាលមកពីអំពើខុសច្បាប់របស់ អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិកនៃអង្គការទាំងនោះ ។ ការដោះស្រាយបណ្ដឹងតវ៉ា និងសំណងជួសជុលការខូចខាត ជាសមត្ថកិច្ចរបស់តុលាការ។[20]

សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថាន- ភាពស្របច្បាប់របស់ប្រជាពលរដ្ឋ ត្រូវបានគោរព ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេស ក្រៅ ឬវិលត្រឡប់មកវិញបាន ការរក្សាសិទ្ធិមិនឱ្យរំលោភ

---

[17] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣៦

[18] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣៧

[19] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣៨

[20] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៣៩

លំនៅឋាន និងអាថ៌កំបាំង នៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និងតាម ទូរស័ព្ទ ត្រូវបានធានា ការឆែកឆេរលំនៅឋាន សម្ភារៈវត្ថុ និងលើរូបបុគ្គល ត្រូវ ធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។[21]

ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយ មិនអាចឆ្លៀតប្រើសិទ្ធិនេះ ដោយរំលោភ នាំឱ្យប៉ះពាល់ដល់កិត្តិយសរបស់អ្នកដទៃ ដល់ទំនៀម ទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខ ជាតិបានឡើយ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។[22]

ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមនិងគណបក្ស នយោបាយ សិទ្ធិនេះត្រូវកំណត់ក្នុងច្បាប់ ប្រជាពលរដ្ឋខ្មែរទាំងឡាយ អាចចូលរួមក្នុងអង្គការ មហាជន ជួយគ្នាទៅវិញទៅមក ការពារសមិទ្ធផលជាតិ និងសណ្តាប់ធ្នាប់សង្គម ។[23]

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិពេញទីខាងជំនឿ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនាត្រូវ បានរដ្ឋធានាក្នុងល័ក្ខខ័ណ្ឌ ដែលមិនប៉ះពាល់ដល់ជំនឿ ឬសាសនាដទៃ ទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ ។[24]

ជនណាក៏ដោយ ទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិ ជាម្ចាស់កម្មសិទ្ធិ មានតែរូបវន្តបុគ្គល ឬនីតិបុគ្គលដែលមានសញ្ជាតិ ជាខ្មែរទេ ទើបមានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លី កម្មសិទ្ធិឯកជនស្របច្បាប់ស្ថិតនៅក្រោមការគាំពារនៃច្បាប់ ដែលនឹងដកហូតកម្មសិទ្ធិអំពីជនណាមួយបាននោះ លុះត្រា តែប្រយោជន៍សាធារណៈតម្រូវឱ្យធ្វើក្នុងករណីដែលច្បាប់បានបញ្ញត្តិ ទុក ហើយត្រូវផ្តល់សំណងជាមុន ដោយសមរម្យ និងយុត្តិធម៌ ។[25]

ការរើសអើងគ្រប់ប្រភេទ ប្រឆាំងនឹងស្ត្រីភេទ ត្រូវបំបាត់ចោល ការធ្វើអាជីវកម្មលើការងាររបស់ស្ត្រី ត្រូវហាមឃាត់បុរសនិងស្ត្រីមានសិទ្ធិស្មើគ្នាក្នុងគ្រប់វិស័យទាំងអស់ជា ពិសេសក្នុងអាពាហ៍ពិពាហ៍ និងគ្រួសារអាពាហ៍ពិពាហ៍ត្រូវធ្វើតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុង ច្បាប់ និងតាមគោលការណ៍ស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ។[26]

---

[21] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤០

[22] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤១

[23] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤២

[24] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤៣

[25] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤៤

[26] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤៥

អំពើលក់ដូរមនុស្ស អំពើធ្វើអាជីវកម្មផ្នែកពេស្យាកម្ម និង អំពើអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាម ឃាត់ ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់នារីពីការងារ ដោយ មូលហេតុមានគភ៌ នារីមានសិទ្ធិឈប់សំរាកនៅពេលសំរាលកូនដោយ ទទួលប្រាក់បៀវត្ស និងដោយមានការធានារក្សាសិទ្ធិអតីតភាពក្នុង ការងារ និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារី ជាពិសេស នារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម្ភ ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅ សមរម្យ ។[27]

មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សានិងអប់រំកូនឱ្យទៅ ជាពលរដ្ឋល្អ កូនត្រូវមានករណីយកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរា តាមទំនៀមទម្លាប់ខ្មែរ ។[28]

រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុង អនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការ អប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារ ក្នុងស្ថានការណ៍មាន សង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬកាមគុណ លើកុមារ ។រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយ ដែលអាចធ្វើឱ្យ ខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឲអន្តរាយ ដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។[29]

ប្រជាពលរដ្ឋខ្មែរគ្រប់រូបត្រូវគោរពរដ្ឋធម្មនុញ្ញ និងគោរពច្បាប់ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចរួមចំណែកកសាង ប្រទេសជាតិ និងការពារមាតុភូមិ កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ ។[30]

ប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពគោលការណ៍ អធិបតេយ្យជាតិ និងលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សប្រជាពលរដ្ឋខ្មែរទាំងពីរភេទត្រូវគោរពទ្រព្យសម្បត្តិ សាធារណៈ និងកម្មសិទ្ធិស្របច្បាប់របស់ឯកជន ។[31]

[27] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤៦
[28] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤៧
[29] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤៨
[30] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៤៩
[31] យោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, ១៩៩៣, មាត្រាទី ៥០

# ជំពូកទី២

# ការទទួលបានសញ្ជាតិខ្មែរ នីតិវិធីនៃការស្នើសុំ និងការបាត់បង់សញ្ជាតិ

## ផ្នែកទី១ លក្ខខណ្ឌនៃការទទួលបានសញ្ជាតិខ្មែរ

យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨ សញ្ជាតិខ្មែរ សំដៅដល់ចំណងគតិយុត្ត និងនយោបាយដែលភ្ជាប់រូបវន្តបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា ។[32] ជនណាមានសញ្ជាតិខ្មែរជាប្រជាពលរដ្ឋខ្មែរ មានតែប្រជាពលរដ្ឋខ្មែរទេ ទើបមានសិទ្ធិទទួលនិងកាន់កាប់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងលិខិត ឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។[33] ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។[34] ចំណែកឯប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស ត្រូវបានរដ្ឋគាំពារតាមគ្រប់មធ្យោបាយការទូត និងមិនអាចបាត់សញ្ជាតិដោយឯកឯងបានឡើយ ។[35]

សញ្ជាតិខ្មែរត្រូវផ្តល់ឲតាមរយៈ ការទទួលបានសញ្ជាតិខ្មែរពីកំណើត ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ ការទទួលបានសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម។[36]

### ១.ការទទួលបានសញ្ជាតិខ្មែរពីកំណើត

យោងតាមច្បាប់សញ្ជាតិខ្មែរ ២០១៨ បានពន្យល់ថា បុគ្គលត្រូវបានសញ្ជាតិខ្មែរពីកំណើត ទោះបីកើតនៅទីណាក៏ដោយចំពោះ កូនដែលកើតពីឪពុកឬម្តាយមានសញ្ជាតិខ្មែរឬម្តាយដែលមានសញ្ជាតិខ្មែរ និងត្រូវបានសញ្ជាតិខ្មែរពីកំណើត ដោយបានកើតក្នុងព្រះរាជាណាចក្រកម្ពុជា ចំពោះកូនដែលកើតពីឪពុកនិងម្តាយជាជនបរទេស ដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា កូនដែលកើតពីឪពុកម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។[37]

---

[32] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រាទី ៣

[33] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រាទី ៦

[34] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រាទី ៧

[35] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រាទី ៨

[36] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រាទី ២

[37] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រាទី ៩

## ២.ការទទួលបានសញ្ជាតិខ្មែរតាមរយៈសុំកូនពេញលេញ

កូនជនបរទេសដែលត្រូវបានសុំជាកូនសុំពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិ ខ្មែរ នៅពេលដែលសុំកូនពេញលេញត្រូវបានបង្កើតឡើង ស្របតាមច្បាប់ជាធរមាន ។[38]

សុំកូនពេញលេញ សំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនង អចិន្ត្រៃយ៍ ជាឪពុកម្តាយ និង កូនរវាងឪពុកម្តាយចិញ្ចឹម ឬ ឪពុកចិញ្ចឹម ឬ ម្តាយចិញ្ចឹម និង កូនសុំ នឹង បញ្ចប់សិទ្ធិ និង កាតព្វកិច្ចរវាងកូននិងឪពុកម្តាយបង្កើត ឬ អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់ខ្លួន អ្នកសុំសំដៅដល់ប្តីប្រពន្ធដែលកំពុងស្វះស្វែងសុំកុមារយកទៅចិញ្ចឹម ឪពុកម្តាយចិញ្ចឹម សំដៅដល់ ប្តីប្រពន្ធដែលបានទទួលសិទ្ធិជាផ្លូវការពី តុលាការមានសមត្ថកិច្ចឱ្យធ្វើជាឪពុកម្តាយថ្មីនៃកូនសុំស្របតាមបទប្បញ្ញត្តិដូចមានចែង ក្នុងច្បាប់។[39]

ផ្អែកតាមនិយមន័យដែលបានកំណត់ក្នុងច្បាប់សញ្ជាតិខ្មែរខាងលើ ការសុំកូនពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ដែលសុំកូនជនបរទេសមកធ្វើជាញាតិរបស់ខ្លួន ត្រូវទទួលបានសញ្ជាតិខ្មែរ បានន័យថាសុំកូននេះជាសុំកូនពេញលេញ ហើយមានលក្ខណៈអន្តរប្រទេស ហេតុដូចនេះនាងខ្ញុំសូមលើកនូវគោលការណ៍ទូទៅនៃសុំកូនអន្តរប្រទេស ស្របតាមច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស និងក្រមរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជាដើម្បីឲការសុំកូននេះលក្ខណៈត្រឹមត្រូវ និងអាចឲកូនជនបរទេស ដែលត្រូវសុំនោះអាចទាមទារនិងទទួលបានសញ្ជាតិខ្មែរយ៉ាងជាក់ច្បាស់បាន។

**លក្ខខ័ណ្ឌតម្រូវសំរាប់សុំកូនអន្តរប្រទេស** សុំកូនដែលស្ថិតក្នុងវិសាលភាពនៃអនុសញ្ញានេះ អាចប្រព្រឹត្តទៅ បានលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋដើម៖

ក បានកំណត់ថាកុមារមានលក្ខណៈសម្បត្តិអាចសុំយកទៅចិញ្ចឹមបាន ។

ខ បានសំរេចថា សុំកូនអន្តរប្រទេសជាឧត្តមប្រយោជន៍របស់កុមារ បន្ទាប់ពីបានពិចារណាដិតដល់នូវលទ្ធភាព នៃការទុកដាក់កុមារនោះនៅក្នុងរដ្ឋដើម ។

---

[38] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រាទី ១០

[39] យោងតាមច្បាប់ស្តីពី សុំកូនអន្តរប្រទេស ឆ្នាំ២០០៩,មាត្រាទី ៤

គ.បានធានាថា៖

(១) ជន ស្ថាប័ន និង អាជ្ញាធរដែលចាំបាច់ត្រូវយល់ព្រមលើសុំកូនត្រូវបានពិគ្រោះយោបល់ បើជាការ ចាំបាច់ ហើយត្រូវបានជូនពត៌មានឱ្យបានដឹងដោយត្រឹមត្រូវអំពីផលប៉ះពាល់នៃការយល់ព្រមរបស់គេជា ពិសេស ឱ្យដឹងថាតើសុំកូននោះនឹងនាំឱ្យមានការបញ្ចប់ទំនាក់ទំនងតាមផ្លូវច្បាប់រវាងកុមារ និង គ្រួសារ កំណើតរបស់កុមារ ឬយ៉ាងណា ។

(២) ជន ស្ថាប័ន និងអាជ្ញាធរនោះផ្តល់ការយល់ព្រមរបស់ខ្លួនដោយសេរី តាមរយៈទម្រង់ ដែលច្បាប់តម្រូវ និងបញ្ជាក់ ឬផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ។

(៣) ការយល់ព្រមទាំងនោះមិនបានធ្វើឡើងដោយសារការផ្តល់ប្រ មិនបានធ្វើឡើងដោយសារការផ្តល់ប្រាក់កាស ឬការទូទាត់គ្នាតាមបែបណាមួយ ឡើយ និងមិនត្រូវបានដកវិញឡើយ ។ ហើយនិង

(៤) ការយល់ព្រមរបស់ម្តាយត្រូវបានផ្តល់តែបន្ទាប់ពីកូនកើតរួចហើយប៉ុណ្ណោះ ក្នុងករណីដែលមានការតម្រូវ ឱ្យម្តាយយល់ព្រម ។ ហើយនិង

(ឃ) បានធានា បន្ទាប់ពីបានគិតដល់អាយុ និងកំរិតនៃមជ្ឈិមវ័យរបស់កុមារ ថា ៖-

(១) កុមារនោះត្រូវបានពិគ្រោះយោបល់ និងត្រូវបានប្រាប់ឱ្យដឹងត្រឹមត្រូវអំពីផលនៃសុំកូន និងអំពីផល នៃ ការយល់ព្រមរបស់ខ្លួនចំពោះសុំកូន ក្នុងករណីតម្រូវឱ្យមានការយល់ព្រមបែបនេះ ។

(២) មានការយកចិត្តទុកដាក់ដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារ ។

(៣) ការយល់ព្រមរបស់កុមារចំពោះសុំកូន ក្នុងករណីតម្រូវឱ្យមានការយល់ព្រមបែបនេះ ត្រូវបានផ្តល់ដោយ សេរី តាមទម្រង់ដែលច្បាប់តម្រូវ និងបញ្ជាក់ ឬផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ហើយនិង

(៤) ការយល់ព្រមនោះមិនបានធ្វើឡើងដោយសារការផ្តល់ប្រាក់កាស ឡើយ ។ ឬការទូទាត់គ្នាតាមបែបណាមួយ។ [40]

សុំកូននៅក្នុងវិសាលភាពនៃអនុសញ្ញានេះ អាចប្រព្រឹត្តទៅបានលុះត្រាណាតែអាជ្ញាធរមានសមត្ថកិច្ចនៃរដ្ឋទទួល ៖-

(ក) បានសំរេចថា អនាគតឪពុកម្តាយចិញ្ចឹមនោះ មានលក្ខណៈសម្បត្តិត្រឹមត្រូវ និងសមស្របអាចយកកូនមកចិញ្ចឹម បាន ។

(ខ) បានធានាថា អនាគតឪពុកម្តាយចិញ្ចឹមនោះ ត្រូវ បានពិគ្រោះយោបល់ បើជាការចាំបាច់ ។ ហើយនិង

[40] ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ៤

(គ) បានសំរេចថា កុមារនោះត្រូវបាន ឬ នឹងត្រូវបានអនុញ្ញាតឱ្យចូល និង រស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋនោះ ។[41]

ដោយឡែកយោងតាមក្រមរដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជាបានចែងពី ទម្រង់នៃការបង្កើតសុំកូនពេញលេញផងដែរ បើយល់ឃើញថា មានល័ក្ខខ័ណ្ឌដែលបានកំណត់នៅក្នុងបញ្ញត្តិចាប់ពីមាត្រា ១០០៨ (សុំកូនដោយសហការរវាងប្តីប្រពន្ធ) ដល់មាត្រា ១០១២ (មូលដ្ឋានវិនិច្ឆ័យនៃការបង្កើត សុំកូនពេញលេញ) ខាងក្រោមនេះ តុលាការអាចបង្កើតសុំកូនពេញលេញ ដោយបញ្ចប់ ញាតិភាពជាមួយនឹងញាតិលោហិតនៃឪពុកម្តាយបង្កើត តាមពាក្យសុំរបស់បុគ្គលដែលនឹង ក្លាយជាឪពុកម្តាយចិញ្ចឹមបាន ។[42]

សុំកូនដោយសហការរវាងប្តីប្រពន្ធ ១-បុគ្គលដែលក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម ត្រូវតែជាបុគ្គលដែលមានសហព័ន្ធ ។ ២-ប្តី ឬ ប្រពន្ធតែម្ខាង ពុំអាចក្លាយជាឪពុក ឬ ម្តាយចិញ្ចឹមបានឡើយ ប្រសិនបើ សហព័ទ្ធម្ខាងទៀត មិនក្លាយជាម្តាយ ឬ ឪពុកចិញ្ចឹម ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមក អនុវត្តឡើយ ចំពោះករណីដែលប្តីប្រពន្ធណាម្ខាងក្លាយជាឪពុក ឬ ម្តាយចិញ្ចឹម របស់ កូនបង្កើតនៃសហព័ន្ធម្ខាងទៀត ។[43]

អាយុរបស់ឪពុកម្តាយចិញ្ចឹម ឪពុកម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ)ឆ្នាំ ឡើងទៅ ហើយត្រូវមានអាយុច្រើនជាងកូនសុំយ៉ាងតិច ២០ (ម្ភៃ) ឆ្នាំ ។[44] អាយុរបស់កូនសុំជាគោលការណ៍ កូនសុំត្រូវមានអាយុតិចជាង ៨ (ប្រាំបី) ឆ្នាំ ។[45]

ការយល់ព្រមរបស់ឪពុកម្តាយ ដើម្បីបង្កើតសុំកូនពេញលេញ ត្រូវមានការយល់ព្រមពីឪពុកម្តាយបង្កើត ឬ អ្នក អាណាព្យាបាលសម្រាប់អនីតិជន របស់កុមារដែលនឹងក្លាយជាកូនសុំនោះ ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវយកមកអនុវត្តឡើយ ចំពោះករណីដែលឪពុកម្តាយនោះ មិនអាចបង្ហាញ ឆន្ទៈបាន ឬ ករណីដែលមានការធ្វើបាបដោយឪពុកម្តាយ ការបោះបង់កូនចោលដោយ គំនិតទុច្ចរិត ឬ ហេតុផ្សេងៗទៀត ដែលបំពានផលប្រយោជន៍របស់កុមារដែលនឹងក្លាយ ជាកូនសុំនោះ យ៉ាងធ្ងន់ធ្ងរ ។[46]

---

[41] ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ៥

[42] រដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១០០៧

[43] រដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១០០៨

[44] រដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១០០៩

[45] រដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១០១០

[46] រដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១០១១

មូលដ្ឋានវិនិច្ឆ័យនៃការបង្កើតសុំកូនពេញលេញ សុំកូនពេញលេញ ត្រូវបានបង្កើតឡើង នៅក្នុងករណីដែលមានការពិបាកយ៉ាង ខ្លាំង ឬ មិនសមរម្យ ក្នុងការគ្រប់គ្រងថែរក្សាកុមារដែលនឹងក្លាយជាកូនសុំ ដោយឪពុក ម្តាយបង្កើត ឬ មានស្ថានភាពពិសេសផ្សេងៗទៀត បើយល់ឃើញថា មានភាពចាំបាច់ ពិសេស ដើម្បីផលប្រយោជន៍របស់កូននោះ ។[47]

## ៣.ការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍

យោងតាមច្បាប់ស្តីពីពាហ៍ពិពាហ៍និងគ្រួសារ បានចែងថា អាពាហ៍ពិពាហ៍គឺជាកិច្ចសន្យាដ៏ឱឡារិកមួយធ្វើឡើងដោយបុរសម្នាក់ និង ស្ត្រីម្នាក់ដែលប្តេជ្ញាថា ខ្លួននឹងរួមសមគ្គសង្វាសជាមួយគ្នាតាមបញ្ញត្តិ ច្បាប់ ហើយដែលមិនអាចរំលាយទៅវិញបានតាមទំនើងចិត្តរបស់ខ្លួន អាពាហ៍ពិពាហ៍នឹងមានអានុភាពពេញលក្ខណៈច្បាប់បាន លុះត្រាតែអាពាហ៍ពិពាហ៍នោះធ្វើឡើងស្រប តាមក្បួនខ្នាតដែលមាចែងក្នុងច្បាប់។[48] បុរស និង នារីដែលមានអាយុពេញលក្ខណៈច្បាប់មានសិទ្ធិពេញលេញក្នុងការសំរេចអាពាហ៍ពិពាហ៍។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ ។ គ្មាននរណាមួយ អាចបង្ខំបុគ្គលម្នាក់អោយរៀប ឬ រារាំងមិនអោយរៀបអាពាហ៍ពិពាហ៍បានឡើយ បើអាពាហ៍ពិពាហ៍នោះរៀបតាមក្បួនខ្នាត ដែលមានចែងក្នុងច្បាប់នេះ ។[49]

អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ២០ឆ្នាំឡើង នារីចាប់ពីអាយុ១៨ឆ្នាំឡើង។ ក្នុងករណីពិសេស បុរសដែលមានរាយុមិនទាន់ដល់ ២០ឆ្នាំ និង នារីដែលមានរាយុមិនទាន់ដល់ ១៨ ឆ្នាំ រាចរៀបរាពាហ៍ពិពាហស្របច្បាប់បាន ប្រសិនបើនារីមានផ្ទៃពោះ ហើយមានការអនុញ្ញាតពីឪពុកម្តាយ ឬ អ្នកអាណាព្យាបាល។[50]

ច្បាប់សញ្ជាតិរបស់ព្រះរាជាណាចក្រកម្ពុជា បានផ្តល់សញ្ជាតិដល់ជនបរទេសដែលបានរៀបការជាមួយប្តីឬប្រពន្ធដែលជាពលរដ្ឋខ្មែរ ហើយពាហ៍ពិពាហ៍នោះត្រូវស្របតាមច្បាប់និងលិខិតបទដ្ឋានជាធរមានទើបជនបរទេស

---

[47] រដ្ឋប្បវេណីរបស់ព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៧ មាត្រា ១០១២

[48] ច្បាប់ស្តីពីពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៣

[49] ច្បាប់ស្តីពីពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៤

[50] ច្បាប់ស្តីពីពាហ៍ពិពាហ៍និងគ្រួសារ ឆ្នាំ ១៩៨៩ មាត្រា ៥

[50] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ១១

[51] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ១២

នោះអាចទាមទារនិងទទួលបានសញ្ជាតិខ្មែរបាន ហេតុនេះនាងខ្ញុំសូមលើកយកលក្ខខណ្ឌតម្រូវសម្រាប់ទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបពាហ៍ពិពាហ៍មកបង្ហាញជូនដូចខាងក្រោម៖

ចំពោះស្ត្រី ឬបុរសបរទេសដែលយកប្តី ឬប្រពន្ធពលរដ្ឋខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិ ខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និង បានស្នាក់នៅយ៉ាងហោចរយៈពេល ១២ (ដប់ពីរ)ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។ ត្រូវបានអនុញ្ញាតឱ្យសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្តាយ ឬឪពុកដែលមានកូនជាអនីតិជន។[51]

ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖ ១- មានគំនិត មារយាទ និងសីលធម៌ល្អ ២- ពុំដែលមានទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ ៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរ ដោយអាពាហ៍ពិពាហ៍ ៤- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ៥- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។[52]

យោងតាមអនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ក៏បានកំណត់យ៉ាងច្បាស់លាស់ផងដែរ អំពីបទនិង នីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេសដើម្បីអោយការរៀបពាហ៍ពិពាហ៍ នោះលក្ខណៈត្រឹមត្រូវសមស្របតាមច្បាប់កំណត់នឹងអាចឈានដល់ការទទួលបានសញ្ជាតិនាពេលខាងមុខ។

យោងតាមអនុក្រឹត្យនេះបានលើកឡើងថា ការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេសត្រូវផ្អែកលើគោលការណ៍ស្ម័គ្រចិត្ត និងឆន្ទៈ ផ្ទាល់របស់សាមីខ្លួន និងត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌដែលមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា នៃ ព្រះរាជាណាចក្រកម្ពុជា ។[53] ហើយត្រូវបានហាមឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ដែលធ្វើឡើងតាមរយៈភ្នាក់ងាររើសគូស្រករ ឈ្មួញ កណ្តាល ឬក្រុមហ៊ុនអាជីវកម្ម។[54]ត្រូវបានហាម

[53] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ២

[54] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ៣

[54] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ៤

[54] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ៥

ឃាត់ដាច់ខាតចំពោះអាពាហ៍ពិពាហ៍ក្លែងក្លាយ បោកបញ្ឆោត ក្នុងគោលបំណងកេងប្រវ័ញ្ច ពលកម្ម ជួញដូរមនុស្ស ឬធ្វើអាជីវកម្មផ្លូវភេទ ។[55]

ចំពោះបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរនិងជនបរទេសមានដូចតទៅ៖ ជនបរទេសដែលមានបំណងរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ ចាំបាច់ត្រូវមានវត្តមាននៅ ព្រះរាជាណាចក្រកម្ពុជាដើម្បីបំពេញបែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ ។[56]

ដើម្បីរៀបអាពាហ៍ពិពាហ៍បានជាមួយពលរដ្ឋខ្មែរ សាមីខ្លួនជនបរទេសត្រូវបំពេញបែបបទទៅក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ដោយភ្ជាប់នូវសំណុំឯកសារដូចខាងក្រោម : ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ឯកសារថតចម្លងនៃ លិខិតឆ្លងដែនរបស់សាមីខ្លួនជនបរទេសមានទិដ្ឋាការចូលប្រទេសកម្ពុជា ដែល នៅមានសុពលភាពលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួន ជនបរទេសលិខិតបញ្ជាក់សុខភាពចេញដោយសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា លិខិតថ្កោលទោសចេញដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេសលិខិតបញ្ជាក់អំពីមុខរបរពិតប្រាកដរបស់សាមីខ្លួនជនបរទេសដែលធានាដល់ជីវភាពរស់នៅចេញ ដោយសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស។ឯកសារថតចម្លងនៃលិខិតឆ្លងដែន និងលិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ត្រូវមាន បញ្ជាក់នីត្យានុកូលភាពពីស្ថានទូត ឬស្ថានតំណាងនៃប្រទេសរបស់សាមីខ្លួនជនបរទេស ប្រចាំព្រះរាជាណាចក្រកម្ពុជា។[57]

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជាមានភារកិច្ចពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសាររបស់ជនបរទេសដែលសុំរៀបអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុងរយៈពេលយ៉ាងយូរ០៥ថ្ងៃការងារ។ ក្រោយពីបានពិនិត្យ និងផ្តល់យោបល់លើ សំណុំឯកសាររបស់ជនបរទេសហើយ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបញ្ជូនសំណុំ ឯកសារទាំងនោះទៅក្រសួងមហាផ្ទៃ និងជូនពត៌មានទៅស្ថាប័នពាក់ព័ន្ធ ។[58]

[57] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ៦

[58] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ៧

[58] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ៨

បន្ទាប់ពីទទួលសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍របស់ជនបរទេសពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃមានភារកិច្ច ចុះបញ្ជីសំណុំឯកសាររបស់ជនបរទេសនោះ និងត្រូវជូនដំណឹងទៅសាមីខ្លួនជនបរទេសវិញ ក្នុង រយៈពេលយ៉ាងយូរ ០៥ថ្ងៃការងារ ។ជូនដំណឹងអំពីការសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ របស់សាមីខ្លួនពលរដ្ឋខ្មែរ ។ ពិនិត្យនីត្យានុកូលភាពលើសំណុំឯកសារដែលចេញដោយមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋាន អចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។[59]

សាមីខ្លួនជនបរទេស បន្ទាប់ពីបានទទួលការពិនិត្យ និងផ្តល់យោបល់លើសំណុំឯកសារ និងបានចុះបញ្ជីសំណុំឯកសារសុំរៀបអាពាហ៍ពិពាហ៍រួចហើយ ត្រូវដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋាន ឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។ ចំពោះសាមីខ្លួនពលរដ្ឋខ្មែរ ដែលត្រូវរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសនោះ ក៏ត្រូវដាក់ពាក្យសុំរៀប អាពាហ៍ពិពាហ៍ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍ដែលខ្លួនរស់នៅដោយមានភ្ជាប់ នូវសំណុំឯកសារដូចខាងក្រោមៈ
ពាក្យសុំរៀបអាពាហ៍ពិពាហ៍ សេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើតរបស់សាមីខ្លួនពលរដ្ឋខ្មែរ លិខិតបញ្ជាក់ភាពនៅលីវ ឬពោះម៉ាយ ឬមេម៉ាយ ចេញដោយមេឃុំ ឬចៅសង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ លិខិតបញ្ជាក់សុខភាពចេញដោយមន្ទីរពេទ្យ ដែលទទួលស្គាល់ជាផ្លូវការពីក្រសួងសុខាភិបាលនៃ ព្រះរាជាណាចក្រកម្ពុជា។ ពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារសាមីខ្លួនជាពលរដ្ឋខ្មែរ និងជនបរទេសត្រូវដាក់ ស្របពេលជាមួយគ្នា ទៅមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ដោយអនុវត្តតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។[60]

មន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់មានភារកិច្ច ពិនិត្យ និងសំរេចលើពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍របស់សាមីខ្លួនបុរស និងនារី ក្នុងរយៈពេលយ៉ាងយូរ ០៣ថ្ងៃការងារ បន្ទាប់ពីបានទទួលពាក្យសុំរៀបអាពាហ៍ពិពាហ៍ និងសំណុំឯកសារភ្ជាប់ ។បន្ទាប់ពីពិនិត្យពាក្យសុំ និងសំណុំឯកសារភ្ជាប់របស់សាមីខ្លួនបុរស និងនារី បានត្រឹមត្រូវតាមគោលការណ៍ ច្បាប់រួចហើយ មន្ត្រីអត្រានុកូលដ្ឋានត្រូវរៀបចំប័ណ្ណប្រកាសអាពាហ៍ពិពាហ៍ ដោយមានវត្តមានផ្ទាល់របស់សាមីខ្លួន បុរស និងនារី ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានឃុំ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់សាមីខ្លួនពលរដ្ឋខ្មែរ ។ ប័ណ្ណប្រកាសអាពាហ៍ពិពាហ៍នេះត្រូវបិទផ្សាយរយៈពេល១០ថ្ងៃ នៅស្ថានទូត ឬស្ថានតំណាង នៃ

---

[60] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ៩

[61] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ១០

ប្រទេសសាមីខ្លួនជនបរទេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅលំនៅដ្ឋានអចិន្ត្រៃយ៍ និងនៅសាលាឃុំ សង្កាត់ នៃសាមីខ្លួនពលរដ្ឋខ្មែរ ស្របតាមការកំណត់ក្នុងបែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន។ ផុត រយៈពេល១០ ថ្ងៃ ប្រសិនគ្មានការប្តឹងតវ៉ាឬប្តឹងជំទាស់នឹងអាពាហ៍ពិពាហ៍នោះ ទើបសាមីខ្លួនបុរស និងនារី អាចរៀបអាពាហ៍ពិពាហ៍បាន ។[61]

អាពាហ៍ពិពាហ៍នឹងមានអនុភាពពេញលក្ខណៈច្បាប់បានលុះត្រាតែសាមីខ្លួនបុរស និងនារី ចុះកិច្ចសន្យាអាពាហ៍ពិពាហ៍តាមរយៈការចុះបញ្ជីអាពាហ៍ពិពាហ៍ដោយសាមីខ្លួនផ្ទាល់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៃឃុំ សង្កាត់ ដែលសាមីខ្លួនទាំងពីរបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ ដោយនាំមកជាមួយនូវសាក្សីគ្រប់អាយុការចំនួន ០២រូបផង ស្របទៅតាមទម្រង់បែបបទ និងនីតិវិធីនៃការងារអត្រានុកូលដ្ឋាន ។[62]

## ៤.ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម

ក្រៅពីការរៀបរាប់ខាងលើការផ្តល់សញ្ជាតិខ្មែរ ឲទៅជនបរទេសអាចផ្តោតទៅលើលក្ខខណ្ឌពិសេសមួយចំនួនដូចតទៅ៖ **សញ្ជាតូបនីយកម្ម** សំដៅដល់ការផ្តល់សញ្ជាតិខ្មែរតាមរយៈការស្នើសុំរបស់ជនបរទេស ដោយផ្អែកតាមលក្ខខណ្ឌនៃការស្នាក់នៅ ការវិនិយោគ អំណោយជាសាច់ប្រាក់ និងគុណសម្បត្តិពិសេស ឬថ្វីដៃ ពិសេស ។[63]

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។ សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ ព្រះរាជាណាចក្រកម្ពុជា តែប៉ុណ្ណោះ ។ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលតាមអំណាចឆន្ទានុសិទ្ធិ ។[64]

ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

---

[62] អនុក្រឹត្យ ស្តីពី ការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស មាត្រា ១១

[63] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ៤

[64] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ១៨

[65] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ១៩

ក- មានគំនិត មារយាទ និងសីលធម៌ល្អ ។

ខ- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

គ- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន ៧ (ប្រាំពីរ)ឆ្នាំ ដោយ បានទទួលប័ណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្ដីពីអន្តោប្រវេសន៍ ចំពោះជនបរទេសអន្តោប្រវេសន្ត ។

ឃ- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅដែលចេញឱ្យក្នុងក្របខ័ណ្ឌ នៃច្បាប់ស្ដីពីអន្តោប្រវេសន៍ ចំពោះជនបរទេសដែលបានកំណត់នៅក្នុងមាត្រា២១ និងមាត្រា២២នៃច្បាប់សញ្ជាតិខ្មែរ។

ង- ចេះនិយាយភាសាខ្មែរចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាង ថាខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់និងប្រពៃណីល្អ របស់ខ្មែរ

ច- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។[65]

ចំពោះជនបរទេសអន្តោប្រវេសន្តណាដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ ចំនួន ឆ (ប្រាំពីរ)ឆ្នាំ មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដោយ បានទទួលប័ណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្ដីពីអន្តោប្រវេសន៍ ចំពោះជនបរទេសអន្តោប្រវេសន្ត ត្រូវបន្ថយមកនៅ ៣(បី) ឆ្នាំវិញ ។[66]

### ៤.១ ជនបរទេសណាដែលបានទទួលការអនុញ្ញាតឱ្យវិនិយោគត្រឹមត្រូវតាមច្បាប់

ជនបរទេសណាដែលបានទទួលការអនុញ្ញាតឱ្យវិនិយោគត្រឹមត្រូវតាមច្បាប់ ពីស្ថាប័នមានសមត្ថកិច្ច ហើយបានចំណាយទុនអនុវត្តគម្រោងវិនិយោគជាក់ស្ដែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះ អាចដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីជនបរទេសនោះបានបំពេញលក្ខខណ្ឌតម្រូវ នៃច្បាប់សញ្ជាតិខ្មែរ ដូចជា៖

មានគំនិត មារយាទ និងសីលធម៌ល្អ

ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

[65] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ១៩

[66] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ២០

[67] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ២១

មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅដែលចេញឱ្យក្នុងក្របខ័ណ្ឌ នៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះជនបរទេសដែលបានកំណត់នៅក្នុងមាត្រា២១ និងមាត្រា២២ នៃច្បាប់នេះ ។

ចេះនិយាយភាសាខ្មែរចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្រ្តខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាង ថាខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់និងប្រពៃណីល្អ របស់ខ្មែរ

មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ និងបានស្នាក់នៅស្របច្បាប់យ៉ាង ហោចរយៈពេល ១២ (ដប់ពីរ) ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។[67]

**៤.២ ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ**

ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ សម្រាប់ជាផលប្រយោជន៍ ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឬវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យ សុំចូលសញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ និងទី៦ មាត្រា១៩ នៃច្បាប់សញ្ជាតិខ្មែរ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ៦ (ប្រាំមួយ) ខែពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។[68]

**៤.៣ ជនបរទេសដែលបានបង្ហាញនូវភស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយ**

ជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចដាក់បានស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្មបាន ក្នុងករណីដែលជននោះបានបំពេញចំណុចទី១ ទី២ និងទី៦ មាត្រា១៩ នៃច្បាប់សញ្ជាតិខ្មែរ។[69]

ដោយសារការទទួលសញ្ជាតិខ្មែរតាមរយៈសញ្ញាតូបនីយកម្ម មានជាប់ពាក់ព័ន្ធនិង ពាក្យជនបរទេសនិងអន្តោប្រវេសន៍ អត្ថន័យរបស់ ជនបរទេសមិនមែនអន្តោប្រវេសន៍ ជនបរទេសអន្តោប្រវេសន៍ ជនបរទេសអន្តោប្រវេសន៍ ជាអ្នកវិនិយោគឯកជន ស្របតាមច្បាប់អន្តោប្រវេសន៍ នឹងត្រូវលើកយកមកបង្ហាញជូនដូចតទៅៈ

[68] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ២២

[69] យោងតាមច្បាប់សញ្ជាតិខ្មែរ ឆ្នាំ២០១៨,មាត្រា ២៣

[70] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ២

[71] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ៤

យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤ ត្រូវចាត់ទុកជាជនបរទេស ជនណាដែលគ្មានសញ្ជាតិជាខ្មែរ ដោយគ្មានរើសអើង ទោះបីជននោះមានសញ្ជាតិ ជំនឿ សាសនា ឬមានដើមកំណើតណាមួយក៏ដោយ ។[70]

អនុលោមតាមល័ក្ខខ័ណ្ឌនៃប្រវេសន៍ និងការស្នាក់អាស្រ័យនៅប្រទេសកម្ពុជា ជនបរ ទេស ត្រូវចែកជាបីប្រភេទគឺ ៖១. ជនបរទេសមិនមែនអន្តោប្រវេសន្ត ២. ជនបរទេសអន្តោប្រវេសន្ត ៣. ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ។[71]

**៤.៤ ជនបរទេសមិនមែនអន្តោប្រវេសន្តគឺ ៖**

ក- ភ្នាក់ងារដែលបំរើការនៅស្ថានទូតបរទេស ឬស្ថានកុងស៊ុលបរទេស ឬ ស្ថានតំណាងបេសកកម្មបរទេស អ្នកជំនាញការអន្តរជាតិនិងជនផ្សេងៗទៀតដែលចូលមកកុំព្រះរាជាណាចក្រកម្ពុជា តាមការស្នើសុំ ឬតាមកិច្ចព្រមព្រៀងជាមួយរាជរដ្ឋាភិបាលកម្ពុជា ដោយរាប់ទាំងក្រុមគ្រួសារ, និងបុគ្គលិករបស់គេ ក្នុងរយៈពេលដែលគេស្នាក់អាស្រ័យនៅ ។

ខ. ទាហាន មន្ត្រី អ្នករដ្ឋការ និយោជិត និងភ្នាក់ងារបរទេស និស្សិត ព្រមទាំងគ្រួសារដែលចូលមកព្រះរាជាណាចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។ គ. អ្នកធ្វើដំណើរឆ្លងកាត់ ជាអ្នករង់ចាំមធ្យោបាយធ្វើដំណើរមុនពេលចេញ ដំណើរឆ្ពោះទៅកាន់ទីនៅចុងក្រោយរបស់ខ្លួន ។ ក្នុងករណីនេះ ការស្នាក់អាស្រ័យនៅមិនត្រូវលើសពីមួយសប្តាហ៍ លើកលែងតែក្នុងករណីប្រធានសក្តិ ។

ឃ. អ្នកទេសចរដែលមានសំបុត្រត្រឡប់ទៅវិញ ហើយរយៈពេលស្នាក់អាស្រ័យ ដែលកំណត់ដោយអនុក្រឹត្យ ។

ង. អ្នកតំណាងពាណិជ្ជកម្ម ធនាគារ អ្នកប្រកបមុខរបរផ្សេងៗទៀត ដែល ចូលមកព្រះរាជាណាចក្រកម្ពុជា ក្នុងគោលបំណងបង្កើតទំនាក់ទំនងអំពីកិច្ចការខាងលើ ។ក្នុងករណីនេះ ការស្នាក់ អាស្រ័យមិនអាចលើសពី ៣ ខែ។ ក្នុងករណីមានហេតុផលចាំបាច់ ការស្នាក់អាស្រ័យនៅនេះ អាចបន្តទៀតបាន, រយៈពេល ៣ ខែ ជាអតិបរមា តាមការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។

ច. ជនបរទេសរស់នៅតាមព្រំប្រទល់ជាប់នឹងខេត្តនានានៃព្រះរាជាណាចក្រ កម្ពុជា ៉ដែលបានទទួលការអនុញ្ញាតឱ្យឆ្លងកាត់ព្រំប្រទល់ច្រើនដង ឬមួយដងមួយកាល ។

ឆ. អ្នកធ្វើដំណើរ កងនាវិក និងយានិក ដែលមកសំចតយកស្បៀងនៅតាមកំពង់ផែសមុទ្រ និងតាមព្រលានយន្តហោះ ។

ជ. ជនបរទេសដែលមកធ្វើការនេសាទនៅតាមឆ្នេរសមុទ្រនៃព្រះរាជាណា ចក្រកម្ពុជា ដោយមានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា ។[72]

**៤.៥ ជនបរទេសអន្តោប្រវេសន៍**

ជនបរទេសដែលចាត់ទុកជាអន្តោប្រវេសន៍:

ក. ជនបរទេសដែលមកដល់ព្រះរាជាណាចក្រកម្ពុជាដោយស្របច្បាប់ ដើម្បីស្នាក់នៅ រយៈពេលយូរ ឬដើម្បីប្រកបវិជ្ជាជីវៈ ឬធ្វើសកម្មភាពផ្សេងៗដែលទាក់ទងនឹងឧស្សាហកម្ម ពាណិជ្ជកម្ម សេវា ឬកសិកម្ម ។

ខ. ជនបរទេសដែលគ្មានរាប់ចូលក្នុងប្រភេទណាមួយ ដូចមានចែងក្នុងមាត្រា ៧ នៃច្បាប់អន្តោប្រវេសន៍។

**៤.៦ ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន**

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន គឺជនបរទេសដែលចូលមកក្នុងព្រះរា ជាណាចក្រកម្ពុជា ដើម្បីធ្វើវិនិយោគក្នុងក្របខ័ណ្ឌនៃច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ។[73]

ជនបរទេសអន្តោប្រវេសន្តជាអ្នកវិនិយោគឯកជន ចែកចេញជាពីរប្រភេទគឺ ៖

ក. ជនបរទេសដែលចូលមកកម្ពុជាដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ

ខ. ជនបរទេសដែលបានទទួល « លិខិតអនុញ្ញាតឱ្យវិនិយោគ» ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជារួចហើយ ។[74]

ជនបរទេសដែលចូលមកព្រះរាជាណាចក្រកម្ពុជាដើម្បីពិនិត្យលទ្ធភាពធ្វើវិនិយោគ ត្រូវ បំពេញល័ក្ខខ័ណ្ឌទាំងឡាយដែលមានចែងក្នុងជំពូកទី ៣ ស្តីពីជនបរទេសអន្តោប្រវេសន្ត លើកលែងតែសុពលភាព សំរាប់រយៈពេលស្នាក់នៅបណ្តោះអាសន្ន គឺសំរាប់រយៈពេលមួយឆ្នាំ ។ ក្រោយរយៈពេលមួយឆ្នាំនៃការស្នាក់នៅ ក្នុង ករណីដែលមិនអាចមានលទ្ធភាពធ្វើវិនិយោគបានលើវិស័យណាមួយទេ ជនបរទេសនោះអាចដកប្រាក់តម្កល់នានាវិញ បាន ហើយមិនអាចបន្តឱ្យស្នាក់នៅបានទៀតឡើយ ។[75]

---

[72] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ៧

[73] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ២៥

[74] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ២៥

[75] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ២៦

ជនបរទេសដែលបានទទួល " លិខិតអនុញ្ញាតឱ្យវិនិយោគ " ពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រួមទាំងគ្រួសារផ្ទាល់ខ្លួន នឹងបានទទួលការអនុញ្ញាតឱ្យស្នាក់នៅក្នុងព្រះរាជាណាចក្រកម្ពុជាជាអចិន្ត្រៃយ៍ ឬតាមរយៈ ពេលដែលបានកំណត់ក្នុងលិខិតអនុញ្ញាតឱ្យវិនិយោគ និងមានសិទ្ធិសុំកាន់ឯកសារធ្វើដំណើររបស់ព្រះរាជាណាចក្រកម្ពុជា ។[76]

## ផ្នែកទី២ នីតិវិធីនៃការស្នើសុំសញ្ជាតិ ស្របតាមលិខិតបទដ្ឋានគតិយុត្តិជាធរមាន និងបណ្តឹងតវ៉ា

### ១. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរពីកំណើត

**យោងអនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ និង ច្បាប់ ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ ២០២៣** បានកំណត់និងពន្យល់អំពីការចុះបញ្ជីកំណើតរបស់ប្រជាពលរដ្ឋខ្មែរដើម្បីទទួលបានសំបុត្រកំណើត ដើម្បីបញ្ជាក់នូវភាពជាពលរដ្ឋខ្មែរ និងទទួលបានសញ្ជាតិខ្មែរដោយស្វ័យប្រវត្តិហេតុនេះនាងខ្ញុំសូមលើកមកបង្ហាញអំពីនីតិវិធីក្នុងការចុះបញ្ជីកំណើត ដល់ការទទួលសំបុត្រកំណើតដូចតទៅ៖

**អត្រានុកូលដ្ឋាន** គឺជាចំណងរួមភ្ជាប់សញ្ជាតិទៅនឹងរដ្ឋ និង ស្ថានភាពជាក់ស្តែង ដែលជននោះ មាននៅក្នុងត្រកូលគ្រួសារខ្លួន ក្នុងសង្គមជាតិ និង ដែលបង្កើតអោយជននោះមានសិទ្ធិ និង ករណីយកិច្ច ។សំបុត្រអត្រានុកូលដ្ឋាន គឺជាសំបុត្រសម្រាប់កត់ត្រាភាពជាស៊ីវិលនៃពលរដ្ឋខ្មែរ និង ជនបរទេស ដែលរស់នៅស្របច្បាប់ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។ សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍នឹងសំបុត្រមរណភាព។[77]ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋានជកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ គ្រប់ រូប ។[78]

---

[76] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ២៧
[77] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២
[78] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ៣
[79] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ១៧
[80] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ១៨
[81] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ១៩
[82] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៣
[83] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៣
[84] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៦
[85] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៧

ក្នុងដែនសមត្ថកិច្ចកំណត់ នៃច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។ សំបុត្រអត្រានុកូលដ្ឋានរួមមាន សំបុត្រកំណើត សំបុត្រអាពាហ៍ពិពាហ៍នឹងសំបុត្រមរណភាព។[79]ការសុំចុះអត្រានុកូលដ្ឋានក្នុងសៀវភៅអត្រានុកូលដ្ឋានជកាតព្វកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ គ្រប់ រូប ។[80]

**អំពីសំបុត្រកំណើត** បើមានទារកកើត ឪពុក ឬ ម្តាយ មានកាតព្វកិច្ចត្រូវទៅរាយការណ៍ ចុះសៀវភៅកំណើតនៅ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន នៅសាលាឃុំ ឬ សង្កាត់ នៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់ឪពុក : ម្តាយទារកនោះមិនអោយហួស៣០ថ្ងៃ ដោយបញ្ជាក់អោយបានច្បាស់ថា ឪពុកនិងម្តាយនៃ ទារកនោះមានខាន់ស្លា ឬ ឥតខាន់ស្លា ។ បើមានខាន់ស្លាត្រូវបង្ហាញសំបុត្រអាពាហ៍ពិពាហ៍ របស់ឪពុក និង ម្តាយទារកនោះ ។ បើឪពុក ម្តាយមានធុរៈទៅមិនបាន ត្រូវពឹងពាក់អ្នកជាសាច់ញាតិសន្តាន ឬ អ្នកនៅជិតខាងដែល បានឃើញ និងដឹងឮផ្ទាល់ពីទារកនោះកើតអោយទៅចុះសៀវភៅកំណើតអោយបានទាន់ពេល កំណត់ ដោយយកសំបុត្រអាពាហ៍ពិពាហ៍ ឪពុក និងម្តាយទារកនោះជាប់ទៅជាមួយផង ។[81] នាមត្រកូលរបស់ទារក - អាចយកត្រកូល ដែលក្រុមគ្រួសារកំណត់យកតាំងពីដូនតាយូរលង់មក ហើយ ឬ អាចយកឈ្មោះជីតាខាងឪពុក ឬ អាចយកឈ្មោះឪពុករបស់ទារកនោះក៏បាន ។ ឪពុក ម្តាយ ឬ អាណាព្យាបាល ជាអ្នកដាក់នាមខ្លួនអោយទារក ។[82]

**បើបានជនណារើសបានទារកដែលគេបោះបង់ចោល** ត្រូវយកទៅប្រគល់អោយអន្ត្រីអត្រានុកូល ដ្ឋានក្នុងឃុំ ឬ សង្កាត់នៃទីកន្លែងដែលរើសទារកនោះ ។ មន្ត្រីអត្រានុកូលដ្ឋាន ត្រូវធ្វើកំណត់ ហេតុ និង ចុះក្នុងសៀវភៅកំណើត ដោយរកឈ្មោះដាក់អោយ ហើយបើក្នុងករណីចាំបាច់ មន្ត្រី ពានុកូលដ្ឋានត្រូវពិគ្រោះយោបល់ជាមួយមន្ត្រី

---

[79] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ១៧
[80] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ១៨
[81] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ១៩
[82] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៣
[83] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៣
[84] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៦
[85] អនុក្រឹត្យលេខ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០ មាត្រា ២៧

សុខាភិបាល ដើម្បីដាក់ថ្ងៃ ខែ ឆ្នាំ កំណើតទារក ដែលរើសបាននោះ ដោយស្មាន និង ឈ្មោះឪពុកម្តាយដាក់ថាមិនស្គាល់ ។ បើមានជនណា សុំទារកដែលរើសបាននោះធ្វើជាកូនចិញ្ចឹម ត្រូវយកនាមត្រកូលនៃអ្នកសុំ ។[83]

**ទារកកើត ឪពុកម្តាយគ្មានចំណងអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់** ក៏ត្រូវចុះក្នុងសៀវភៅកំណើត ដែរ ។ នៅពេលធ្វើសំបុត្រកំណើត បើឪពុកម្តាយដែលគ្មានចំណងអាពាហ៍ពិពាហ៍នោះបាន ឆ្លើយទទួលស្គាល់ដោយដាក់លាក់ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានថា ទារកដែលកើតមកនោះជា កូនរបស់ខ្លួន មន្ត្រីអត្រានុកូលដ្ឋានត្រូវចាត់ទុកឪពុកម្តាយនោះថាជាឪពុក ម្តាយរបស់កូននោះ ។ ករណីមានតែឪពុក ឬ មានតែម្តាយឆ្លើយទទួលស្គាល់តែម្នាក់ឯង ទារកនោះត្រូវចាត់ទុកជាកូន របស់អ្នកដែលបានទទួលស្គាល់តែម្នាក់ឯងប៉ុណ្ណោះ ។ ក្រោយពេលឪពុក ឬ ម្តាយបានប្តឹងចុះក្នុងសៀវភៅកំណើត ឪពុកម្ម ម្តាយណា ដែលមិនទាន់ ទទួលស្គាល់ទារកនោះ ឪពុក ឬ ម្តាយនោះ អាចប្តឹងសុំទទួលស្គាល់កូនជាក្រោយបាន ។ កូនឥតខាន់ស្លាដែលឪពុក ម្តាយបានទទួលស្គាល់ នឹង ទៅជាកូនមានខាន់ស្លាបាន ប្រសិនបើ ក្រោយពីកំណើតកូននោះ ឪពុក ម្តាយរបស់កូននោះ បានចុះអាពាហ៍ពិពាហ៍ជាមួយគ្នាការទទួលស្គាល់កូនអាចធ្វើនៅមុនពេលចុះអាពាហ៍ពិពាហ៍ ធ្វើដំណាលគ្នា នឹង ពេលចុះអាពាហ៍ ពិពាហ៍ ឬ ក្រោយពេលចុះអាពាហ៍ពិពាហ៍ក៏បាន ។[84]

**ទារកកើតពីម្តាយ ឪពុកជាពលរដ្ឋខ្មែរ រស់នៅស្របច្បាប់ឯបរទេស** ឬ ពីឪពុកជាពលរដ្ឋខ្មែរ ម្តាយជាជនបរទេស ពីឪពុកជាជនបរទេស ម្តាយជាពលរដ្ឋខ្មែរ ឪពុក ម្តាយ នៃទារកនោះ អាចសុំចុះ សៀវភៅកំណើតនៅឯប្រទេសនោះ តាមបញ្ញត្តិច្បាប់របស់ប្រទេសនោះ ។ ពេលវិល ត្រឡប់មកព្រះរាជាណាចក្រកម្ពុជាវិញ ត្រូវទៅចុះសៀវភៅកំណើតនៅឃុំ ឬ សង្កាត់ដែលខ្លួន រស់នៅតាមសំបុត្រកំណើតដែលប្រទេសនោះចេញអោយ ដោយយកសញ្ជាតិតាមច្បាប់សញ្ជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។ មន្ត្រីអត្រានុកូលដ្ឋានត្រូវយកសំបុត្រកំណើតថតចម្លងផ្លូវការនោះ ទុក ហើយចម្លង់ចេញពីសៀវភៅ នូវសំបុត្រកំណើតថ្មីអោយយកទៅប្រើប្រាស់ ។ បើឪពុក ម្តាយនៃទារកនោះបានទៅរាយការណ៍ចុះសៀវភៅកំណើតនៅស្ថានទូត ស្ថានអគ្គ កុងស៊ុល ឬ ស្ថានកុងស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំនៅប្រទេសនោះ ពេលវិលត្រឡប់មក ព្រះរាជាណាចក្រកម្ពុជាវិញ អាចយកសំបុត្រកំណើតដែលប្រគល់អោយនោះមកពីប្រើប្រាស់ ជាផ្លូវការបាន ។[85]

---

[85] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា

**ជនអន្តោប្រវេសន៍ និង ជនបរទេស ដែលបានរស់នៅស្របច្បាប់នៅលើទឹកដីនៃព្រះរាជាណា ចក្រកម្ពុជា** បានកើតទារកនៅលើទឹកដីព្រះរាជាណាចក្រកម្ពុជា ឪពុក ម្តាយទារកនោះ អាចទៅចុះសៀវភៅកំណើតនៅសាលាឃុំ ឬ សង្កាត់ ដែលខ្លួនរស់នៅជាប់លាប់ ឬ អាចហៅចុះសៀវភៅ កំណើតនៅស្ថានទូត ស្ថានអគ្គកុងស៊ុល ឬ ស្ថានកុងស៊ុលនៃប្រទេសរបស់ខ្លួនប្រចាំនៅព្រះរាជា ណាចក្រកម្ពុជា ។ បើចុះសៀវភៅកំណើតនៅសាលាឃុំ សាលាសង្កាត់ នាមត្រកូល និង នាមផ្ទាល់ខ្លួន និងនាមនៃឪពុក ម្តាយរបស់ទារកនោះ ត្រូវសរសេរជាអក្សរឡាតាំងអមជាមួយអក្សរចំពោះសញ្ជាតិនៃកូននោះ ត្រូវអនុវត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។[86]

**នីតិវិធីចុះបញ្ជីកំណើតរស់ ផ្អែកតាម ច្បាប់ស្តីពី អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ឆ្នាំ ២០២៣ ទទួលបានសំបុត្រកំណើត**

**ការចុះបញ្ជីកំណើតរស់**

រាល់កំណើតរស់ដែលកើតឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវរាយការណ៍និងចុះបញ្ជីដោយយោងតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ។[87]

**ទីកន្លែងចុះបញ្ជីកំណើតរស់** អ្នករាយការណ៍ ត្រូវដាក់ពាក្យដើម្បីចុះបញ្ជីកំណើតរស់ នៅការិយាល័យអត្រានុកូលដ្ឋានណាមួយនេះ

ក- ឃុំ សង្កាត់ ដែលកំណើតរស់បានកើតឡើង។

ខ- ឃុំ សង្កាត់ ដែលអ្នកាយការណ៍ស្នាក់នៅ។

គ- កន្លែងផ្សេងទៀត តាមការកំណត់ដោយលិខិតបទដ្ឋានគតិយុត្តរបស់ក្រសួងមហាផ្ទៃ។[88]

**រយៈពេលសម្រាប់ចុះបញ្ជីកំណើតរស់**

ក- អ្នករាយការណ៍ត្រូវដាក់ពាក្យដើម្បីចុះបញ្ជីកំណើតរស់ក្នុងរយៈពេល៣០ (សាមសិប)ថ្ងៃគិតចាប់ ពីកាលបរិច្ឆេទដែលទារកកើត។

---

[88] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ១៨

ខ- ក្រសួងមហាផ្ទៃអាចពន្យាររយៈពេលកំណត់នៃការដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ សម្រាប់ភូមិសាស្ត្រជាក់លាក់ ឬក្រុមជនជាតិដើមភាគតិច ឬដោយសារមូលហេតុផ្សេងទៀត ក្នុង ករណីដែលចាំបាច់ ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[89]

**អ្នករាយការណ៍អំពីកំណើតរស់**

ក- បុគ្គលទទួលខុសត្រូវជាអ្នករាយការណ៍អំពីកំណើតរស់ ត្រូវបានកំណត់តាមអាទិភាពដូចខាងក្រោមៈ

១- ម្ដាយរបស់ទារក

២- ឪពុករបស់ទារក

៣- អ្នកអាណាព្យាបាលទូទៅរបស់ឪពុកម្ដាយទារក

៤- ញាតិជានីតិជនដែលមើលថែទារក

៥- រដ្ឋមន្ត្រីក្រសួងឬប្រធានស្ថាប័ន ឬអ្នកតំណាងឬបុគ្គលផ្សេងទៀត ដែលកំណត់ដោយច្បាប់

ខ- ក្នុងករណីដែលមានការចាំបាច់ អ្នករាយការណ៍ក្រៅពីបុគ្គលដែលបានកំណត់ខាងលើ ត្រូវកំណត់ដោយអនុក្រឹត្យ។[90]

**ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋាន សុខាភិបាល**

១ ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាលដែលកំណើតរស់ បានកើតឡើង ត្រូវផ្ដល់ឯកសារបញ្ជាក់អំពីកំណើតរស់ទៅឱ្យអ្នករាយការណ៍ទៅតាមអាទិភាពដែល បានកំណត់នៅក្នុងមាត្រា២០ (អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់។

២- ប្រសិនបើទារកកើតនៅក្រៅមូលដ្ឋានសុខាភិបាល ហើយម្ដាយនិងទារកធ្វើដំណើរទៅ មូលដ្ឋានសុខាភិបាលក្នុងរយៈពេល៤៨ (សែសិបប្រាំបី)ម៉ោង ប្រធានឬបុគ្គលដែលត្រូវបានប្រគល់ ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្ដល់ឯកសារបញ្ជាក់អំពីកំណើតរស់ឱ្យទៅអ្នករាយការណ៍ទៅ តាមអាទិភាពដែលបានកំណត់នៅក្នុងមាត្រា២០ (អ្នករាយការណ៍អំពីកំណើតរស់) នៃច្បាប់។

[89] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ១៩

[90] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ២០

[89] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ២១

៣- ក្នុងករណីដែលបានកំណត់នៅក្នុងកថាខណ្ឌទី១និងកថាខណ្ឌទី២ខាងលើនេះ ប្រធាន ឬបុគ្គលដែលត្រូវបានប្រគល់ភារកិច្ចនៃមូលដ្ឋានសុខាភិបាល ត្រូវផ្ញើច្បាប់ចម្លងនៃឯកសារបញ្ជាក់ អំពីកំណើតរស់នោះមួយច្បាប់ទៅមន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ច។

៤- ទម្រង់ បែបបទ និងនីតិវិធីសម្រាប់ការផ្តល់ឯកសារបញ្ជាក់អំពីកំណើតរស់ដល់មន្ត្រី អត្រានុកូលដ្ឋានមានសមត្ថកិច្ច ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសុខាភិបាល។[91]

**ពាក្យសុំចុះបញ្ជីកំណើតរស់**

១- អ្នករាយការណ៍ អាចដាក់ពាក្យសុំចុះបញ្ជីកំណើតរស់ជាលាយលក្ខណ៍អក្សរ ដោយ ផ្ទាល់មាត់ឬតាមទម្រង់អេឡិចត្រូនិក។

២- ក្នុងពាក្យសុំចុះបញ្ជីកំណើតរស់ អ្នករាយការណ៍ត្រូវបំពេញពាក្យសុំនូវចំណុចខាងក្រោម៖

ក- ឈ្មោះរបស់ទារក។

ខ- ភេទរបស់ទារក។

គ- ថ្ងៃ ខែ ឆ្នាំកំណើត ម៉ោងនិងទីកន្លែងទារកកើតរស់។

ឃ- ឈ្មោះ ថ្ងៃ ខែ ឆ្នាំកំណើត លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល សញ្ជាតិនិងលំនៅឋានរបស់ឪពុកម្តាយរបស់ទារក។

ង- ឈ្មោះថ្ងៃ ខែ ឆ្នាំកំណើតលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល និងអាសយដ្ឋាន បច្ចុប្បន្នរបស់អ្នករាយការណ៍ ក្នុងករណីដែលអ្នករាយការណ៍មិនមែនជាម្តាយឬឪពុក។

ច- ថ្ងៃ ខែ ឆ្នាំ ដែលពាក្យសុំត្រូវបានធ្វើឡើង។[92]

**ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់**

១- អ្នករាយការណ៍ ត្រូវភ្ជាប់ឯកសារបញ្ជាក់អំពីកំណើតរស់ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ឬកថាខណ្ឌទី២ នៃមាត្រា២១(ការជូនដំណឹងអំពីកំណើតរស់ដែលកើតនៅក្នុងមូលដ្ឋានសុខាភិបាល) នៃច្បាប់នេះ ជាមួយនឹងពាក្យ

[92] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ២៣

សុំចុះបញ្ជីកំណើតរស់។ ប្រសិនបើអ្នករាយការណ៍មិនមានឯកសារបញ្ជាក់អំពីកំណើតរស់នោះទេ អ្នករាយការណ៍ត្រូវភ្ជាប់ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារក។

២- អ្នករាយការណ៍ក៏ត្រូវភ្ជាប់ផងដែរនូវឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ ឪពុកម្តាយរបស់ទារកជាមួយនឹងពាក្យសុំចុះបញ្ជីកំណើតរស់។

៣- ឯកសារផ្សេងទៀតដែលអាចបញ្ជាក់អំពីកំណើតរស់របស់ទារកដែលបានកំណត់នៅក្នុង វាក្យខណ្ឌទី២នៃកថាខណ្ឌទី១និងឯកសារដែលអាចបញ្ជាក់អត្តសញ្ញាណរបស់ឪពុកម្តាយរបស់ទារក ដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្រ្តីក្រសួង មហាផ្ទៃ។[93]

## នីតិវិធីចុះបញ្ជីកំណើតរស់

១- នៅពេលទទួលបានពាក្យសុំចុះបញ្ជីកំណើតរស់និងឯកសារភ្ជាប់ដែលបានកំណត់នៅក្នុង មាត្រា២៣ (ពាក្យសុំចុះបញ្ជីកំណើតរស់) និងមាត្រា២៤(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំចុះបញ្ជី កំណើតរស់) នៃច្បាប់នេះ មន្រ្តីអត្រានុកូលដ្ឋានត្រូវធ្វើការពិនិត្យ ផ្ទៀងផ្ទាត់ និងកត់ត្រាព័ត៌មាននោះ ទៅក្នុងបញ្ជីកំណើតរស់។

២- ព័ត៌មានអប្បបរមាសម្រាប់ការចុះបញ្ជីកំណើតរស់ រួមមានឈ្មោះ ភេទ ថ្ងៃ ខែ ឆ្នាំកំណើត និងទីកន្លែងកំណើតរបស់អ្នកកើត។

៣- ប្រសិនបើមន្រ្តីអត្រានុកូលដ្ឋានពិនិត្យឃើញថាពាក្យសុំចុះបញ្ជីកំណើតរស់ខ្វះនូវព័ត៌មាន ណាមួយក្នុងចំណោមព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ មន្រ្តីអត្រានុកូលដ្ឋានត្រូវទាមទារឱ្យអ្នករាយការណ៍ផ្តល់ព័ត៌មានដែលខ្វះនោះ ដោយកំណត់រយៈពេល សមរម្យ។ ក្នុងករណីដែលអ្នករាយការណ៍មិនផ្តល់ព័ត៌មានដែលខ្វះក្នុងរយៈពេលសមរម្យដែលបាន កំណត់ដោយមន្រ្តីអត្រានុកូលដ្ឋាន មន្រ្តីអត្រានុកូលដ្ឋានអាចលើកចោលពាក្យសុំចុះបញ្ជីកំណើតរស់ នោះ។

៤- មន្រ្តីអត្រានុកូលដ្ឋានមិនត្រូវបដិសេធពាក្យសុំចុះបញ្ជីកំណើតរស់ ដោយសារខ្វះព័ត៌មាន ដែលទាក់ទងទៅនឹងឪពុកឬម្តាយឡើយ។

---

[93] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ២៤

៥- ប្រសិនបើមន្ត្រីអត្រានុកូលដ្ឋានពិនិត្យឃើញថាពាក្យសុំចុះបញ្ជីកំណើតរស់ដែលខ្វះនូវ ព័ត៌មានមួយចំនួនក្នុងចំណោមចំណុចនីមួយៗ ដែលបានកំណត់នៅក្នុងកថាខណ្ឌទី២នៃមាត្រា២៣ (ពាក្យសុំចុះបញ្ជីកំណើតរស់) ក្រៅពីព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ ខាងលើនេះ ឬខ្វះឯកសារភ្ជាប់ដែលបានកំណត់នៅក្នុងមាត្រា២៤(ឯកសារភ្ជាប់ជាមួយនឹងពាក្យសុំ ចុះបញ្ជីកំណើតរស់) នៃច្បាប់នេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវចុះបញ្ជីកំណើតរស់តាមព័ត៌មានដែលមាន នោះ។ ក្នុងករណីនេះ មន្ត្រីអត្រានុកូលដ្ឋានត្រូវទាមទារឱ្យអ្នករាយការណ៍ផ្តល់ព័ត៌មានបន្ថែម ដោយ កំណត់រយៈពេលសមរម្យ ។

៦- ទោះបីជាមានបញ្ញត្តិនៃកថាខណ្ឌទី៤ខាងលើនេះក៏ដោយ មន្ត្រីអត្រានុកូលដ្ឋានអាច ចុះបញ្ជីដោយឆន្ទានុសិទ្ធិឬដោយទទួលការអនុញ្ញាតពីមន្ត្រីអត្រានុកូលដ្ឋានថ្នាក់លើ ប្រសិនបើមន្ត្រី អត្រានុកូលដ្ឋានបានទទួលព័ត៌មានអប្បបរមាដែលបានកំណត់នៅក្នុងកថាខណ្ឌទី២ខាងលើនេះ តាមការជូនដំណឹងពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធឬវិធីផ្សេងទៀត។[94]

## ការផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល

១- ក្រោយពេលមន្ត្រីអត្រានុកូលដ្ឋានទទួលយកនិងកត់ត្រាព័ត៌មានទាក់ទងនឹងកំណើតរស់ រួចមក មន្ត្រីអត្រានុកូលដ្ឋានត្រូវស្នើទៅមជ្ឈមណ្ឌលជាតិគ្រប់គ្រងអត្តសញ្ញាណប្រជាជននៃអាជ្ញាធរជាតិ គ្រប់គ្រងអត្តសញ្ញាណប្រជាជនដូចមានចែងនៅក្នុងជំពូកទី៦ (ប្រព័ន្ធរួមអត្តសញ្ញាណប្រជាជន) នៃច្បាប់នេះ ដើម្បីផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលដល់អ្នកកើត។

២- ការផ្តល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គល ត្រូវអនុវត្តទៅតាមជំពូកទី៦ (ប្រព័ន្ធរួម អត្តសញ្ញាណប្រជាជន) នៃច្បាប់នេះ។

៣- ក្រោយពេលទទួលបានលេខកូដសម្គាល់អត្តសញ្ញាណបុគ្គល មន្ត្រីអត្រានុកូលដ្ឋានត្រូវ ប្រគល់លេខកូដសម្គាល់អត្តសញ្ញាណបុគ្គលរបស់អ្នកកើតនោះទៅឱ្យអ្នករាយការណ៍។[95]

[94] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ២៥

[93] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ២៦

[94] ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ មាត្រា ២៧

**ការទទួលបានសំបុត្រកំណើត**

១- ក្រោយពេលបានចុះបញ្ជីកំណើតរស់រួចរាល់ មន្ត្រីអត្រានុកូលដ្ឋានមានសមត្ថកិច្ចត្រូវ ចេញសំបុត្រកំណើតច្បាប់ដើម១ (មួយ) ច្បាប់ជូនអ្នករាយការណ៍ដោយឥតគិតថ្លៃ។

២- ព័ត៌មាននៅលើសំបុត្រកំណើតច្បាប់ដើម រួមមាន៖

ក- ឈ្មោះរបស់អ្នកកើត។

ខ- ភេទរបស់អ្នកកើត។

គ- ឈ្មោះឪពុកនិង/ឬម្តាយរបស់អ្នកកើត។

ឃ- ទីកន្លែងកំណើត និងថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នកកើត។

ង- ព័ត៌មានផ្សេងទៀតតាមការចាំបាច់ ដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[96]

## ២. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរតាមរយៈការសុំកូនពេញលេញ

ដោយហេតុថាការសុំកូនពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ដែលសុំកូនជនបរទេសមកធ្វើជាញាតិរបស់ខ្លួន ត្រូវទទួលបានសញ្ជាតិខ្មែរ បានន័យថាសុំកូននេះជាសុំកូនពេញលេញ ហើយមានលក្ខណៈអន្តរប្រទេស ហេតុដូចនេះនាងខ្ញុំសូមលើកនូវនីតិវិធីនៃសុំកូនអន្តរប្រទេស ស្របតាមច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស និងក្រមរដ្ឋប្បវេណី របស់ព្រះរាជាណាចក្រកម្ពុជាដើម្បីឲការសុំកូននេះលក្ខណៈត្រឹមត្រូវ និងអាចឲកូនជនបរទេស ដែលត្រូវសុំនោះអាចទាមទារនិងទទួលបាននូវសញ្ជាតិខ្មែរ ដូចតទៅ៖

ជនដែលមានទីលំនៅជាទៀងទាត់នៅក្នុងរដ្ឋជាភាគីមួយ ដែលប្រាថ្នាចង់យកកុមារម្នាក់ដែលមានលំនៅជាទៀងទាត់ នៅក្នុងរដ្ឋជាភាគីណាមួយទៀតទៅចិញ្ចឹម ត្រូវដាក់ពាក្យទៅអាជ្ញាធរកណ្តាលនៅក្នុងរដ្ឋជាទីលំនៅជាទៀងទាត់របស់ខ្លួន ។[97]

---

[97] ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ១៤

ប្រសិនបើអាជ្ញាធរកណ្តាលនៃរដ្ឋទទួលពេញចិត្តថាអ្នកដាក់ពាក្យនោះមានលក្ខណៈសម្បត្តិ និងសមស្រប អាច យកកុមារមកចិញ្ចឹមបាន អាជ្ញាធរកណ្តាលនោះត្រូវរៀបចំរបាយការណ៍មួយដោយរួមបញ្ចូលពត៌មាន អំពីអត្តសញ្ញាណ លក្ខណៈសម្បត្តិនិងភាពសមស្របអាចសុំកូនបាន ប្រវត្តិផ្ទាល់ខ្លួន ប្រវត្តិគ្រួសារ និង ប្រវត្តិផ្នែកពេទ្យ បរិយាកាសសង្គម ហេតុផលសុំកូន សមត្ថភាពដើម្បីយកកុមារពីប្រទេសមួយទៀតមកចិញ្ចឹមរបស់អ្នកដាក់ពាក្យទាំងនោះ៖ ព្រមទាំងចរិតលក្ខណៈ នៃកុមារដែលគេអាចយកមកបីបាច់រក្សាបាន អាជ្ញាធរកណ្តាល នៃរដ្ឋទទួលត្រូវផ្ញើរបាយការណ៍នេះទៅឱ្យអាជ្ញាធរកណ្តាលនៃរដ្ឋដើម ។[98] បើអាជ្ញាធរកណ្តាលនៃរដ្ឋដើមពេញចិត្តថា កុមារនោះមានលក្ខណៈសម្បត្តិអាចអោយគេយកទៅចិញ្ចឹមបានអាជ្ញាធរនោះត្រូវ ៖-

(ក) រៀបចំរបាយការណ៍មួយដោយរួមបញ្ចូលពត៌មានអំពីអត្តសញ្ញាណ ភាពអាចយកទៅចិញ្ចឹមជាកូនបានប្រវត្តិបរិយាកាសសង្គម ប្រវត្តិគ្រួសារ ប្រវត្តិផ្នែកពេទ្យរបស់កុមារ រួមទាំងប្រវត្តិផ្នែកពេទ្យរបស់ គ្រួសារកុមារផង និង សេចក្តីត្រូវការពិសេសរបស់កុមារ ។

(ខ) ធ្វើការពិចារណាដិតដល់លើការចិញ្ចឹមបីបាច់កុមារ និង ប្រវត្តិជាតិពន្ធ សាសនា និងវប្បធម៌របស់កុមារនោះ ។

(គ) ធានាថា ការយល់ព្រមត្រូវបានស្របនឹងមាត្រា ៤ ។

ឃ) សំរេចថា តើការទុកដាក់កុមារតាមការស្នើសុំទោះស្ថិតក្នុងឧត្តមប្រយោជន៍របស់កុមារដែរ ឬទេ ដោយសំអាងជាពិសេសលើរបាយការណ៍ទាក់ទងនឹងកុមារ និងអនាគតឪពុកម្តាយចិញ្ចឹម ។

២) អាជ្ញាធរកណ្តាលនៃរដ្ឋដើមត្រូវបញ្ជូនអោយអាជ្ញាធរកណ្តាលនៃរដ្ឋទទួលនូវរបាយការណ៍របស់ខ្លួន ស្តីពីកុមារ ភស្តុតាងដែលបញ្ជាក់ថាមានការយល់ព្រមជាចាំបាច់ និង ហេតុផលនៃការសំរេចរបស់ខ្លួនស្តីពីការអោយសុំកូននោះដោយ យកចិត្តទុកដាក់មិនបញ្ចេញឱ្យដឹងអត្តសញ្ញាណនៃម្តាយនិងឪពុករបស់កុមារ ប្រសិនបើអត្តសញ្ញាណនេះមិនអាចបញ្ចេញឱ្យ ដឹងបាននៅក្នុងរដ្ឋដើម ។[99] សេចក្តីសំរេចណាមួយនៅក្នុងរដ្ឋដើមដែលថា កុមារម្នាក់គួរតែបានប្រគល់អោយអនាគតឪពុកម្តាយចិញ្ចឹមថែទាំ នោះ អាចធ្វើបានលុះត្រាណាតែ ៖-

(ក) អាជ្ញាធរកណ្តាលនៃរដ្ឋនោះបានធានាថាអនាគតឪពុកម្តាយចិញ្ចឹមបានព្រមព្រៀង

[98] ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ១៥

[99] ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ១៦

(ខ) អាជ្ញាធរកណ្តាលនៃរដ្ឋទទួលបានយល់ព្រមលើសេចក្តីសំរេចនោះ ក្នុងករណីច្បាប់នៃរដ្ឋនោះ ឬអាជ្ញាធរកណ្តាលនៃរដ្ឋដើមតម្រូវឱ្យមានការយល់ព្រមបែបនោះ

(គ) អាជ្ញាធរកណ្តាលនៃរដ្ឋទាំងពីរបានព្រមព្រៀងគ្នាថា សុំកូនអាចប្រព្រឹត្តទៅបាន

(ឃ) អាជ្ញាធរកណ្តាលនៃរដ្ឋដើមបានពិនិត្យឃើញថា អនាគតឳពុកម្តាយចិញ្ចឹមមានលក្ខណៈសម្បត្តិ និងសមស្រប អាចយកកុមារទៅចិញ្ចឹមបាន ហើយកុមារនោះត្រូវបាន ឬ នឹងត្រូវបានអនុញ្ញាតឱ្យចូលនិងរស់នៅជាអចិន្ត្រៃយ៍ នៅក្នុងរដ្ឋទទួលស្របតាមមាត្រា៥ ។[100]

អាជ្ញាធរកណ្តាលនៃរដ្ឋទាំងពីរត្រូវចាត់វិធានការជាចាំបាច់ ដើម្បីបានការអនុញ្ញាតឱ្យកុមារចាកចេញពីរដ្ឋដើម និង ចូល និងរស់នៅជាអចិន្ត្រៃយ៍នៅក្នុងរដ្ឋទទួល ។

១) ការផ្ទេរកុមារទៅរដ្ឋទទួលអាចអនុវត្តបាន លុះត្រាតែលក្ខខ័ណ្ឌទាំងឡាយនៃមាត្រា ១៧ ត្រូវបានបំពេញ។

២) អាជ្ញាធរកណ្តាលនៃរដ្ឋទាំងពីរត្រូវធានាថា ការផ្ទេរនេះធ្វើឡើងនៅក្នុងកាលៈទេសៈធានាសន្តិសុខនិងសមស្រប ហើយប្រសិនបើអាចធ្វើបានដោយមានការរួមដំណើរនៃឳពុកម្តាយចិញ្ចឹម ឬ អនាគតឳពុកម្តាយចិញ្ចឹម ។

៣) បើការផ្ទេរកុមារនោះមិនបានធ្វើឡើងទេនោះ របាយការណ៍ដែលបានពោលនៅក្នុងមាត្រា ១៥ និង ១៦ ត្រូវផ្ញើត្រឡប់មកឱ្យអាជ្ញាធរដែលបញ្ជូនរបាយការណ៍នោះវិញ ។[101]

ក្រោយពីកូនដែលកម្មវត្ថុនៃការសុំ ត្រូវបានទទួលនិងមកដល់ព្រះរាជាណាចក្រកម្ពុជា ឳពុកម្តាយចិញ្ចឹមត្រូវរៀបចំចុះសំបុត្រកំណើតកូនដែលសុំនោះស្របតាមក្រមរដ្ឋប្បវេណី មាត្រា ១០១៨ បានចែងថា ការចុះបញ្ជី និង ការរក្សាការសម្ងាត់នៃសុំកូនពេញលេញ ប្រសិនបើបានបង្កើតសុំកូនពេញលេញ បញ្ជីកំណើតរបស់កូនសុំ ត្រូវធ្វើជាថ្មី ។ ប៉ុន្តែ នៅក្នុងសំបុត្រកំណើត ឬ សេចក្តីចម្លងសំបុត្រកំណើត ឬ ឯកសារដកស្រង់នៃ បញ្ជីកំណើត មិនត្រូវសរសេរចំណុចស្តីពីសុំកូនឡើយ ក្នុងន័យនេះកូនដែលត្រូវបានសុំនិងទទួលបានសំបុត្រកំណើតថ្មីនិងសញ្ជាតិខ្មែរស្របតាមច្បាប់ស្តីពីសញ្ជាតិខ្មែរផងដែរ។

## ៣. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរតាមរយៈការរៀបអាពាហ៍ពិពាហ៍

---

[100] [100] ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ១៧

[101] ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ១៨

[100] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ៤

ជនបរទេសដែលបានរៀបអាពាហ៍ពិពាហ៍ស្របច្បាប់ជាមួយពលរដ្ឋខ្មែរអាចទាមទារសញ្ជាតិខ្មែរបាន ដោយត្រូវ ដាក់ពាក្យសុំនិងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ។[102]ជនបរទេសដែលទាមទារសញ្ជាតិខ្មែរត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំ និងត្រូវបំពេញបែបបទដូចខាងក្រោម៖ – ពាក្យទាមទារសញ្ជាតិខ្មែរចំនួន ២ (ពីរ) ច្បាប់

– ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម – រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក

-- សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍របស់សាមីខ្លួនចំនួន ២ (ពីរ) ច្បាប់

– លិខិតបញ្ជាក់ទីលំនៅចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់

– ឯកសារបញ្ជាក់ការស្នាក់នៅរយៈពេល ១២ (ដប់ពីរ)ខែ ពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជាចំនួន ២(ពីរ)ច្បាប់

– ច្បាប់ចតចម្លងលិខិតឆ្លងដែននិងទិដ្ឋាការរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន ២(ពីរ) ច្បាប់

– លិខិតបញ្ជាក់គំនិតមារយាទ និងសីលធម៌ចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួន ចំនួន ២ (ពីរ) ច្បាប់

– លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស របស់សាមីខ្លួនចំនួន ១(មួយ)ច្បាប់

- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃ ព្រះរាជាណាចក្រកម្ពុជាចំនួន ១(មួយ)ច្បាប់

–លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋ នៃព្រះរាជាណាចក្រកម្ពុជាចំនួន ២(ពីរ) ច្បាប់។[103]

ជនបរទេសជាឪពុក ឬម្តាយដែលមានកូនរបស់ខ្លួនជាអនីតិជនមុនមានចំណងអាពាហ៍ពិពាហ៍ជាមួយពលរដ្ឋខ្មែរអាចសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារបាន។ ក្នុងករណីនេះ ឪពុក ឬម្តាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូនដូចខាងក្រោម៖

- ពាក្យទាមទារសញ្ជាតិខ្មែរចំនួន ២(ពីរ)ច្បាប់

- ជីវប្រវត្តិសង្ខេបរបស់កូនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម

---

[103] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ៥

– រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក - សេចក្តីចម្លងសំបុត្រកំណើតរបស់កូនចំនួន ២(ពីរ)ច្បាប់

-ច្បាប់ថតចម្លងលិខិតឆ្លងដែននិងទិដ្ឋាការរបស់កូនដែលនៅមានសុពលភាពចំនួន ២(ពីរ)ច្បាប់ លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស របស់កូនចំនួន ១(មួយ)ច្បាប់ ប្រសិនបើកូននោះមានអាយុចាប់ពី១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម១៨ (ដប់ប្រាំបី) ឆ្នាំ

- លិខិតបញ្ជាក់សុខភាពរបស់កូនចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ២ (ពីរ)ច្បាប់។[104]

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ ស្រាវជ្រាវលើសំណុំបែបបទទាមទារសញ្ជាតិខ្មែរក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ស្តីពីសញ្ជាតិ និងបែបបទដែលមានចែងក្នុងមាត្រា៥ និងមាត្រា៦នៃអនុក្រឹត្យនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ ៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ និងបន្តនីតិវិធីលើការទាមទារសញ្ជាតិខ្មែរក្នុងរយៈពេលយ៉ាងយូរ ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។[105]

រាល់ឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ជនបរទេស ត្រូវមានការផ្តល់នីត្យានុកូលកម្មពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួននោះ។[106]ការដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោអាពាហ៍ពិពាហ៍របស់ជនបរទេសត្រូវបង់កម្រៃសេវា។កម្រៃសេវានៃការដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[107]

ការផ្តល់សញ្ជាតិខ្មែរតាមករណីទាមទារសញ្ជាតិខ្មែរដល់ជនបរទេសត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។[108]

[104] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ៦

[105] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ៧

[106] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ៨

[107] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១០

[108] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១១

ជនបរទេសដែលព្រះមហាក្សត្របានប្រទានសញ្ជាតិខ្មែរត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។ ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរត្រូវប្រគល់ជូនសាមីខ្លួន បន្ទាប់ពីបានធ្វើសម្បថរួច។[109]

**៤. នីតិវិធីនៃការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មស្របតាមលិខិតបទដ្ឋានជាធរមាន**

យោងអនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨ បានកំណត់អំពីបែបបទ និងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែរ តាមសញ្ជាតូបនីយកម្ម និងទំហំទឹកប្រាក់វិនិយោគ និងវិភាគទានដើម្បីទទួលបានសញ្ជាតិខ្មែរ ដូចតទៅ៖

ជនបរទេសដែលមានបំណងសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវដាក់ពាក្យសុំ និងបំពេញបែបបទ នៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ។ នៅពេលដាក់ពាក្យសុំ ជនបរទេសនេះត្រូវមានវត្តមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។[110]

ជនបរទេសដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម តាមលក្ខខណ្ឌកំណត់ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិ ត្រូវដាក់ពាក្យសុំ និងបំពេញបែបបទដូចខាងក្រោម៖

- ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២(ពីរ) ច្បាប់
– ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម – រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក
– ច្បាប់ថតចម្លងបណ្ណស្នាក់នៅ ចេញដោយសមត្ថកិច្ចអន្តោប្រវេសន៍ចំនួន ២(ពីរ)ច្បាប់
– បណ្ណការងារ ឬឯកសារបញ្ជាក់មុខរបរ ចំពោះជនបរទេសអន្តោប្រវេសន្តដែលបានកំណត់នៅក្នុងចំណុចទី៣ មាត្រា១៩ និងមាត្រា២០ នៃច្បាប់ស្តីពីសញ្ជាតិចំនួន ២ (ពីរ)ច្បាប់ ឬឯកសារពាក់ព័ន្ធនឹងការវិនិយោគ ចំពោះជនបរទេសដែលបានកំណត់នៅក្នុងចំណុចទី៤មាត្រា១៩ និងមាត្រា២១ នៃច្បាប់ស្តីពីសញ្ជាតិ ចំនួន ២(ពីរ)ច្បាប់
- លិខិតបញ្ជាក់ទីលំនៅចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២(ពីរ) ច្បាប់
– សេចក្តីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ចំនួន ២(ពីរ) ច្បាប់
-- ឯកសារបញ្ជាក់ការស្នាក់នៅជាប់ ឬពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជាដូចបានកំណត់ក្នុងមាត្រា១៩

[109] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១២
[110] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១៦

មាត្រា២០ និងមាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិចំនួន ២(ពីរ)ច្បាប់

- ច្បាប់ថតចម្លងលិខិតឆ្លងដែននិងទិដ្ឋាការរបស់សាមីខ្លួនដែលនៅមានសុពលភាពចំនួន ២(ពីរ)ច្បាប់ - លិខិតបញ្ជាក់គំនិតមារយាទចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់

- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស របស់សាមីខ្លួនចំនួន ១(មួយ)ច្បាប់

- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃ ព្រះរាជាណាចក្រកម្ពុជាចំនួន ១(មួយ)ច្បាប់

- លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចំនួន ២(ពីរ)ច្បាប់។[111]

ជនបរទេសដែលធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌ អាចសុំចូលសញ្ជាតិខ្មែរដោយសញ្ញាតូបនីយកម្ម និងត្រូវបំពេញបែបបទដូចខាងក្រោម ៖

- ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២ (ពីរ) ច្បាប់

- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម – រូបថត ត្រូវថតថ្មីចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក

–លិខិតបញ្ជាក់អំពីអំណោយជាសាច់ប្រាក់ដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រ កម្ពុជាចំនួន ១ (មួយ)ច្បាប់

– សេចក្តីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ចំនួន ២(ពីរ) ច្បាប់

– ឯកសារបញ្ជាក់ការស្នាក់នៅជាប់ ឬពេញលេញក្នុងព្រះរាជាណាចក្រកម្ពុជាដូចបានកំណត់ក្នុងមាត្រា២២ នៃច្បាប់ស្តីពីសញ្ជាតិចំនួន ២(ពីរ) ច្បាប់

– ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមីខ្លួន ដែលនៅមានសុពលភាពចំនួន ២(ពីរ)ច្បាប់

– លិខិតបញ្ជាក់គំនិតមារយាទចេញដោយមេឃុំ ចៅសង្កាត់នៃទីលំនៅរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់

---

[111] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១៧

–លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស របស់សាមីខ្លួនចំនួន ១(មួយ)ច្បាប់

– លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចំនួន២ (ពីរ)ច្បាប់។ [112]

ជនបរទេសដែលមានគុណសម្បត្តិពិសេសឬថ្វីដៃពិសេស អាចសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម និងត្រូវបំពេញបែបបទនៅក្រសួងមហាផ្ទៃដូចខាងក្រោម ៖

- ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២(ពីរ)ច្បាប់
- ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម
- រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក
- លិខិតទទួលស្គាល់របស់រាជរដ្ឋាភិបាលកម្ពុជាអំពីគុណសម្បត្តិពិសេសឬថ្វីដៃពិសេសចំនួន ១(មួយ)ច្បាប់
- សេចក្តីចម្លងសំបុត្រកំណើតដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់សាមីខ្លួនជនបរទេស ចំនួន ២ (ពីរ) ច្បាប់
- លិខិតថ្កោលទោសមានសុពលភាពគិតត្រឹមថ្ងៃដាក់ពាក្យ ចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេស របស់សាមីខ្លួនចំនួន ១(មួយ)ច្បាប់
- ច្បាប់ថតចម្លងលិខិតឆ្លងដែន និងទិដ្ឋាការរបស់សាមីខ្លួន ដែលនៅមានសុពលភាពចំនួន ២(ពីរ)ច្បាប់
- លិខិតបញ្ជាក់សុខភាពចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជាចំនួន - ២ (ពីរ) ច្បាប់។[113]

ជនបរទេសដែលមានសហព័ទ្ធមានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ។ សហព័ទ្ធរបស់ជនបរទេសនោះ ត្រូវបំពេញបែបបទទៅតាមករណីនីមួយៗដូចខាងក្រោម៖ ១-ចំពោះសហព័ទ្ធរបស់ជនបរទេសដែលសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម តាមលក្ខខណ្ឌកំណត់ ក្នុងមាត្រា១៩ មាត្រា២០ និងមាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិ ត្រូវដាក់ពាក្យសុំ និងបំពេញបែបបទដូច បានកំណត់ក្នុង

[112] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១៨

[113] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១៩

[112] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២០

មាត្រា១៧នៃអនុក្រឹត្យនេះ លើកលែងតែចំណុចទី៥ ហើយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លង សំបុត្រអាពាហ៍ពិពាហ៍ចំនួន ២ (ពីរ)ច្បាប់។[114]

២-ចំពោះសហព័ទ្ធរបស់ជនបរទេសដែលធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌ ត្រូវ បំពេញបែបបទដូចបានកំណត់ក្នុងមាត្រា១៨នៃអនុក្រឹត្យនេះ លើកលែងតែចំណុចទី៤ ហើយត្រូវភ្ជាប់ ជាមួយនូវសេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ចំនួន ២ (ពីរ) ច្បាប់។

៣-ចំពោះសហព័ទ្ធរបស់ជនបរទេសដែលមានគុណសម្បត្តិពិសេសឬថ្វីដៃពិសេសត្រូវបំពេញបែបបទដូច បាន កំណត់ក្នុងមាត្រា១៩នៃអនុក្រឹត្យនេះ លើកលែងតែចំណុចទី៤ ហើយត្រូវភ្ជាប់ជាមួយនូវសេចក្តីចម្លង សំបុត្រអាពាហ៍ពិពាហ៍ចំនួន ២(ពីរ)ច្បាប់។

ជនបរទេសដែលមានកូនជាអនីតិជន មានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ។ ក្នុងករណីនេះ ឪពុក ឬម្តាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូនដូចខាងក្រោម៖

-ពាក្យសុំចូលសញ្ជាតិខ្មែរចំនួន ២(ពីរ) ច្បាប់

– ជីវប្រវត្តិសង្ខេបរបស់កូនចំនួន ២ (ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម

– រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក សេចក្តីចម្លងសំបុត្រកំណើតរបស់កូនចំនួន ២(ពីរ) ច្បាប់

– ច្បាប់ថតចម្លងលិខិតឆ្លងដែននិងទិដ្ឋាការរបស់កូនដែលនៅមានសុពលភាពចំនួន ២(ពីរ)ច្បាប់ - លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់កូនចំនួន ១(មួយ) ច្បាប់ ប្រសិនបើកូននោះមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ

– លិខិតថ្កោលទោសមានសុពលភាពចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជាចំនួន ១(មួយ) ច្បាប់ ប្រសិនបើកូននោះមានអាយុចាប់ពី១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ ហើយបានចូលមករស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា

– លិខិតបញ្ជាក់សុខភាពរបស់កូនចេញដោយគ្រូពេទ្យជំនាញនៃមន្ទីរពេទ្យរដ្ឋនៃព្រះរាជាណាចក្រកម្ពុជា ចំនួន ២ (ពីរ)ច្បាប់។[115]

---

[115] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២១

រាល់ឯកសារដែលចេញដោយអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសរបស់ជនបរទេស ត្រូវមានការផ្តល់នីត្យានុកូលកម្ម ពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសសាមីខ្លួននោះ។[116] ការដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មរបស់ជនបរទេសត្រូវបង់កម្រៃសេវា។ កម្រៃសេវានៃការដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មត្រូវកំណត់ដោយប្រកាសអន្តរក្រសួង រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[117]

សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មដល់ជនបរទេសត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើ របស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្តីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។[118]ជនបរទេសដែលព្រះមហាក្សត្របានប្រទានសញ្ជាតិខ្មែរត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល។ ព្រះរាជក្រឹត្យផ្តល់សញ្ជាតិខ្មែរត្រូវប្រគល់ជូនសាមីខ្លួន បន្ទាប់ពីបានធ្វើសម្បថរួច។[119]

អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ ស្រាវជ្រាវលើសំណុំបែបបទសុំចូលសញ្ជាតិខ្មែរដោយ សញ្ជាតូបនីយកម្ម ក្នុងរយៈពេលយ៉ាងយូរ៤៥(សែសិបប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ។ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ស្តីពីសញ្ជាតិ និង បែបបទដែលមានចែងក្នុងមាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ និងមាត្រា២១ នៃអនុក្រឹត្យពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ អគ្គនាយកដ្ឋាន អត្តសញ្ញាណកម្មត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំ ឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ និងបន្តនីតិវិធីលើការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ក្នុងរយៈពេលយ៉ាងយូរ១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។[120]

**ចំនួនទឹកប្រាក់វិនិយោគ វិស័យអាទិភាព ដើម្បីបានសញ្ជាតិខ្មែរតាមរយៈសញ្ជាតិតូបនីយកម្ម**

ជនបរទេសណាដែលបានទទួលការអនុញ្ញាតឱ្យវិនិយោគត្រឹមត្រូវតាមច្បាប់ពីស្ថាប័នមានសមត្ថកិច្ច ស្របតាម គោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាល អាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន តាមមាត្រា២១នៃច្បាប់ស្តីពីសញ្ជាតិ លុះត្រាតែជនបរទេសនោះបាន៖

[116] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២២
[117] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២៤
[118] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២៥
[119] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២៦
[120] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២៧

១- ចំណាយទុនផ្ទាល់ខ្លួនអនុវត្តគម្រោងវិនិយោគជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ចាប់ពី ៤ ០០០ ០០០ ០០០ (បួនប៊ីលាន)រៀលឡើងទៅ។

២- វិនិយោគស្ថិតនៅក្នុងវិស័យអាទិភាពដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

៣- អនុវត្តប្រភេទគម្រោងវិនិយោគដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី២នៃអនុក្រឹត្យនេះ។

៤- បំពេញលក្ខខណ្ឌផ្សេងទៀត ដូចជាកាតព្វកិច្ចសារពើពន្ធ និងផែនការវិនិយោគ។[121]

**ចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិឬវិស័យមនុស្សធម៌ សញ្ជាតិខ្មែរតាមរយៈសញ្ជាតិតូបនីយកម្ម**

ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ផ្ទាល់ខ្លួនដល់ថវិកាជាតិសម្រាប់ជាផលប្រយោជន៍ដល់ ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឬវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យស្នើសុំចូល សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបានតាមមាត្រា២២នៃច្បាប់ស្តីពីសញ្ជាតិ ក្នុងករណីដែលជននោះបានធ្វើអំណោយ ជាសាច់ប្រាក់ចំនួន ចាប់ពី១២ ០០០ ០០០ ០០០ (ដប់ពីរប៊ីលាន)រៀលឡើងទៅ។ អំណោយជាសាប្រាក់ផ្ទាល់ខ្លួនត្រូវមានប្រភពច្បាស់លាស់ និងស្របច្បាប់។ អំណោយនោះត្រូវបង់ចូលថវិកាជាតិ តាមរយៈក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។[122]

## ផ្នែកទី៣សារប្រយោជន៍នៃសញ្ជាតិនិងគោលការណ៍ច្បាប់អន្តរជាតិទប់ស្កាត់ស្ថានភាពគ្មានរដ្ឋ

### ១ គោលការណ៍នៃការបាត់បង់សញ្ជាតិខ្មែរ

### ១.១ តាមការស្ម័គ្រចិត្តរបស់សាមីខ្លួន

យោងតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់សញ្ជាតិខ្មែរ បានចែងថាពលរដ្ឋខ្មែរគ្រប់រូបពុំត្រូវដកហូតសញ្ជាតិដោយឯកឯងនោះទេ។ ការបាត់បង់សញ្ជាតិខ្មែររបស់ប្រជាពលរដ្ឋខ្មែរ គឺស្របតាមការស្នើសុំលះបង់សញ្ជាតិដោយស្ម័គចិត្តប្រសិនបើក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀតហើយការលះបង់នោះគឺ ដើម្បីឲស្របតាមច្បាប់នៃប្រទេសដែលខ្លួនទទួលបានសញ្ជាតិថ្មីនោះ ដែលមិនអនុញ្ញាតប្រជាពលរដ្ឋមានសញ្ជាតិពីរនោះឡើយ។

[121] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២៨

[122] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២៩

ជាក់ស្តែងក្នុងករណីដែលប្រជាពលរដ្ឋខ្មែរដែលបានរៀបការ ស្របច្បាប់ជាមួយជនបរទេស ប្រជាជនខ្មែរដែលបានទៅរស់នៅប្រកបការងារ និងវិនិយោគនៅឯបរទេស ស្របតាមច្បាប់នៃប្រទេសទាំងនោះហើយប្រជាពលរដ្ឋខ្មែរទាំងអស់នោះបានបំពេញនូវរាល់ លក្ខខណ្ឌតម្រូវដើម្បីទទួលបានសញ្ជាតិ នឹងក្រោយពីទទួលបានសញ្ជាតិបរទេសរួចមក ប្រជាពលរដ្ឋខ្មែរដែលរស់នៅប្រទេសដែលអនុញ្ញាតិឲប្រជាជនខ្លួនមានសញ្ជាតិតែមួយប៉ុណ្ណោះ ត្រូវមកស្នើសុំលះបង់សញ្ជាតិខ្មែរដោយស្ម័គ្រចិត្តតាមច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជា ។

**១.១.១ លក្ខខណ្ឌ**

ពលរដ្ឋខ្មែរអាចសុំលះបង់សញ្ជាតិខ្មែរបានដោយស្ម័គចិត្ត ហើយច្បាប់ក៏បានកំណត់ផងដែរថា ជនណាដែលមានសញ្ជាតិខ្មែរហើយមានអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ យ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរ បាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀតនិងដោយគ្មានការបង្ខិតបង្ខំ ។ ត្រូវបានអនុញ្ញាតឱ្យមានការសុំលះបង់សញ្ជាតិខ្មែរជាចង្កោមគ្រួសាររបស់ពលរដ្ឋខ្មែរជាម្តាយ ឬឪពុក ដែលមានកូនជាអនីតិជន ។

ពលរដ្ឋខ្មែរដែលមានបំណងសុំលះបង់សញ្ជាតិខ្មែរ ត្រូវដាក់ពាក្យសុំ និងបំពេញបែបបទនៅអគ្គនាយកដ្ឋានអត្តសញ្ញាណកម្មនៃក្រសួងមហាផ្ទៃ។ពលរដ្ឋខ្មែរដែលសុំលះបង់សញ្ជាតិខ្មែរត្រូវដាក់ពាក្យសុំលះបង់សញ្ជាតិខ្មែរ និងត្រូវបំពេញបែបបទដូចខាងក្រោមៈ

- ពាក្យសុំលះបង់សញ្ជាតិខ្មែរចំនួន ២(ពីរ)ច្បាប់

– ជីវប្រវត្តិសង្ខេបរបស់សាមីខ្លួនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម

– រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក – លិខិតបញ្ជាក់សញ្ជាតិមួយផ្សេងទៀត ឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួន បានដាក់ពាក្យសុំចូលសញ្ជាតិចំនួន ១(មួយ)ច្បាប់

-ច្បាប់ចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅចំនួន ២(ពីរ)ច្បាប់

– សេចក្តីចម្លងសំបុត្រកំណើត ឬច្បាប់ចម្លងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រ កម្ពុជាចំនួន ២ (ពីរ) ច្បាប់

– ចំពោះពលរដ្ឋខ្មែររស់នៅបរទេសស្របច្បាប់ត្រូវមានលិខិតបញ្ជាក់ទីលំនៅរបស់សាមីខ្លួន នៃប្រទេសនោះ ចំនួន ១ (មួយ)ច្បាប់។[123]

ពលរដ្ឋខ្មែរដែលមានកូនជាអនីតិជន មានបំណងស្នើសុំលះបង់សញ្ជាតិខ្មែរ អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារបាន។ ក្នុងករណីនេះ ឪពុក ម្ដាយត្រូវបំពេញបែបបទបន្ថែមសម្រាប់កូនដូចខាងក្រោម ៖

– ពាក្យសុំលះបង់សញ្ជាតិខ្មែរចំនួន ២(ពីរ)ច្បាប់

- ជីវប្រវត្តិសង្ខេបរបស់កូនចំនួន ២(ពីរ)ច្បាប់ ដោយមានបិទរូបថតទំហំ៤ស.មគុណ៦ស.ម

– រូបថត ត្រូវថតថ្មី ចំពីមុខ គ្មានពាក់មួក និងគ្មានពាក់វ៉ែនតាទំហំ៤ស.មគុណ៦ស.មចំនួន ១០(ដប់)សន្លឹក

- លិខិតបញ្ជាក់សញ្ជាតិមួយផ្សេងទៀត ឬលិខិតបញ្ជាក់របស់អាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសដែលសាមីខ្លួនបានដាក់ពាក្យសុំចូលសញ្ជាតិចំនួន ១(មួយ)ច្បាប់ ច្បាប់ចម្លងសៀវភៅគ្រួសារ ឬសៀវភៅស្នាក់នៅចំនួន ២(ពីរ)ច្បាប់

- សេចក្ដីចម្លងសំបុត្រកំណើតរបស់កូនចំនួន ២ (ពីរ) ច្បាប់

- ច្បាប់ចម្លងលិខិតឆ្លងដែនរបស់កូនដែលនៅមានសុពលភាពចំនួន ២(ពីរ)ច្បាប់។

បន្ទាប់ពីបំពេញសំណុំបែបបទរួច អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ ស្រាវជ្រាវលើសំណុំបែបបទសុំលះបង់សញ្ជាតិខ្មែរក្នុងរយៈពេល យ៉ាងយូរ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ ក្នុងករណីដែលអ្នកស្នើសុំមិនបានបំពេញត្រឹមត្រូវតាមលក្ខខណ្ឌដែលបានកំណត់ក្នុងច្បាប់ស្ដីពីសញ្ជាតិ និង បែបបទដែលមានចែងក្នុងមាត្រា៣២និងមាត្រា៣៣នៃអនុក្រឹត្យនេះ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវជូនដំណឹង ជាលាយលក្ខណ៍អក្សរទៅអ្នកស្នើសុំឱ្យធ្វើការកែតម្រូវក្នុងរយៈពេលយ៉ាងយូរ៣០ (សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការ។ អគ្គនាយកដ្ឋានអត្តសញ្ញាណកម្មត្រូវពិនិត្យ និងបន្តនីតិវិធីលើការសុំលះបង់សញ្ជាតិខ្មែរ ក្នុងរយៈពេលយ៉ាងយូរ ១០(ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃទទួលបានឯកសារកែតម្រូវ។

### ១.១.២ អានុភាព

ក្រោយពេលក្រសួងមហាផ្ទៃ ពិនិត្យឃើញនូវភាពត្រឹមត្រូវនៃឯកសារសំណុំបែបបទ នៃការស្នើសុំលះបង់សញ្ជាតិខ្មែរ ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរដល់ពលរដ្ឋខ្មែរនឹង ត្រូវសម្រេចដោយព្រះរាជក្រឹត្យ តាមសំណើរបស់នាយករដ្ឋមន្ត្រី បន្ទាប់ពីមានសេចក្ដីស្នើសុំរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

[123] អនុក្រឹត្យ ស្ដីពី ការអនុវត្តច្បាប់ស្ដីពីសញ្ជាតិ ២០១៨ មាត្រា ៣

បន្ទាប់ពីសាមីខ្លួនទទួលបានព្រះរាជក្រឹត្យស្តីពីការអនុញ្ញាតឲលះបង់សញ្ជាតិខ្មែរដោយគ្មានការបង្ខិតបង្ខំរួច មកមានន័យថាភាពជាពលរដ្ឋខ្មែរក៏ត្រូវបានបាត់បង់នាពេលនោះផងដែរ ជននោះនឹងបាត់បង់នូវរាល់ សិទ្ធិរបស់ប្រជាពលរដ្ឋខ្មែរ ករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ហើយជននោះក៏នឹងក្លាយជាជនបរទេសស្របពេលជាមួយគ្នាផងដែរហើយ លិខិតឆ្លងដែន អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឯកសារស្នាក់នៅរួមមាន សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ នៃព្រះរាជាណាចក្រកម្ពុជាក៏ត្រូវអស់តម្លៃគតិយុត្តិសម្រាប់ជននោះដែរ។

## ១.២ តាមរយៈទោសទណ្ឌ

### ១.២.១ លក្ខខណ្ឌ

ទោះបីជាព្រះរាជាណាចក្រកម្ពុជាពុំមានការដកហូតសញ្ជាតិខ្មែរ ពីជនបរទេសដែលបានចូលសញ្ជាតិខ្មែរតាមរយៈសញ្ជាតិតូបនីយកម្ម ឬតាមរយៈការរៀបអាពាហ៍ពិពាហ៍ក៏ដោយ ក៏ប៉ុន្តែរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាក៏អាចបដិសេធក្នុងការផ្តល់ជូននូវសញ្ជាតិខ្មែរតាមរយៈសញ្ជាតិតូបនីយកម្ម ឬតាមរយៈការៀបអាពាហ៍ពិពាហ៍ផងដែរព្រោះថាការផ្តល់ឲនូវ សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ ព្រះរាជាណាចក្រកម្ពុជា តែប៉ុណ្ណោះ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលតាមអំណាចឆន្ទានុសិទ្ធិ។[124] រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចសម្រេចបដិសេធ ចំពោះសំណើសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ និង តាមរយៈសញ្ជាតិតូបនីយកម្ម ក្នុងករណីណាមួយដូចខាងក្រោម៖

១- អាពាហ៍ពិពាហ៍ក្លែង ២- ឯកសារក្លែងនៅក្នុងសំណុំបែបបទស្នើសុំទាមទារសញ្ជាតិខ្មែរ ៣- អាពាហ៍ពិពាហ៍ផ្ទុយនឹងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ៤- ការមិនបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា១១ និងមាត្រា១២នៃច្បាប់ស្តីពីសញ្ជាតិ ៥- ការមិនបានបំពេញកាតព្វកិច្ចដូចបានកំណត់ក្នុងកថាខណ្ឌទី២ មាត្រា៧នៃអនុក្រឹត្យអនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ ។[125]

### ១.២.២ អានុភាព

[124] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ២៨

[125] អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ មាត្រា ១៣

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជារាល់ជនបរទេស អន្តោប្រវេសន៍ណាដែលរំលោភលើ បញ្ញត្តិច្បាប់អន្តោប្រវេសន៍។ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ មានសិទ្ធិបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសដែល ៖ ១. មានអាកប្បកិរិយានិងសកម្មភាពគ្រោះថ្នាក់ដល់សន្តិសុខជាតិនៃព្រះរាជាណាចក្រកម្ពុជា ២- ក្រសួងមានសមត្ថកិច្ចមានភស្តុតាងជាក់លាក់ថាជននោះជាអ្នកប្រឆាំងនឹងសន្តិសុខនៃព្រះរាជាណាចក្រកម្ពុជា ៣_ មកធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយគ្មានប័ណ្ណការងារ ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជា រាល់ជនបរទេសណាដែលចូលក្នុងព្រះរាជាណាចក្រកម្ពុជាដោយខុសច្បាប់ ។ សេចក្តីសំរេចបណ្តេញចេញត្រូវអនុវត្តភ្លាម ចាប់ពីថ្ងៃចុះហត្ថលេខារបស់រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ សាមីខ្លួនមានសិទ្ធិប្តឹងទៅតុលាការក្នុងរយៈពេល ២ ខែ ។ ការបណ្តេញចេញត្រូវអនុវត្តក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរ ក្រោយពីសេចក្តីសំរេចចេញ ជាផ្លូវការពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ លើកលែងតែមានសាលក្រមផ្អាកការអនុវត្តពីតុលាការ ។[126]

រាល់ជនបរទេសដែលប្រព្រឹត្តល្មើសនិងច្បាប់អន្តោប្រវេសន៍និងច្បាប់សញ្ជាតិនៃព្រះរាជាណាចក្រកម្ពុជាត្រូវដកហូតរាល់ឯកសារពាក់ព័ន្ធ និងបដិសេដរាល់ការស្នើសុំសញ្ជាតិខ្មែរ នឹងត្រូវបណ្តេញចេញពីព្រះរាជាណាចក្រកម្ពុជាក្រោយមានសម្រេចផ្លូវការពីក្រសួងមហាផ្ទៃ។

## ២ គោលការណ៍ច្បាប់អន្តរជាតិ

### ២.១ អនុសញ្ញាទីក្រុងញូយ៉ក ឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានសញ្ជាតិ

#### ក.ខ្លឹមសារ

អនុសញ្ញាទីក្រុងញូវយ៉កឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានរដ្ឋនិងសញ្ជាតិ គឺជាសន្ធិសញ្ញាអន្តរជាតិដែលបង្កើតឡើងដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ជនគ្មានសញ្ជាតិ បុគ្គលដែលខ្វះភាពជាពលរដ្ឋ វាបង្កើតស្តង់ដារសម្រាប់ដោះស្រាយដល់ជនដែលគ្មានរដ្ឋ និងមានគោលបំណងទប់ស្កាត់ភាពគ្មានរដ្ឋ។ អនុសញ្ញាទីក្រុងញូវយ៉កឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានរដ្ឋនិងសញ្ជាតិ ក៏ជាសន្ធិសញ្ញាអន្តរជាតិដ៏ទូលំទូលាយមួយដែលត្រូវបានបង្កើតឡើងដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់បុគ្គលគ្មានរដ្ឋ និងសម្រាប់ការពារជនគ្មានរដ្ឋផងដែរ។

---

[126] យោងតាមច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៩៤, មាត្រា ៣៥

បទប្បញ្ញត្តិសំខាន់ៗនៃអនុសញ្ញា៖

និយមន័យនៃជនគ្មានរដ្ឋ៖ អនុសញ្ញាកំណត់បុគ្គលគ្មានរដ្ឋថាជាអ្នកដែលមិនត្រូវបានចាត់ទុកថាជាជនជាតិដោយរដ្ឋណាមួយក្រោមច្បាប់របស់ខ្លួន។ សិទ្ធិ និងកាតព្វកិច្ច៖ អនុសញ្ញាបង្ហាញអំពីសិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋទាក់ទងនឹងជនគ្មានរដ្ឋ រួមមានៈ ការមិនរើសអើង៖ រដ្ឋនានាមិនត្រូវរើសអើងប្រឆាំងនឹងជនគ្មានរដ្ឋដោយផ្អែកលើមូលដ្ឋាននៃភាពគ្មានសញ្ជាតិរបស់ពួកគេ។ សិទ្ធិស៊ីវិល៖ ជនគ្មានសញ្ជាតិគួរតែមានសិទ្ធិស៊ីវិលដូចគ្នានឹងសញ្ជាតិ រួមទាំងសិទ្ធិធ្វើការ ការអប់រំ លំនៅឋាន និងសិទ្ធិទទួលបានតុលាការ។ ឯកសារធ្វើដំណើរ៖ រដ្ឋគួរតែចេញឯកសារធ្វើដំណើរដល់ជនគ្មានរដ្ឋ ដើម្បីជួយសម្រួលដល់ចលនារបស់ពួកគេ។ ការបណ្តេញចេញ៖ រដ្ឋមិនគួរបណ្តេញជនគ្មានសញ្ជាតិទៅកាន់ប្រទេសដែលពួកគេប្រថុយនឹងការធ្វើទុក្ខបុកម្នេញ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត។ ការកាត់បន្ថយភាពគ្មានរដ្ឋ៖ អនុសញ្ញាលើកទឹកចិត្តឱ្យរដ្ឋនានាចាត់វិធានការទប់ស្កាត់ និងកាត់បន្ថយភាពគ្មានរដ្ឋ ដូចជា៖ ការចុះឈ្មោះកំណើត៖ ធានាថាការសម្រាលកូនត្រូវបានចុះបញ្ជីដើម្បីការពារភាពគ្មានសញ្ជាតិនៅពេលកើត។ ការសុំកូន៖ ការសម្រួលដល់ការសុំកូនដែលគ្មានរដ្ឋដើម្បីផ្តល់សញ្ជាតិដល់ពួកគេ។ ការចូលសញ្ជាតិ៖ ធ្វើឱ្យនីតិវិធីនៃការចូលសញ្ជាតិអាចចូលដំណើរការបានសម្រាប់ជនគ្មានរដ្ឋ។[127]

**ខ.ការអនុវត្តនិងចំនួនប្រទេសចូលរួមហត្ថលេខី**

យោងតាមគេហទំព័ររបស់ ឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន (UNHCR) គិតត្រឹមខែកញ្ញា ឆ្នាំ ២០២៣ ប្រទេសចំនួន ៩៦ គឺជាភាគីនៃអនុសញ្ញាឆ្នាំ ១៩៥៤ ទាក់ទងនឹងស្ថានភាពនៃជនគ្មានសញ្ជាតិ។ សន្ធិសញ្ញាអន្តរជាតិនេះមានគោលបំណងការពារបុគ្គលដែលគ្មានរដ្ឋ ដោយផ្តល់ឱ្យពួកគេនូវក្របខ័ណ្ឌច្បាប់ដើម្បីធានានូវសិទ្ធិជាមូលដ្ឋាន និងការទទួលបានសេវា។ វាក៏កំណត់ផងដែរនូវអ្នកដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាជនគ្មានរដ្ឋ ហើយផ្តល់ការណែនាំសម្រាប់ស្ថានភាពផ្លូវច្បាប់របស់ពួកគេ រួមទាំងសិទ្ធិទទួលបានការអប់រំ ការងារ និងឯកសារ។ អនុសញ្ញាឆ្នាំ ១៩៥៤ រួមជាមួយនឹងអនុសញ្ញាឆ្នាំ ១៩៦១ ស្តីពីការកាត់បន្ថយភាពគ្មានសញ្ជាតិ បង្កើតជាមូលដ្ឋាននៃក្របខ័ណ្ឌច្បាប់អន្តរជាតិសម្រាប់ការដោះស្រាយភាពគ្មានសញ្ជាតិហើយត្រូវបានអនុវត្តជាសកល។ ប្រទេសមួយចំនួនដែលជាហត្ថលេខីនៃអនុសញ្ញាឆ្នាំ ១៩៥៤ រួមមានៈ សហរដ្ឋអាមេរិក អាល្លឺម៉ង់ ចក្រភពអង់គ្លេស ប្រទេសបារាំង ប្រេស៊ីល អូស្ត្រាលី ប្រទេសកាណាដា ប្រទេសជាច្រើនដែលបានផ្តល់សច្ចាប័នលើអនុសញ្ញានេះ បានបង្កើតគោលនយោបាយជាតិ ឬយន្តការដើម្បីកំណត់ និងគាំទ្របុគ្គលដែលគ្មានរដ្ឋនៅក្នុងព្រំដែន

[127] អនុសញ្ញាទីក្រុងញូវយ៉កឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានរដ្ឋនិងសញ្ជាតិ

របស់ពួកគេ ខណៈដែលប្រទេសផ្សេងទៀតកំពុងធ្វើការលើការអនុវត្តក្របខ័ណ្ឌដ៏ទូលំទូលាយ។ ទោះបីជាយ៉ាងនេះក៏ដោយ ប្រទេសមួយចំនួនមិនទាន់បានចុះហត្ថលេខា ឬផ្តល់សច្ចាប័នលើអនុសញ្ញានេះទេ ហើយភាពគ្មានរដ្ឋនៅតែជាបញ្ហាសំខាន់នៅទូទាំងពិភពលោក ដែលប៉ះពាល់ដល់មនុស្សរាប់លាននាក់ ជាពិសេសនៅក្នុងតំបន់ដែលមានជម្លោះជនជាតិភាគតិច ការធ្វើចំណាកស្រុក និងច្បាប់សញ្ជាតិដែលអាចបណ្តាលឱ្យបុគ្គលគ្មានសញ្ជាតិ។[128]

**គ.លទ្ធផល**

អនុសញ្ញាទីក្រុងញូវយ៉កឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានរដ្ឋនិងសញ្ជាតិ បានចូលរួមចំណែកយ៉ាងសំខាន់ដល់ច្បាប់អន្តរជាតិ និងការការពារសិទ្ធិមនុស្ស លទ្ធផលនៃការអនុវត្តរបស់អនុសញ្ញារួមមាន:

១ ការកំណត់និយមន័យនៃភាពគ្មានរដ្ឋ៖ អនុសញ្ញាផ្តល់និយមន័យច្បាស់លាស់នៃជនគ្មានរដ្ឋជាបុគ្គលដែលមិនត្រូវបានចាត់ទុកថាជាជាតិដោយ រដ្ឋណាមួយនៅក្រោមច្បាប់របស់ខ្លួន។ និយមន័យនេះបានក្លាយជាមូលដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិ ហើយបានជួយកំណត់អត្តសញ្ញាណ និងការពារបុគ្គលដែលងាយរងគ្រោះដោយសារភាពគ្មានរដ្ឋ។

២. ស្តង់ដារអប្បបរមានៃការដោះស្រាយ៖ អនុសញ្ញានេះបង្កើតស្តង់ដារអប្បបរមានៃការដោះស្រាយសម្រាប់ជនគ្មានរដ្ឋ។ វាទាមទារឱ្យជនគ្មានរដ្ឋមានសិទ្ធិដូចគ្នានឹងពលរដ្ឋទាក់ទងនឹងសេរីភាពខាងសាសនា និងការអប់រំកូនរបស់ពួកគេ។ វាក៏ផ្តល់សិទ្ធិសម្រាប់ជនគ្មានសញ្ជាតិក្នុងការធ្វើដំណើរ និងធ្វើការផងដែរ។

៣. ការទប់ស្កាត់ការបណ្តេញចេញ៖ អនុសញ្ញាហាមឃាត់ការបណ្តេញជនគ្មានរដ្ឋចេញពីទឹកដីនៃរដ្ឋជាប់កិច្ចសន្យា លុះត្រាតែវាចាំបាច់សម្រាប់ហេតុផលសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ។ ការផ្តល់នេះជួយធានាថា ជនគ្មានសញ្ជាតិមិនត្រូវបានទុកចោលដោយគ្មានកន្លែងសម្រាប់ហៅទៅផ្ទះនោះទេ។

៤. ការសម្របសម្រួលនៃការចូលសញ្ជាតិ៖ អនុសញ្ញានេះលើកទឹកចិត្តដល់រដ្ឋជាប់កិច្ចសន្យា ដើម្បីជួយសម្រួលដល់ការចូលសញ្ជាតិនៃជនគ្មានរដ្ឋ។ នេះអាចផ្តល់ឱ្យជនគ្មានរដ្ឋនូវផ្លូវទៅកាន់ភាពជាពលរដ្ឋ និងជួយកាត់បន្ថយឧប្បត្តិហេតុនៃភាពគ្មានសញ្ជាតិ។

[128] អនុសញ្ញាទីក្រុងញូវយ៉កឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានរដ្ឋនិងសញ្ជាតិ

៥. កិច្ចសហប្រតិបត្តិការអន្តរជាតិ៖ អនុសញ្ញានេះជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិក្នុងការដោះស្រាយបញ្ហានៃភាពគ្មានរដ្ឋ។ វាលើកទឹកចិត្តឱ្យរដ្ឋចែករំលែកព័ត៌មាន និងសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងរបស់ពួកគេដើម្បីការពារ និងកាត់បន្ថយភាពគ្មានរដ្ឋ។

សរុបមក អនុសញ្ញាញូវយ៉កឆ្នាំ ១៩៥៤ ស្តីពីភាពគ្មានរដ្ឋគឺជាឧបករណ៍ដ៏មានតម្លៃសម្រាប់ការពារសិទ្ធិជនគ្មានសញ្ជាតិ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរជាតិលើបញ្ហាដ៏សំខាន់នេះ។ ខណៈពេលដែលនៅតែមានការងារដែលត្រូវធ្វើដើម្បីដោះស្រាយបញ្ហាប្រឈមដែលមនុស្សគ្មានរដ្ឋជួបប្រទះ អនុសញ្ញាបានផ្តល់នូវមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់វឌ្ឍនភាព។[129]

## ៣ សារៈប្រយោជន៍នៃការទទួលបានសញ្ជាតិ

### ៣.១ ភាពជាពលរដ្ឋតាមច្បាប់ជាតិ និងអន្តរជាតិ

សារៈសំខាន់នៃសញ្ជាតិក្រោមច្បាប់ជាតិ និងអន្តរជាតិជាតិ សញ្ជាតិតែងតែផ្សារភ្ជាប់ទៅនិង ហើយភាពជាពលរដ្ឋគឺជាស្ថានភាពផ្លូវច្បាប់ជាមូលដ្ឋានដែលផ្តល់សិទ្ធិ និងកាតព្វកិច្ចដល់បុគ្គល វាជាមូលដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិ និងច្បាប់ជាតិ ដែលបង្កើតជីវិតមនុស្សរាប់លាននាក់ជុំវិញពិភពលោក។

**ភាពជាពលរដ្ឋតាមច្បាប់ជាតិ៖** ភាពជាពលរដ្ឋគឺជាកត្តាកំណត់យ៉ាងសំខាន់នៃសិទ្ធិ និងការទទួលខុសត្រូវ ជាធម្មតា ប្រជាពលរដ្ឋទទួលបានសិទ្ធិជាច្រើន រួមទាំង៖ សិទ្ធិនយោបាយ៖ បោះឆ្នោត កាន់តំណែងសាធារណៈ និងចូលរួមក្នុងដំណើរការនយោបាយ។ សិទ្ធិពលរដ្ឋ៖ សេរីភាពនៃការបញ្ចេញមតិ ការជួបជុំ និងសាសនា។ សិទ្ធិសង្គម៖ ការទទួលបានការអប់រំ ការថែទាំសុខភាព និងកម្មវិធីសុខុមាលភាពសង្គម។សិទ្ធិសេដ្ឋកិច្ច៖ សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ការងារ និងចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ច។ សញ្ជាតិក៏អាចជាតម្រូវការជាមុនសម្រាប់សេវាសាធារណៈមួយចំនួន ដូចជាសេវាយោធា ការបំពេញការងារសាធារណៈ នៅក្នុងប្រទេសមួយចំនួន ភាពជាពលរដ្ឋអាចត្រូវបានផ្សារភ្ជាប់ជាមួយនឹងអត្ថប្រយោជន៍ ឬសិទ្ធិជាក់លាក់ ដូចជាការអនុគ្រោះពន្ធនិងការទទួលបានផលប្រយោន៍នានាក្នុងប្រទេសដែលខ្លួនរស់នៅ។

**ច្បាប់អន្តរជាតិ**

នៅក្រោមច្បាប់អន្តរជាតិ សញ្ជាតិគឺពាក់ព័ន្ធជាចម្បងទៅនឹងការអនុវត្តការការពារការទូត។ នេះពាក់ព័ន្ធនឹងរដ្ឋដែលតំណាងឱ្យពលរដ្ឋរបស់ខ្លួននៅបរទេស និងការពារផលប្រយោជន៍របស់ពួកគេ ជាពិសេសនៅក្នុងករណីនៃ

[129] អនុសញ្ញាទីក្រុងញូវយ៉កឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានរដ្ឋនិងសញ្ជាតិ

ការអនុវត្តខុស ឬការបដិសេធសិទ្ធិ។ ភាពជាពលរដ្ឋក៏ដើរតួនាទីក្នុងការកំណត់លទ្ធភាពទទួលបានសេវាកុងស៊ុល ដែលអាចមានសារៈសំខាន់សម្រាប់ពលរដ្ឋដែលធ្វើដំណើរ ឬរស់នៅក្រៅប្រទេស។

សរុបមក ភាពជាពលរដ្ឋគឺជាស្ថានភាពផ្លូវច្បាប់ដ៏សំខាន់ដែលកំណត់សិទ្ធិ កាតព្វកិច្ច និងឱកាសរបស់បុគ្គលម្នាក់ៗ វាជាមូលដ្ឋានគ្រឹះនៃច្បាប់អន្តរជាតិ និងច្បាប់ជាតិ ដែលធានាថាបុគ្គលម្នាក់ៗមានមូលដ្ឋានច្បាប់សម្រាប់សិទ្ធិ និងការការពាររបស់ពួកគេ។

**៣.២ ទទួលបានសិទ្ធិស៊ីវិល នយោបាយ និង និងភាពជាពលរដ្ឋនៃប្រទេសពេញបរិបូណ៌**

សិទ្ធិស៊ីវិលរបស់ពលរដ្ឋ និងសិទ្ធិនយោបាយ គឺជាទិដ្ឋភាពទាក់ទងគ្នាយ៉ាងជិតស្និទ្ធនៃសញ្ជាតិ។ សិទ្ធិស៊ីវិលរបស់ពលរដ្ឋគឺជាសេរីភាពជាមូលដ្ឋាន និងការការពារដែលប្រជាពលរដ្ឋទាំងអស់ទទួលបាន ចំណែកនយោបាយសំដៅទៅលើដំណើរការនៃការចូលរួមក្នុង សកម្មភាពសម្រាប់ជីវិតប្រចាំថ្ងៃ និងកែការកែសម្អក្នុងការគ្រប់គ្រងរដ្ឋ។ ទាំងពីរគឺជាសមាសធាតុសំខាន់នៃសង្គមដែលមានប្រជាធិបតេយ្យ។

**សិទ្ធិស៊ីវិលរបស់ពលរដ្ឋ**

មូលដ្ឋានគ្រឹះនៃភាពជាពលរដ្ឋ៖ សិទ្ធិពលរដ្ឋគឺជាមូលដ្ឋានគ្រឹះដែលសញ្ជាតិត្រូវបានបង្កើតឡើង ពួកគេផ្តល់នូវក្របខ័ណ្ឌសំខាន់សម្រាប់បុគ្គលម្នាក់ៗក្នុងការរស់នៅប្រកបដោយសេចក្តីថ្លៃថ្នូរ និងការគោរព។ ការការពារសិទ្ធិបុគ្គល៖ សិទ្ធិស៊ីវិលការពារបុគ្គលពីការរំលោភបំពានរបស់រដ្ឋាភិបាល និងធានាថាសិទ្ធិរបស់ពួកគេមិនត្រូវបានរំលោភបំពាន។ សមភាព និងយុត្តិធម៌៖ សិទ្ធិពលរដ្ឋលើកកម្ពស់សមភាព និងយុត្តិធម៌ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ ដោយមិនគិតពីសាវតា ឬកាលៈទេសៈរបស់ពួកគេ។

**នយោបាយ និងពលរដ្ឋ៖**

ការចូលរួមក្នុងរដ្ឋាភិបាល៖ នយោបាយអនុញ្ញាតឱ្យប្រជាពលរដ្ឋចូលរួមក្នុងការគ្រប់គ្រងរដ្ឋរបស់ពួកគេតាមរយៈការបោះឆ្នោត ការកាន់តំណែងសាធារណៈ និងការចូលរួមក្នុងសកម្មភាពនយោបាយផ្សេងទៀត។ គណនេយ្យភាពរបស់រដ្ឋាភិបាល៖ នយោបាយធានាថារដ្ឋាភិបាលមានទំនួលខុសត្រូវចំពោះប្រជាពលរដ្ឋដែលខ្លួនតំណាង ហើយថាពួកគេឆ្លើយតបទៅនឹងតម្រូវការ និងកង្វល់របស់ប្រជាពលរដ្ឋ។ការចូលរួមរបស់ពលរដ្ឋ៖ ការចូលរួមនយោបាយជំរុញឱ្យមានការចូលរួមរបស់ប្រជាពលរដ្ឋ និងការយល់ដឹងអំពីភាពជាកម្មសិទ្ធិរបស់សហគមន៍។ទំនាក់ទំនងរវាងសិទ្ធិពលរដ្ឋ និងនយោបាយ៖ភាពអាស្រ័យគ្នាទៅវិញទៅមក៖ សិទ្ធិពលរដ្ឋ និងនយោបាយគឺអាស្រ័យគ្នាទៅវិញទៅមក។ បើគ្មានសិទ្ធិពលរដ្ឋទេ ប្រជាពលរដ្ឋមិនអាចចូលរួមក្នុងដំណើរការនយោបាយបានពេញលេញទេ ហើយបើគ្មានការ

ចូលរួមនយោបាយទេ សិទ្ធិពលរដ្ឋអាចនឹងត្រូវបាត់បង់។ការពង្រឹងគ្នាទៅវិញទៅមក៖ សិទ្ធិស៊ីវិលដ៏រឹងមាំ និងការចូលរួមនយោបាយសកម្មពង្រឹងគ្នាទៅវិញទៅមក។ នៅពេលដែលប្រជាពលរដ្ឋមានសិទ្ធិពលរដ្ឋខ្លាំង ពួកគេទំនងជាចូលរួមក្នុងនយោបាយ ហើយនៅពេលដែលពលរដ្ឋចូលរួមយ៉ាងសកម្មក្នុងនយោបាយ ពួកគេទំនងជាការពារសិទ្ធិពលរដ្ឋរបស់ពួកគេ។

សរុបសេចក្តីមក សិទ្ធិពលរដ្ឋ និងនយោបាយ គឺជាធាតុផ្សំដ៏សំខាន់នៃសញ្ជាតិ។ ពួកគេផ្តល់មូលដ្ឋានគ្រឹះសម្រាប់សង្គមប្រជាធិបតេយ្យ និងយុត្តិធម៌ ដោយធានាថាបុគ្គលម្នាក់ៗអាចរស់នៅដោយសេចក្តីថ្លៃថ្នូរ និងចូលរួមប្រកបដោយអត្ថន័យក្នុងការគ្រប់គ្រងរដ្ឋរបស់ពួកគេ។[130]

### ៣.៣ ការលុបបំបាត់ភាពរើសអើងជនជាតិដើមភាគតិចដែលទទួលបានសញ្ជាតិខ្មែរ

ជនជាតិដើមភាគតិចនៅកម្ពុជាត្រូវបានទទួលស្គាល់ថាជាពលរដ្ឋកម្ពុជា ពួកគេមានសិទ្ធិ និងទំនួលខុសត្រូវដូចគ្នានឹងពលរដ្ឋកម្ពុជាផ្សេងទៀត រួមទាំងសិទ្ធិបោះឆ្នោត កាន់តំណែងសាធារណៈ និងទទួលបានសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយផ្សេងទៀត ស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់សញ្ជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា និងការផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ៖ កម្ពុជាបានផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន រួមទាំងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃ ការរើសអើងប្រឆាំងនឹងជនជាតិដើមផងដែរ ហើយបើ ប្រៀបធៀបនិងប្រទេសជិតខាងមួយចំនួនដែលពុំទទួលស្គាល់សិទ្ធិជនជាតិដើម មួយចំនួនជាពលរដ្ឋរបស់ខ្លួននោះទេ។

ជាក់ស្តែងដូចជាប្រទេសប្រទេសវៀតណាម ពុំបានទទទួលស្គាល់សិទ្ធិពេញលេញនូវជនជាតិ ម៉ុងតាញ៉ា (ឬ Degar)នោះទេ ជនជាតិម៉ុងតាញ៉ា រួមមានក្រុមជនជាតិផ្សេងៗជាច្រើនដូចជា ចារ៉ាយ បាណារ រ៉ាដេ និងក្រុមផ្សេងៗទៀត។ ក្រុមនីមួយៗមានភាសា ទំនៀមទម្លាប់ និងអង្គការសង្គមផ្ទាល់ខ្លួន។ អង្គការសិទ្ធិមនុស្ស និងស្ថាប័នអន្តរជាតិជាច្រើនបានលើកឡើងពីបញ្ហាដែលជនជាតិម៉ុងតាញ៉ាប្រឈមមុខ រួមមានជម្លោះដីធ្លី និងបញ្ហាសិទ្ធិមនុស្ស។ ទោះជាយ៉ាងណាក៏ដោយ ការដោះស្រាយបញ្ហាទាំងនេះជារឿយៗពាក់ព័ន្ធនឹងការរុករកទិដ្ឋភាពនយោបាយ និងសង្គមដ៏ស្មុគស្មាញនៅក្នុងប្រទេសវៀតណាម។ រដ្ឋាភិបាលវៀតណាមទទួលស្គាល់ក្រុមម៉ុងតាញ៉ាមួយចំនួនជាផ្នែកនៃក្រុមជនជាតិភាគតិចចំនួន ៥៤ នៅក្នុងប្រទេស ប៉ុន្តែសហគមន៍ទាំងនេះនៅតែប្រឈមមុខនឹងបញ្ហាប្រឈមជាច្រើនទាក់ទងនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ច សិទ្ធិដីធ្លី និងការអភិរក្សវប្បធម៌។ ចំណែកឯប្រទេសមីយ៉ាន់ម៉ាក៏ មានក្រុមជន

[130] សេចក្តីប្រកាសអំពីសិទ្ធិមនុស្សក្នុងរដ្ឋធម្មនុញ្ញកម្ពុជាការិយាល័យឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

ជាតិដើមភាគតិចជាច្រើននៅក្នុងប្រទេ ដែលមិនត្រូវបានទទួលស្គាល់ជាផ្លូវការដោយរដ្ឋាភិបាលយោធាមុនៗ។[131] ក្រុមទាំងនេះជារឿយៗប្រឈមមុខនឹងការរើសអើង ការរើសអើង និងការរំលោភសិទ្ធិមនុស្ស។ ជនជាតិដើមភាគតិចដែលមិនត្រូវបានទទួលស្គាល់ពេញលេញនៅក្នុងប្រទេសមីយ៉ាន់ម៉ា៖ កាឈីន៖ ជនជាតិកាឈីន គឺជាក្រុមជនជាតិភាគតិចដ៏ធំមួយ ដែលមានទីតាំងនៅភាគខាងជើងប្រទេសមីយ៉ាន់ម៉ា។ ពួកគេបានប្រឈមមុខនឹងជម្លោះបន្តជាមួយរដ្ឋាភិបាលមីយ៉ាន់ម៉ា ហើយមានអង្គការនយោបាយ និងយោធាផ្ទាល់ខ្លួន។ ការ៉ែន៖ ជនជាតិ Karen គឺជាក្រុមជនជាតិភាគតិចដ៏ធំមួយទៀត ដែលមានទីតាំងនៅភាគអាគ្នេយ៍នៃប្រទេសមីយ៉ាន់ម៉ា។ ពួកគេមានជម្លោះជាយូរមកហើយជាមួយរដ្ឋាភិបាលមីយ៉ាន់ម៉ា ហើយមានអង្គការនយោបាយ និងយោធាផ្ទាល់ខ្លួន។ សាន៖ ជនជាតិ Shan គឺជាក្រុមជនជាតិភាគតិចធំមួយ ដែលមានទីតាំងនៅភាគខាងកើតប្រទេសមីយ៉ាន់ម៉ា។ ពួកគេមានអង្គការនយោបាយ និងយោធាផ្ទាល់ខ្លួន ហើយបានប្រឈមមុខនឹងការរើសអើង និងការរើសអើងពីរដ្ឋាភិបាលមីយ៉ាន់ម៉ា។ Chin: ជនជាតិ Chin គឺជាក្រុមជនជាតិភាគតិចដែលមានទីតាំងជាចម្បងនៅភាគខាងលិចប្រទេសមីយ៉ាន់ម៉ា។ ពួកគេបានប្រឈមមុខនឹងការរើសអើង និងការរើសអើងពីរដ្ឋាភិបាលមីយ៉ាន់ម៉ា និងមានអង្គការនយោបាយ និងយោធាផ្ទាល់ខ្លួន។[132] រីឯក្រុមជនជាតិដើមភាគតិចនៅក្នុងប្រទេសថៃ ក៏បានប្រឈមមុខនឹងបញ្ហាទាក់ទងនឹងការទទួលស្គាល់ និងការការពារក្នុងនោះរួមមានជនជាតិ ការ៉ែន៖ ជនជាតិ Karen ដែលមានទីតាំងនៅភាគខាងលិច និងភាគខាងត្បូងនៃប្រទេសថៃ មានប្រវត្តិជម្លោះជាមួយរដ្ឋាភិបាលថៃជាយូរមកហើយ ពួកគេមានអង្គការនយោបាយ និងយោធារបស់ពួកគេ ហើយបានប្រឈមមុខនឹងការរើសអើង ។ ជនជាតិម៉ុង៖ ជនជាតិ Hmong ដែលមានទីតាំងនៅតំបន់ភ្នំភាគខាងជើងនៃប្រទេសថៃ ក៏បានប្រឈមមុខនឹងការរើសអើង និងការរើសអើងផងដែរ។[133] ក្រៅពីប្រទេសដែលបានរៀបរាប់ខាងលើក៏នូវមានប្រទេសមួយចំនួនទៀតដែលពុំបានផ្តល់នូវសញ្ជាតិនិងសិទ្ធិជាពលរដ្ឋពេញលេខ ដូចជាប្រទេសកម្ពុជានោះឡើយ។

ប៉ុន្តែទោះបីជាសញ្ជាតិនិងភាពជាពលពលរដ្ឋត្រូវផ្តល់ជូន ជនជាតិភាគតិចនៅកម្ពុជាក៏ដោយ តែតាមរយៈការសិក្សាបានបង្ហាញថា ជនជាតិដើមភាគតិចនៅកម្ពុជា នៅតែបន្តប្រឈមមុខនឹងការរើសអើង និងការរើសអើង បើទោះបីជាទទួលបានសញ្ជាតិខ្មែរក៏ដោយ។[134] ការរើសអើងនេះអាចបង្ហាញក្នុងទម្រង់ផ្សេងៗគ្នា រួមមាន៖ លទ្ធភាពទទួលបានការអប់រំ និងការថែទាំសុខភាពមានកម្រិត៖ សហគមន៍ជនជាតិដើមភាគតិចច្រើនតែមានលទ្ធភាពទទួល

---

[131] Ethnic minorities and indigenous people - Open Development Vietnam (opendevelopmentmekong.net)
[132] Myanmar - IWGIA - International Work Group for Indigenous Affairs
[133] Thailand's Indigenous Peoples fight for 'land of our heart' (commentary) (mongabay.com)
[134] World Directory of Minorities and Indigenous Peoples - Cambodia : Indigenous peoples | Refworld

បានការអប់រំប្រកបដោយគុណភាព និងសេវាថែទាំសុខភាពមានកម្រិត ដែលអាចបន្តវដ្តនៃភាពក្រីក្រ និងគុណវិបត្តិ។ ការដកហូតដីធ្លី៖ ជនជាតិដើមភាគតិចអាចប្រឈមនឹងការដកហូតដីធ្លី និងការតាំងទីលំនៅថ្មីដោយបង្ខំ ដែលអាចរំខានដល់ការរស់នៅបែបប្រពៃណី និងទំនៀមទម្លាប់វប្បធម៌របស់ពួកគេ។ ការមិនរាប់បញ្ចូលសង្គម៖ បុគ្គលជនជាតិដើមភាគតិចអាចត្រូវបានដកចេញពីដំណើរការធ្វើការសម្រេចចិត្ត និងបដិសេធឱកាសសម្រាប់ភាពជាអ្នកដឹកនាំ និងតំណាង។ ការប្រកាន់ពូជសាសន៍ និងការរើសអើង៖ ជនជាតិដើមភាគតិចអាចប្រឈមមុខនឹងភាពអវិជ្ជមាន និងការរើសអើង ដែលអាចរួមចំណែកដល់ការរើសអើង និងការមិនរាប់បញ្ចូលក្នុងសង្គម។

ប៉ុន្តែទន្ទឹមនិងនេះ ដើម្បីដោះស្រាយបញ្ហាប្រឈមទាំងនេះ រដ្ឋាភិបាលកម្ពុជាបានចាត់វិធានការមួយចំនួន ដើម្បីលើកកម្ពស់សិទ្ធិជនជាតិដើមភាគតិច ទាំងនេះរួមមានៈការផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិ៖ កម្ពុជាបានផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន រួមទាំងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងជនជាតិដើម។ ការបង្កើតគណៈកម្មាធិការជាតិសម្រាប់ជនជាតិដើមភាគតិច៖ រដ្ឋាភិបាលបានបង្កើតគណៈកម្មាធិការជាតិសម្រាប់ជនជាតិដើមភាគតិច ដើម្បីលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់សហគមន៍ជនជាតិដើមភាគតិច។ ការអនុវត្តវិធានការមួយចំនួន៖ រដ្ឋាភិបាលបានអនុវត្តវិធានការបញ្ជាក់មួយចំនួន ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានជនជាតិដើមភាគតិច ដើម្បីទទួលបានការអប់រំ ការថែទាំសុខភាព និងឱកាសការងារ ទោះយ៉ាងណាក៏ដោយ ចាំបាច់ត្រូវធ្វើបន្ថែមទៀត ដើម្បីលុបបំបាត់ការរើសអើងលើជនជាតិដើមភាគតិចនៅកម្ពុជា នេះរួមមាន៖ ការពង្រឹងការអនុវត្តច្បាប់ប្រឆាំងការរើសអើង៖ រដ្ឋាភិបាលត្រូវពង្រឹងការអនុវត្តច្បាប់ប្រឆាំងការរើសអើង ដើម្បីធានាថាពួកគេកំពុងការពារសិទ្ធិជនជាតិដើមភាគតិចប្រកបដោយប្រសិទ្ធភាព។ការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិជនជាតិដើមភាគតិច៖ រដ្ឋាភិបាលចាំបាច់ត្រូវលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិជនជាតិដើមភាគតិចក្នុងចំណោមសាធារណជនទូទៅ និងមន្ត្រីរដ្ឋាភិបាល ការចូលរួមសហគមន៍ជនជាតិដើមភាគតិចក្នុងការសម្រេចចិត្ត៖ រដ្ឋាភិបាលចាំបាច់ត្រូវចូលរួមសហគមន៍ជនជាតិដើមភាគតិចក្នុងដំណើរការធ្វើការសម្រេចចិត្តដែលប៉ះពាល់ដល់ជីវិតរបស់ពួកគេ។ការផ្តល់ធនធានគ្រប់គ្រាន់ដល់សហគមន៍ជនជាតិដើមភាគតិច៖ រដ្ឋាភិបាលចាំបាច់ត្រូវផ្តល់ធនធានគ្រប់គ្រាន់ដល់សហគមន៍ជនជាតិដើមភាគតិច ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ និងការប្តេជ្ញាចិត្តដោយខ្លួនឯង តាមរយៈការចាត់វិធានការទាំងនេះ រដ្ឋាភិបាលកម្ពុជាអាចជួយបង្កើតសង្គមមួយបន្ថែមទៀត និងសមធម៌សម្រាប់ប្រជាពលរដ្ឋរបស់ខ្លួនទាំងអស់ រួមទាំងជនជាតិដើមភាគតិចផងដែរ។

### ៣.៤ ការគោរពតាមគោលការណ៍សន្ធិសញ្ញាស្តីពី ការលុបបំបាត់ ជនគ្មានសញ្ជាតិលើដែនដីកំណើតរបស់ខ្លួន

ការប្រកាន់ខ្ជាប់នូវគោលការណ៍នៃសន្ធិសញ្ញាស្តីពីការលុបបំបាត់ជនគ្មានរដ្ឋនៅក្នុងមាតុភូមិ សន្ធិសញ្ញាស្តីពីការលុបបំបាត់ជនគ្មានរដ្ឋ (១៩៥៤) បង្កើតស្តង់ដារអន្តរជាតិសម្រាប់ការព្យាបាលបុគ្គលដែលគ្មានរដ្ឋ។ ខណៈពេលដែលសន្ធិសញ្ញានេះសំដៅលើសិទ្ធិរបស់ជនគ្មានរដ្ឋនៅក្នុងប្រទេសបរទេស គោលការណ៍របស់វាក៏អាចពាក់ព័ន្ធទៅនឹងការប្រព្រឹត្តចំពោះជនគ្មានរដ្ឋនៅក្នុងទឹកដីកំណើតរបស់ពួកគេផងដែរ។[135]

នេះគឺជាគោលការណ៍សំខាន់ៗមួយចំនួនពីសន្ធិសញ្ញាដែលអាចអនុវត្តបានក្នុងស្រុក៖

ក. ការមិនរើសអើង៖ ការប្រព្រឹត្តិដោយស្មើភាពគ្នា៖ រដ្ឋគួរតែធានាថាជនគ្មានរដ្ឋនៅក្នុងទឹកដីរបស់ពួកគេត្រូវបានប្រព្រឹត្តដោយស្មើភាពជាមួយជាតិរបស់ពួកគេក្នុងបញ្ហាសិទ្ធិស៊ីវិល នយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌។ ការហាមឃាត់ការរើសអើង៖ រដ្ឋគួរតែហាមឃាត់ការរើសអើងណាមួយដោយផ្អែកលើសញ្ជាតិ ឬកង្វះសញ្ជាតិ។

ខ. សិទ្ធិស៊ីវិល និងសេរីភាព៖ សិទ្ធិជាមូលដ្ឋាន៖ រដ្ឋគួរតែធានាថា ជនគ្មានសញ្ជាតិទទួលបានសិទ្ធិស៊ីវិល និងសេរីភាពដូចសញ្ជាតិរបស់ពួកគេ រួមទាំងសិទ្ធិរស់រានមានជីវិត សេរីភាព សន្តិសុខរបស់មនុស្ស សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពខាងសាសនា។

គ. សិទ្ធិសេដ្ឋកិច្ច ការងារ៖ រដ្ឋគួរតែផ្តល់សិទ្ធិដល់ជនគ្មានសញ្ជាតិដូចជនជាតិខ្លួនក្នុងបញ្ហាការងារ រួមទាំងសិទ្ធិធ្វើការ សិទ្ធិទទួលបានលក្ខខណ្ឌការងារសមរម្យ និងយុត្តិធម៌ និងសិទ្ធិការពារប្រឆាំងនឹងភាពអត់ការងារធ្វើ។

ឃ. របបសន្តិសុខសង្គម៖ រដ្ឋគួរតែធានាថា ជនគ្មានរដ្ឋអាចទទួលបានអត្ថប្រយោជន៍សន្តិសុខសង្គមដោយផ្អែកលើមូលដ្ឋានដូចគ្នានឹងសញ្ជាតិរបស់ពួកគេដែរ។

ង. ការអប់រំ៖ សិទ្ធិទទួលបានការអប់រំ៖ រដ្ឋគួរតែធានាថាជនគ្មានសញ្ជាតិមានសិទ្ធិទទួលបានការអប់រំនៅលើមូលដ្ឋានដូចគ្នានឹងសញ្ជាតិរបស់ពួកគេដែរ។

ច. លំនៅដ្ឋាន៖លំនៅឋានសមរម្យ៖ រដ្ឋគួរតែធានាថា ជនគ្មានសញ្ជាតិមានសិទ្ធិទទួលបានលំនៅដ្ឋានគ្រប់គ្រាន់។

ឆ.សុខភាពសាធារណៈ៖សិទ្ធិទទួលបានសេវាថែទាំសុខភាព៖ រដ្ឋគួរតែធានាថាជនគ្មានរដ្ឋអាចទទួលបានសេវាសុខភាពសាធារណៈដោយផ្អែកលើមូលដ្ឋានដូចគ្នាទៅនឹងសញ្ជាតិរបស់ពួកគេដែរ។

ខណៈពេលដែលសន្ធិសញ្ញាផ្តោតជាចម្បងលើសិទ្ធិរបស់ជនគ្មានរដ្ឋនៅបរទេស គោលការណ៍ទាំងនេះអាចផ្តល់នូវក្របខ័ណ្ឌដ៏មានតម្លៃសម្រាប់រដ្ឋនានា ដើម្បីធានាថាជនគ្មានរដ្ឋនៅក្នុងព្រំដែនរបស់ពួកគេត្រូវបានប្រព្រឹត្តដោយយុត្តិធម៌ និងសមធម៌។ តាមរយៈការប្រកាន់ខ្ជាប់នូវគោលការណ៍ទាំងនេះ រដ្ឋអាចជួយកាត់បន្ថយភាពងាយរង

[135] សន្ធិសញ្ញាស្តីពីការលុបបំបាត់ជនគ្មានរដ្ឋ (១៩៥៤) បង្កើតស្តង់ដារអន្តរជាតិសម្រាប់ការព្យាបាលបុគ្គលដែលគ្មានរដ្ឋ

គ្រោះនៃជនគ្មានរដ្ឋ និងលើកកម្ពស់សមាហរណកម្មសង្គម និងសេដ្ឋកិច្ចរបស់ពួកគេ។វាជាការសំខាន់ក្នុងការកត់សម្គាល់ថាការអនុវត្តគោលការណ៍ទាំងនេះអាចប្រែប្រួលអាស្រ័យលើកាលៈទេសៈជាក់លាក់នៃប្រទេសនីមួយៗ។ រដ្ឋអាចនឹងត្រូវអនុម័តវិធានការបន្ថែម ដើម្បីដោះស្រាយតម្រូវការពិសេសរបស់មនុស្សគ្មានរដ្ឋនៅក្នុងទឹកដីរបស់ពួកគេ។

### ៣.៥ ភារកិច្ចរបស់រាជរដ្ឋាភិបាលក្នុងការបម្រើនិងថែទាំប្រជាពលរដ្ឋរបស់ខ្លួន

រាជរដ្ឋាភិបាល មានកាតព្វកិច្ចជាមូលដ្ឋានក្នុងការបម្រើ និងថែទាំប្រជាពលរដ្ឋរបស់ខ្លួន។ កាតព្វកិច្ចនេះត្រូវបានចាក់ឫសតាមគោលការណ៍អភិបាលកិច្ចល្អ សិទ្ធិមនុស្ស និងយុត្តិធម៌សង្គម។ ខាងក្រោមនេះជាចំណុចសំខាន់មួយចំនួននៃកាតព្វកិច្ចរបស់រដ្ឋាភិបាលក្នុងការបម្រើ និងថែទាំប្រជាជនរបស់ខ្លួនៈ

ការការពារសិទ្ធិមនុស្សៈ រដ្ឋាភិបាលមានកាតព្វកិច្ចការពារ និងលើកកម្ពស់សិទ្ធិមនុស្សរបស់ប្រជាពលរដ្ឋទាំងអស់ រួមទាំងសិទ្ធិរស់រានមានជីវិត សេរីភាព សន្តិសុខរបស់មនុស្ស សេរីភាពនៃការបញ្ចេញមតិ និងសេរីភាពខាងសាសនា។

ការផ្តល់សេវាសំខាន់ៗៈ រដ្ឋាភិបាលត្រូវតែផ្តល់សេវាសំខាន់ៗដល់ប្រជាពលរដ្ឋរបស់ខ្លួន ដូចជាការអប់រំ ការថែទាំសុខភាព ហេដ្ឋារចនាសម្ព័ន្ធ និងកម្មវិធីសុខុមាលភាពសង្គម។

ការអភិវឌ្ឍន៍សេដ្ឋកិច្ចៈ រដ្ឋាភិបាលទទួលខុសត្រូវលើការលើកកម្ពស់ការអភិវឌ្ឍន៍សេដ្ឋកិច្ច និងបង្កើតឱកាសសម្រាប់ប្រជាពលរដ្ឋរបស់ខ្លួនក្នុងការលើកកម្ពស់ជីវភាពរស់នៅរបស់ពួកគេ។

អភិបាលកិច្ចល្អៈ រដ្ឋាភិបាលត្រូវតែទទួលខុសត្រូវចំពោះប្រជាពលរដ្ឋ និងអនុវត្តអភិបាលកិច្ចល្អ ដែលរួមមានតម្លាភាព ការចូលរួម និងនីតិរដ្ឋ។

យុត្តិធម៌សង្គមៈ រដ្ឋាភិបាលត្រូវខិតខំធានានូវយុត្តិធម៌សង្គម និងសមធម៌ ដោយធានាថាប្រជាពលរដ្ឋទាំងអស់មានឱកាសស្មើគ្នា និងមិនត្រូវបានរើសអើងដោយផ្អែកលើសាវតា ឬកាលៈទេសៈរបស់ពួកគេ។[136]

ចំពោះរាជរដ្ឋាភិបាលកម្ពុជាបានបោះជំហានយ៉ាងសំខាន់ក្នុងការបំពេញកាតព្វកិច្ចបម្រើ និងថែទាំប្រជាពលរដ្ឋរបស់ខ្លួន ទោះយ៉ាងណាក៏ដោយ នៅតែមានបញ្ហាប្រឈមដែលត្រូវជម្នះ ដូចជាភាពក្រីក្រ វិសមភាព និងអំពើពុករលួយ តាមរយៈការបន្តផ្តល់អាទិភាពដល់តម្រូវការរបស់ប្រជាពលរដ្ឋ និងធ្វើការឆ្ពោះទៅរកសង្គមមួយដែល

[136] Human Rights Advocacy and the History of Human Rights Standards » Government Obligations (umich.edu)

យុត្តិធម៌ និងសមធម៌ជាងមុន រដ្ឋាភិបាលអាចបំពេញកាតព្វកិច្ចរបស់ខ្លួន និងកសាងប្រទេសកម្ពុជាឱ្យកាន់តែរឹងមាំ និងរីកចម្រើន។

# សេចក្តីសន្និដ្ឋាន

ក្រោយពីសិក្សាស្រាវជ្រាវចងក្រងសារណាលើប្រធានបទ ភាពជាពលរដ្ឋ និងការទទួលបានសញ្ជាតិខ្មែរ នាងខ្ញុំបានសិក្សាស្រាវជ្រាវដោយយកចិត្តទុកលើ សិទ្ធិនិងករណីកិច្ច របស់ប្រជាពលរដ្ឋខ្មែរ លក្ខខណ្ឌ បែបបទនីតិវិធីក្នុងការទទួលបានសញ្ជាតិខ្មែរ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីសញ្ជាតិខ្មែរ ២០១៨ ច្បាប់ស្តីពីច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣ អនុក្រឹត្យ ស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ២០១៨ និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនានា បានស្វែងយល់ជាច្រើន លើការបង្កើតរដ្ឋ សិទ្ធិរបស់ប្រជាពលរដ្ឋសកល ស្របតាមរដ្ឋធម្មនុញ្ញអង្គការសហប្រជាជាតិ និងសន្ធិសញ្ញា កតិកាសញ្ញា អន្តរជាតិនានា ជាពិសេសបានយល់ដឹងជាច្រើនអំពីសិទ្ធិនិងករណីកិច្ច របស់ប្រជាពលរដ្ឋខ្មែរ លក្ខខណ្ឌ បែបបទនីតិវិធីក្នុងការទទួលបានសញ្ជាតិខ្មែរ ហើយក៏អាចសន្និដ្ឋានបានថា ប្រជាពលរដ្ឋខ្មែរ ទទួលបានការគាំពារតាមរដ្ឋធម្មនុញ្ញនិងច្បាប់នានា ហើយព្រះរាជាណាចក្រកម្ពុជាបានទទួលស្គាល់ និងគោរពសិទ្ធិ មនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំង ឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិ សេរីភាពនិងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។ ការប្រើសិទ្ធិ សេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាព អ្នកដទៃឡើយ ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមល័ក្ខខ័ណ្ឌ កំណត់ក្នុងច្បាប់ ហើយជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និង មានសន្តិសុខផ្ទាល់ខ្លួនទោសប្រហារជីវិតមិនត្រូវ ឱ្យមានឡើយ ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យ ប្រទេសក្រៅណាមួយឡើយ លើកលែងតែមាន កិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ប្រជាពលរដ្ឋខ្មែរដែលកំពុងរស់នៅឯបរទេសត្រូវបាន រដ្ឋគាំពារ ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ មួយវិញទៀតសិទ្ធិជនជាតិដើមភាគតិចនៅកម្ពុជាត្រូវបានលើកតម្កើងនិងទទួលស្គាល់ថាជាពលរដ្ឋកម្ពុជាហើយ ពួកគេមានសិទ្ធិ និងទំនួលខុសត្រូវដូចគ្នានឹងពលរដ្ឋកម្ពុជាផ្សេងទៀត រួមទាំងសិទ្ធិបោះឆ្នោត កាន់តំណែងសាធារណៈ និងទទួលបានសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយផ្សេងទៀត ស្របតាមរដ្ឋធម្មនុញ្ញនិងច្បាប់សញ្ជាតិខ្មែរ នៃព្រះរាជាណាចក្រកម្ពុជា និងការផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិៈ កម្ពុជាបានផ្តល់សច្ចាប័នលើឧបករណ៍សិទ្ធិមនុស្សអន្តរជាតិជាច្រើន រួមទាំងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃ ការរើសអើងប្រឆាំងនឹងជនជាតិដើមផងដែរ ហើយបើ ប្រៀបធៀបនិង

ប្រទេសជិតខាងមួយចំនួនដែលពុំទទួលស្គាល់សិទ្ធិជនជាតិដើម មួយចំនួនជាពលរដ្ឋរបស់ខ្លួននោះទេ ទាំងនេះស បញ្ជាក់ថាពីភាពល្អប្រសើររបស់ព្រះរាជាណាចក្រកម្ពុជាក្នុងការក្នុងការបម្រើ និងថៃទាំប្រជាពលរដ្ឋរបស់ខ្លួនស្រប តាមគោលការណ៍ច្បាប់ជាតិ និងអន្តរជាតិលើការលើកកម្ពស់សិទ្ធិជាពលរដ្ឋ ក្នុងដែនដីរបស់ខ្លួនទោះបីជាជនទាំង នោះមានពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ខុសពីគ្នាក៏ដោយ។

ចំពោះច្បាប់ស្តីពីសញ្ជាតិខ្មែរថ្មី ឆ្នាំ ២០១៨ ដែលប្រកាសអោយប្រើជំនួសច្បាប់សញ្ជាតិខ្មែរចាស់កាលពីឆ្នាំ ១៩៩៦ ឃើញថាមានល្អប្រសើរស្របតាមសម័យកាល ដោយហេតុបច្ចុប្បន្នជាសម័យសកលភាវូបនីយកម្មដែល មានចរន្ត ប្រជាពលរដ្ឋធ្វើដំណើរ ដើម្បីប្រកបការងារនាប្រទេសផ្សេងៗនិងផ្លាស់ប្តូរទីលំនៅទៅរស់នៅប្រទេសផ្សេងៗ តាមរយៈគូស្វាមីភរិយាក្រោយការរៀបការរួច ជាក់ស្តែងព្រះរាជាណាចក្រកម្ពុជាជាប្រទេសដែលមានវប្បធម៌ចំណាស់ និងមានសក្កដានុពលលើវិស័យទេសចរណ៍ និងវិស័យអទិភាពមួយចំនួនដូចជាវិស័យ ឧស្សាហកម្ម កសិកម្ម ក្រោយ ព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាព ព្រះរាជាណាចក្រកម្ពុជា បានចូលជាសមាជិកអាស៊ាន អង្គការ ពាណិជ្ជកម្មពិភព និងអង្គការអន្តរជាតិនានា កត្តាទាំងអស់នេះហើយដែលទាក់ទាញអ្នកវិនិយោគ បរទេស និងជន អន្តោប្រវេសន៍ តាមបណ្តាប្រទេសនានា មករស់នៅធ្វើការ និងមានអ្នកវិនិយោគបរទេស និងជនអន្តប្រវេសន៍មួយ ចំនួនបានស្រលាញ់ពេញចិត្តក្នុងការសុំចូលសញ្ជាតិខ្មែរផង ដោយខ្លះតាមរយៈរៀបការនិងតាមរយៈសញ្ជាតិតូបនី យកម្ម កាន់តែមានចំនួនច្រើនឡើងៗ អាស្រ័យហេតុនេះច្បាប់ស្តីពីសញ្ជាតិខ្មែរថ្មីនេះ រួមនិងអនុក្រឹត្យ ស្តីពី ការអនុវត្ត ច្បាប់ស្តីពីសញ្ជាតិ ២០១៨ និងលិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធនានា ពិតជាមានសារប្រយោជន៍ណាស់ សម្រាប់ គ្រប់គ្រងការសុំចូលសញ្ជាតិនិងការលះបង់សញ្ជាតិខ្មែរ ហើយច្បាប់និងអនុក្រឹត្យនេះក៏បានចែងច្បាស់អំពី លក្ខខណ្ឌនិងនីតិវិធីចាប់បាច់ក្នុងការសុំចូលសញ្ជាតិនិងការលះបង់សញ្ជាតិខ្មែរយ៉ាងច្បាស់លាស់ ដែលបង្កលក្ខ ណៈងាយស្រួលចំពោះអ្នកវិនិយោគបរទេស និងជនអន្តប្រវេសន៍ដែលចង់សុំចូលសញ្ជាតិខ្មែរ ហើយភាព ច្បាស់លាស់នេះក៏បានចូលរួមយ៉ាងសំខាន់ក្នុងការទាក់ទាញ អ្នកវិនិយោគ ដើម្បីជួយជម្រុញកំណើនសេដ្ឋកិច្ចជាតិ ផងដែរ។

# អនុសាសន៍

ការសិក្សាស្រាវជ្រាវតាមរយៈសារណា លើប្រធានបទ **ភាពជាពលរដ្ឋ និងការទទួលបានសញ្ជាតិខ្មែរ** បានរកឃើញនូវចំណុចល្អប្រសើរ និងខ្វះចន្លោះខ្លះៗ ទន្ទឹមនិងនេះភាពខ្វះចន្លោះទាំងនោះអាចនឹងកំពុងកើតមានជាបន្តបន្ទាប់នាពេលបច្ចុប្បន្ន ក្នុងការអនុវត្តជាក់ស្តែង ដែលត្រូវកែតម្រូវនូវចំណុចខ្វះចន្លោះមួយចំនួនដូចជា៖

រាជរដ្ឋាភិបាលគួរកែទម្រង់មន្ថែមទៀតលើផ្តល់សញ្ជាតិខ្មែរជូនប្រជាពលរដ្ឋខ្មែរ និងជនបរទេសដែលចង់បានសញ្ជាតិខ្មែរបញ្ហាទាំងនោះរួមកន្លែងផ្តល់សេវាមានតិចកន្លែង និងមានចំងាយឆ្ងាយចំពោះពលរដ្ឋនៅជនបទដាច់ស្រយាល ការយល់ដឹងពីសារសំខាន់អំពីនៃចុះបញ្ជីកំណើត ដើម្បីទទួលបានការចុះសំបុត្រកំណើត ស្របតាមច្បាប់ស្តីពីអត្រានីកូលដ្ឋានឆ្នាំ២០២៣ នៅមិនទាន់មានភាពទូលំទូលាយនៅឡើយ ចំពោះជនបរទេសមួយចំនួនដែលបានបំពេញលក្ខខណ្ឌគ្រប់គ្រាន់ក្នុងការស្នើសុំសញ្ជាតិ តាមរយៈ តូបនីយកម្មឬរៀបការ ដែលមានបំណងដាក់ពាក្យស្នើសុំសញ្ជាតិខ្លួនឯងនៅពុំសូវយល់ច្បាស់ពីបែបបទនិងនីតិវិធីក្នុង ការស្នើសុំនិងមានការលំបាកក្នុងការរៀបចំឯកសារ ដោយហេតុថាការផ្សព្វផ្សាយច្បាប់សញ្ជាតិខ្មែរ ឆ្នាំ ២០១៨ និងអនុក្រឹត្យស្តីការអនុវត្តច្បាប់សញ្ជាតិ ឆ្នាំ ២០១៨ នៅមានលក្ខណៈតិចតួចនៅឡើយ និងមានការប្រើប្រាស់រយៈពេលយូរខុសកាលកំណត់ ការរត់ការជំនួសឬថ្លៃសេវាក្រៅប្រព័ន្ធ។

ចំពោះការយល់ដឹងពី បែបបទនីតិវិធីនៃការរៀបការរវាងជនបរទេសនិងប្រជាពលរដ្ឋខ្មែរនៅមានកម្រិតទាបនៅឡើយ ជាហេតុធ្វើឲមានការបោសប្រាស់របស់ជនបរទេសមួយចំនួនមកលើពលរដ្ឋខ្មែរ ជាពិសេសស្ត្រីត្រូវបានបោកបញ្ជោតរៀបការដើម្បីទៅរស់នៅខុសច្បាប់នៅឯបរទេស ក្នុងបំណងជួញដូរមនុស្សនិងកេងប្រវ័ញ្ចផ្លូវភេទ។

មួយវិញទៀតចំពោះបញ្ហាជនជាតិភាគតិច ទោះបីជាសញ្ជាតិនិងភាពជាពលពលរដ្ឋត្រូវផ្តល់ជូន ជនជាតិភាគតិចនៅកម្ពុជាក៏ដោយ តែ ជនជាតិដើមភាគតិចនៅកម្ពុជា នៅតែបន្តប្រឈមមុខនឹងការរើសអើង ការមិនចូលរួមនិងសង្គមទូទៅ មិនសូវបានយល់ច្បាស់លាស់ពីច្បាប់ទម្លាប់របស់ជាតិ ក្រៅពីប្រពៃណីទំនៀមទំលាប់របស់ខ្លួនបើទោះបីជា ទទួលបានសញ្ជាតិខ្មែរក៏ដោយ រីឯជនជាតិភាគតិចមួយចំនួនក៏ពុំបានយល់ពីការបំពេញបែបបទឲបានគ្រប់គ្រាន់ដើម្បីទទួលសិទ្ធិជាពលរដ្ឋនៅឡើយទេ អាស្រ័យហេតុនេះរាជរដ្ឋាភិបាល តាមរយៈក្រសួងមហាផ្ទៃ គួរពង្រឹងការផ្សព្វផ្សាយ ពីសារសំខាន់នៃលិខិតបទដ្ឋានគតិយុត្តិ មានដូចជាសំបុត្រកំណើត អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ជាដើមដើម្បីទទួលសិទ្ធិជាពលរដ្ឋពេញលេញផងដែរ។

## ឯកសារយោង

-រដ្ឋធម្មនុញ្ញ ឆ្នាំ ១៩៩៣
-ច្បាប់សញ្ជាតិ ឆ្នាំ ២០១៨
-ច្បាប់អត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម ២០២៣
-ក្រមរដ្ឋប្បវេណី ឆ្នាំ ២០០៧
-ក្រមនីតិវិធីរដ្ឋប្បវេណី ឆ្នាំ ២០០៦
-ច្បាប់ ស្តីពី ការអនុម័តយល់ព្រមអោយព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនិងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៦

## ច្បាប់អន្តរជាតិ

-ធម្មនុញ្ញអង្គការសហប្រជាជាតិ ឆ្នាំ ១៩៤៥
-សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ឆ្នាំ ១៩៤៨
-អនុសញ្ញាទីក្រុងញូយ៉ក ឆ្នាំ ១៩៥៤ ស្តីពីការទប់ស្កាត់និងលុបបំបាត់ស្ថានភាពនៃជនគ្មានសញ្ជាតិ
-ច្បាប់ស្តីពីការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជាចូលជាភាគីនៃអនុសញ្ញាក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងការសុំកូនអន្តរប្រទេស ឆ្នាំ ២០០៧ មាត្រា ៤

## អនុក្រឹត្យ

-អនុក្រឹត្យស្តីពី ការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ឆ្នាំ ២០១៨
-អនុក្រឹត្យ ១០៣ អនក្រ.បក ស្តីពីអត្រានុកូលដ្ឋាន ឆ្នាំ ២០០០
-អនុក្រឹត្យលេខ១៨៣ អនក្រ.បក ស្តីពីការកំណត់បែបបទ និងនីតិវិធីនៃការរៀបអាពាហ៍ពិពាហ៍ រវាងពលរដ្ឋខ្មែរ និងជនបរទេស ឆ្នាំ ២០០៨

## គេហទំព័រផ្សេងៗ

state | Wex | US Law | LII / Legal Information Institute
https://migrationobservatory.ox.ac.uk//resources/primers/citizenship-what-is-it-and-why-does-it-matter
https://www.un.org/en/about-us/universal-declaration-of-human-rights
https://www.un.org/en/about-us/universal-declaration-of-human-rights
Ethnic minorities and indigenous people - Open Development Vietnam (opendevelopmentmekong.net)
Myanmar - IWGIA - International Work Group for Indigenous Affairs
Thailand’s Indigenous Peoples fight for ‘land of our heart’ (commentary) (mongabay.com)

**ព្រះរាជក្រម**

នស/រកម/០៦១៨/០០៩

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សម្មហោរាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ប្រកាសឲ្យប្រើ**

ច្បាប់ស្តីពីសញ្ជាតិ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨ នាសម័យប្រជុំរដ្ឋសភាលើកទី១០ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០១៨ នាសម័យប្រជុំពេញអង្គលើកទី១ នីតិកាលទី៤ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

# ច្បាប់

# ស្ដីពី

# សញ្ជាតិ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ១
# បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ច្បាប់នេះមានគោលបំណងធានាការអនុវត្តដែនយុត្តាធិការរបស់ព្រះរាជាណាចក្រកម្ពុជាទៅលើរូបវន្តបុគ្គល ដើម្បីកំណត់នូវសិទ្ធិទទួលបាន និងសិទ្ធិលះបង់សញ្ជាតិខ្មែរ ចំពោះជនដែលរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស និងដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។

**មាត្រា២ .-**

ច្បាប់នេះមានគោលដៅកំណត់អំពី ៖

- ការទទួលបានសញ្ជាតិខ្មែរពីកំណើត
- ការទទួលបានសញ្ជាតិខ្មែរដោយការសុំកូនពេញលេញ
- ការទទួលបានសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍
- ការទទួលបានសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម
- ការបាត់សញ្ជាតិខ្មែរ ។

**មាត្រា៣ .-**

ច្បាប់នេះមានវិសាលភាពអនុវត្តចំពោះរូបវន្តបុគ្គលដែលកើត ឬរស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ឬនៅបរទេស ។

**មាត្រា៤ .-**

វាក្យសព្ទសំខាន់ៗដែលប្រើក្នុងច្បាប់នេះ ត្រូវបានកំណត់និយមន័យដូចតទៅ ៖

១-សញ្ជាតិខ្មែរ សំដៅដល់ចំណងគតិយុត្ត និងនយោបាយដែលភ្ជាប់រូបវន្តបុគ្គលទៅនឹងព្រះរាជាណាចក្រកម្ពុជា ។

២- ការទាមទារសញ្ជាតិខ្មែរ សំដៅដល់សិទ្ធិក្នុងការស្នើសុំសញ្ជាតិខ្មែរ ដែលកើតចេញពីចំណងអាពាហ៍ពិពាហ៍ស្របច្បាប់រវាងជនបរទេស និងប្រជាពលរដ្ឋខ្មែរ ។

៣- សញ្ជាតូបនីយកម្ម សំដៅដល់ការផ្តល់សញ្ជាតិខ្មែរតាមរយៈការស្នើសុំរបស់ជនបរទេស ដោយផ្អែកតាមលក្ខខណ្ឌនៃការស្នាក់នៅ ការវិនិយោគ អំណោយជាសាច់ប្រាក់ និងគុណសម្បត្តិពិសេស ឬថ្វីដៃពិសេស ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

## ជំពូកទី ២
## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៥ .–**

ក្រសួងមហាផ្ទៃមានសមត្ថកិច្ចដឹកនាំអនុវត្តច្បាប់ស្តីពីសញ្ជាតិ ។

## ជំពូកទី ៣
## គោលការណ៍ទូទៅ

**មាត្រា៦ .–**

ជនណាមានសញ្ជាតិខ្មែរជាប្រជាពលរដ្ឋខ្មែរ ។

មានតែប្រជាពលរដ្ឋខ្មែរទេ ទើបមានសិទ្ធិទទួលនិងកាន់កាប់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរនិងលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៧ .–**

ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

**មាត្រា៨ .–**

ប្រជាពលរដ្ឋខ្មែរ ដែលកំពុងរស់នៅឯបរទេស៖

១. ត្រូវបានរដ្ឋគាំពារតាមគ្រប់មធ្យោបាយការទូត ។

២. មិនអាចបាត់សញ្ជាតិដោយឯកឯង ។

## ជំពូកទី ៤
## សញ្ជាតិខ្មែរពីកំណើត និងសញ្ជាតិខ្មែរពីការសុំចូលសញ្ជាតិ
### ផ្នែកទី ១
### សញ្ជាតិខ្មែរពីកំណើត

**មាត្រា៩ .–**

១- ត្រូវបានសញ្ជាតិខ្មែរ ទោះបីកើតនៅទីណាក៏ដោយ ៖

- កូនដែលកើតពីឪពុកឬម្តាយមានសញ្ជាតិខ្មែរឬ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

- កូនដែលឪពុកម្ដាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬម្ដាយដែលមានសញ្ជាតិខ្មែរ ។

២- ត្រូវបានសញ្ជាតិខ្មែរ ដោយកើតក្នុងព្រះរាជាណាចក្រកម្ពុជា ៖

- កូនដែលកើតពីឪពុកនិងម្ដាយជាជនបរទេស ដែលកើតនិងរស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា

- កូនដែលកើតពីឪពុកម្ដាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុង ព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកថា កើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែរ ។

## ផ្នែកទី ២
## សញ្ជាតិខ្មែរដោយការសុំកូនពេញលេញ

**មាត្រា១០ .-**

កូនជនបរទេសដែលត្រូវបានសុំជាកូនសុំពេញលេញដោយសហព័ទ្ធពលរដ្ឋខ្មែរ ត្រូវទទួលបានសញ្ជាតិខ្មែរ នៅពេលដែលសុំកូនពេញលេញត្រូវបានបង្កើតឡើងស្របតាមច្បាប់ជាធរមាន ។

## ជំពូកទី ៥
## សញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍

**មាត្រា១១ .-**

ស្ត្រី ឬបុរសបរទេសដែលយកប្ដី ឬប្រពន្ធពលរដ្ឋខ្មែរដោយបានរៀបអាពាហ៍ពិពាហ៍ អាចទាមទារសញ្ជាតិខ្មែរបាន លុះណាតែស្ត្រី ឬបុរសនោះបានរស់នៅជាមួយគ្នារយៈពេលបីឆ្នាំ ក្រោយចុះបញ្ជីអាពាហ៍ពិពាហ៍ និងបានស្នាក់នៅយ៉ាងហោចរយៈពេល ១២ (ដប់ពីរ)ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ត្រូវបានអនុញ្ញាតឱ្យសុំទាមទារសញ្ជាតិខ្មែរជាចង្កោមគ្រួសារចំពោះជនបរទេសជាម្ដាយ ឬឪពុកដែលមានកូនជាអនីតិជន ។

**មាត្រា១២ .-**

ជនបរទេសដែលអាចសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍បាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ៖

១- មានគំនិត មារយាទ និងសីលធម៌ល្អ ។

២- ពុំដែលមានទោសពីបទឧក្រិដ្ឋឬបទមជ្ឈិមណាមួយ ។

៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅពេលដាក់ពាក្យសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ។

៤- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

៥- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

**មាត្រា១៣ .-**

ជនបរទេសដែលសុំទាមទារសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍អាចសុំប្តូរឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះ ត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះ ក្នុងពាក្យសុំទាមទារសញ្ជាតិខ្មែររបស់ខ្លួន ។

**មាត្រា១៤ .-**

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចបដិសេធការទាមទារសញ្ជាតិខ្មែរ សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ា ។

**មាត្រា១៥ .-**

បែបបទ និងនីតិវិធីនៃការទាមទារសញ្ជាតិខ្មែរ ព្រមទាំងនីតិវិធីនៃការប្តឹងតវ៉ា ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរ តាមករណីទាមទារសញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

**មាត្រា១៦ .-**

ជនដែលបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយអាពាហ៍ពិពាហ៍ ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះ ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា១៧ .-**

ប្រជាពលរដ្ឋខ្មែរមិនបាត់សញ្ជាតិខ្មែរ ដោយសារការរៀបអាពាហ៍ពិពាហ៍ជាមួយជនបរទេសទេ ។

## ជំពូកទី ៦
## សញ្ជាតូបនីយកម្ម

**មាត្រា១៨ .-**

ជនបរទេសអាចសុំចូលសញ្ជាតិខ្មែរបាន ដោយសញ្ជាតូបនីយកម្ម ។

សញ្ជាតូបនីយកម្មមិនមែនជាសិទ្ធិរបស់អ្នកស្នើសុំឡើយ គឺជាការអនុគ្រោះរបស់ ព្រះរាជាណាចក្រកម្ពុជាតែប៉ុណ្ណោះ ។ ទោះក្នុងប្រការណាក៏ដោយ ពាក្យសុំនោះអាចត្រូវបដិសេធចោលតាមអំណាចឆន្ទានុសិទ្ធិ ។

**មាត្រា១៩ .-**

ជនបរទេសដែលអាចសុំសញ្ជាតូបនីយកម្មបាន ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ៖

១- មានគំនិត មារយាទ និងសីលធម៌ល្អ ។

២- ពុំដែលមានទោសពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

៣- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយស្នាក់នៅជាប់ចំនួន ៧ (ប្រាំពីរ)ឆ្នាំ ដោយគិតពីថ្ងៃដែលបានទទួលបណ្ណស្នាក់នៅ ដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះបរមរាជវាំង

ជនបរទេសអន្តោប្រវេសន្ត ។

៤- មានទីលំនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងមានបណ្ណស្នាក់នៅដែលចេញឱ្យក្នុងក្របខ័ណ្ឌនៃច្បាប់ស្តីពីអន្តោប្រវេសន៍ ចំពោះជនបរទេសដែលបានកំណត់នៅក្នុងមាត្រា២១ និងមាត្រា២២ នៃច្បាប់នេះ ។

៥- ចេះនិយាយភាសាខ្មែរ ចេះអក្សរខ្មែរ និងយល់ដឹងប្រវត្តិសាស្ត្រខ្មែរខ្លះៗ ហើយបង្ហាញភស្តុតាងថាខ្លួនអាចរស់នៅក្នុងសង្គមខ្មែរបានដោយសុខដុម ព្រមទាំងទទួលបាននូវទំនៀមទម្លាប់និងប្រពៃណីល្អរបស់ខ្មែរ ។

៦- មានបញ្ញា និងកាយសម្បទាដែលមិននាំឱ្យមានគ្រោះថ្នាក់ ឬនាំឱ្យមានបន្ទុកដល់ជាតិ ។

**មាត្រា២០ .–**

ចំពោះជនបរទេសអន្តោប្រវេសន្តណាដែលកើតក្នុងព្រះរាជាណាចក្រកម្ពុជា រយៈពេលស្នាក់នៅជាប់ចំនួន ៧ (ប្រាំពីរ)ឆ្នាំ ដូចមានចែងក្នុងចំណុចទី៣ មាត្រា១៩ នៃច្បាប់នេះ ត្រូវបន្ថយមកនៅ ៣(បី)ឆ្នាំវិញ ។

**មាត្រា២១ .–**

ជនបរទេសណាដែលបានទទួលការអនុញ្ញាតឱ្យវិនិយោគត្រឹមត្រូវតាមច្បាប់ ពីស្ថាប័នមានសមត្ថកិច្ច ហើយបានចំណាយទុនអនុវត្តគម្រោងវិនិយោគជាក់ស្តែងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីជនបរទេសនោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ ទី៥ និងទី៦ មាត្រា១៩ នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ១២ (ដប់ពីរ) ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំនួនទឹកប្រាក់ វិស័យអាទិភាព និងប្រភេទគម្រោងវិនិយោគ ព្រមទាំងលក្ខខណ្ឌផ្សេងទៀត ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា២២ .–**

ជនបរទេសណាដែលបានធ្វើអំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ សម្រាប់ជាផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ឬវិស័យមនុស្សធម៌នៅព្រះរាជាណាចក្រកម្ពុជា ជនបរទេសនោះអាចដាក់ពាក្យសុំចូលសញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ ទី៤ និងទី៦ មាត្រា១៩ នៃច្បាប់នេះ និងបានស្នាក់នៅស្របច្បាប់យ៉ាងហោចរយៈពេល ៦ (ប្រាំមួយ)ខែ ពេញលេញ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ចំនួនទឹកប្រាក់អំណោយជាសាច់ប្រាក់ដល់ថវិកាជាតិ ឬវិស័យមនុស្សធម៌ត្រូវកំណត់ដោយអនុក្រឹត្យ ។

**មាត្រា២៣ .–**

ជនបរទេសដែលបានបង្ហាញនូវភស្តុតាងថា ខ្លួនបានផ្តល់គុណសម្បត្តិពិសេស ឬថ្វីដៃពិសេសអ្វីមួយជាប្រយោជន៍ដល់ព្រះរាជាណាចក្រកម្ពុជា និងបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា អាចដាក់ពាក្យស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មបាន ក្នុងករណីដែលជននោះបានបំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី១ ទី២ និងទី៦ មាត្រា១៩ នៃច្បាប់នេះ ។

**មាត្រា២៤ .-**

ជនបរទេសដែលមានសហព័ទ្ធ ឬកូនជាអនីតិជន ដែលមានបំណងស្នើសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម អាចដាក់ពាក្យស្នើសុំជាចង្កោមគ្រួសារ ។

**មាត្រា២៥ .-**

ជនបរទេសអាចសុំប្តូរឈ្មោះជាខ្មែរបាន ។ ក្នុងករណីនេះត្រូវសរសេរបញ្ជាក់ឈ្មោះថ្មីនោះ ក្នុងពាក្យសុំសញ្ជាតូបនីយកម្មរបស់ខ្លួន ។

**មាត្រា២៦ .-**

បែបបទ និងនីតិវិធីនៃការសុំចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការផ្តល់សញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្មត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

**មាត្រា២៧ .-**

ជនដែលបានអនុញ្ញាតឱ្យចូលសញ្ជាតិខ្មែរដោយសញ្ជាតូបនីយកម្ម ត្រូវធ្វើសម្បថនៅចំពោះមុខតុលាការកំពូល ។

ខ្លឹមសារនៃសម្បថនេះត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៧
## ការបាត់សញ្ជាតិខ្មែរ

**មាត្រា២៨ .-**

ជនណាដែលមានសញ្ជាតិខ្មែរហើយមានអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ យ៉ាងតិច អាចសុំលះបង់សញ្ជាតិខ្មែរបាន ក្នុងករណីដែលជននោះមានសញ្ជាតិមួយផ្សេងទៀតនិងដោយគ្មានការបង្ខិតបង្ខំ ។

ត្រូវបានអនុញ្ញាតឱ្យមានការសុំលះបង់សញ្ជាតិខ្មែរជាចង្កោមគ្រួសាររបស់ពលរដ្ឋខ្មែរជាម្តាយ ឬឪពុកដែលមានកូនជាអនីតិជន ។

**មាត្រា២៩ .-**

បែបបទ និងនីតិវិធីនៃការសុំលះបង់សញ្ជាតិ ត្រូវកំណត់ដោយអនុក្រឹត្យ ។

ការអនុញ្ញាតឱ្យលះបង់សញ្ជាតិខ្មែរ ត្រូវសម្រេចដោយព្រះរាជក្រឹត្យ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

# ជំពូកទី ៨
## ទោសប្បញ្ញត្តិ

**មាត្រា៣០ .-**

ជនបរទេសណាដែលកាន់កាប់ និងប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ) ឆ្នាំទៅ ១០ (ដប់) ឆ្នាំ ។

មន្ត្រី ភ្នាក់ងាររាជការ ឬជនណាធ្វើអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជាឱ្យជនណាម្នាក់ ដែលមិនមានសញ្ជាតិខ្មែរត្រូវផ្តន្ទាទោសដូចគ្នានឹងកថាខ័ណ្ឌទី១ ខាងលើនៃមាត្រានេះ ។

**មាត្រា៣១ .-**

ជនណាដែលក្លែងបន្លំអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ (ប្រាំ)ឆ្នាំ ទៅ១០(ដប់)ឆ្នាំ ។

ត្រូវចាត់ទុកជាការក្លែងបន្លំផងដែរនូវអំពើធ្វើការកោស លុប សរសេរបន្ថែម ឬធ្វើឱ្យខូចខាតការពិតនូវព័ត៌មាននៅក្នុងអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៣២ .-**

ជនណាដែលប្រើប្រាស់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ឬលិខិតឆ្លងដែននៃព្រះរាជាណាចក្រកម្ពុជាក្លែង ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ៥(ប្រាំ)ឆ្នាំ និងពិន័យជាប្រាក់ពី ៤ ០០០ ០០០(បួនលាន) រៀលទៅ ១០ ០០០ ០០០(ដប់លាន)រៀល ។

**មាត្រា៣៣ .-**

អ្នកផ្តើមគំនិត និងអ្នកសមគំនិតត្រូវទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ ស្របតាមលក្ខខណ្ឌដូចមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

**មាត្រា៣៤ .-**

ចំពោះរូបវន្តបុគ្គលដែលប្រព្រឹត្តបទល្មើសដូចមានចែងក្នុងមាត្រា៣០ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ តុលាការអាចប្រកាសទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា៥៤ (ប្រភេទទោសបន្ថែម) នៃក្រមព្រហ្មទណ្ឌ ។

**មាត្រា៣៥ .-**

នីតិបុគ្គលអាចត្រូវប្រកាសថា ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤២ (ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ចំពោះបទល្មើសដែលមានចែងក្នុងមាត្រា៣០

មាត្រា៣១ និងមាត្រា៣២ នៃច្បាប់នេះ។

នីតិបុគ្គលត្រូវផ្តន្ទាទោសពិន័យជាប្រាក់ពី ១០ ០០០ ០០០(ដប់លាន)រៀលទៅ ១០០ ០០០ ០០០ (មួយរយលាន) រៀល ព្រមទាំងទោសបន្ថែមមួយ ឬច្រើន ដូចមានចែងក្នុងមាត្រា១៦៨ (ទោសបន្ថែមអនុវត្តចំពោះនីតិបុគ្គល)នៃក្រមព្រហ្មទណ្ឌ ។

## ជំពូកទី ៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣៦ .-**

លិខិតបទដ្ឋានគតិយុត្តទាំងឡាយពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីសញ្ជាតិ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ត្រូវមានអានុភាពអនុវត្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

## ជំពូកទី ១០
## អវសានប្បញ្ញត្តិ

**មាត្រា៣៧ .-**

ច្បាប់ស្តីពីសញ្ជាតិដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី ៩ ខែ តុលា ឆ្នាំ ១៩៩៦ ត្រូវទុកជានិរាករណ៍ និងជំនួសដោយច្បាប់នេះ ។

**មាត្រា៣៨ .-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃព្រហស្បតិ៍ ៩កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨

នស/រកម.០៦១៨.០១៣

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**
**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្តលេខា
**នាយករដ្ឋមន្ត្រី**
**ហត្ថលេខា**
**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**
**ហត្ថលេខា**
**សម្តេចក្រឡាហោម ស ខេង**

លេខ:៦៦១ ស.ណ
**សំណៅដែលមានតម្លៃជាការចែកផ្សាយ**
ថ្ងៃសុក្រ ១០កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ .ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០១៨
**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**